# PROPHETIC REVELATION

# ការចាប់ផ្ដើម
# នៃការបង្កើត
# របស់ព្រះ

ព្រះ
នៃ អ័ប្រាហាំ
អ៊ីសាក យ៉ាកុប.០៥

អ្នកណាដែលមានត្រចៀក ចូរឱ្យអ្នកនោះស្ដាប់ចុះ!

# បុព្វបទ

*មេនដេល ខ្រាវីត្យ ជាជនជាតិជីហ្វ ( ជា) អាយុ ៨៤ ឆ្នាំ ត្រូវបានឡានបុក នៅក្នុងទីក្រុងញូវយ៉ក និងដេកហូរឈាមនៅលើផ្លូវដើរ។ ប៉ូលីសម្នាក់បានមកដល់ឃើញហេតុការណ៍នោះ ហើយពេលកំពុងក្រលេកមើលជនរងគ្រោះ ភ្លាមនោះក៏បានទូរសព្ទ័ហៅឡានពេទ្យ និងបូជាចារ្យ (សង្ឃ) ម្នាក់ ។*

លោកបូជាចារ្យ បានមកដល់មុន ហើយឱនពីលើខ្រាវីត្យ គាត់បានសួរថា *"តើអ្នកជឿលើព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធឬទេ?"* ខ្រាវីត្យបានងើយក្បាលឡើង បើកភ្នែកធំៗ ហើយបែរទៅហ្វូងមនុស្ស ដែលបានផ្តុំគ្នានៅជុំវិញគាត់។ *"ខ្ញុំដេកនៅទីនេះជិតស្លាប់ហើយ បែរជាគាត់សួរពាក្យបណ្តៅខ្ញុំវិញ !"*

~ ~ ~ ~ ~ ~ ~

**ភាពល្ងង់ខ្លៅ** មិនមែនជាសេចក្តីសុខទេ ។ ជារឿយៗ អ្នកសរសេរសញ្ញាថ្មី អំពាវនាវដល់យើង ឲ្យដឹង និងច្បាស់លាស់ពីអ្វី ដែលយើងជឿ។ ការសង្កេតរបស់អ្នកបរិសុទ្ធប៉ូល "តើអ្នកមិនដឹងទេឬអ្វី?" បានជាមានញឹកញាប់នៅក្នុងសំបុត្ររបស់គាត់។

គោលលទ្ធិខុសឆ្គងនៅសម័យព្រះយេស៊ូគ្រីស្ទ នាំឲ្យមនុស្សល្ងង់ខាងឯគម្ពីរ ព្រមទាំងអនុវត្តតាម ***"សេចក្តីបង្រៀនជាគោលលទ្ធិ ជាបញ្ញត្តិរបស់មនុស្សវិញ"*** (ម៉ាថា ១៥: ៩)។ អញ្ចឹង តើគ្រីស្ទានសព្វថ្ងៃនេះ ល្ងង់ល្ងើខ្លាំងប៉ុណ្ណារទៅ?ចូរពិចារណាមើលការបន្ទោសរបស់ព្រះអម្ចាស់យេស៊ូរបស់យើង- *"អ្នករាល់គ្នាមិនដឹងជាថ្វាយបង្គំអ្វីទេ"*(យ៉ូហាន៤:២២)។

មិត្តអើយ តើអ្នកដឹងថា អ្នកថ្វាយបង្គំអ្វីឬទេ ឬអ្នកគ្រាន់តែដើរតាមទំលាប់នៃវិហារអ្នក? តើព្រះរបស់អ្នក គឺជា **ព្រះនៃអ័ប្រាហាំ អ៊ីសាក និងយ៉ាកុបឬ?**

គោលបំណងនៃសៀវភៅនេះ គឺត្រូវតែបង្ហាញយ៉ាងសង្ខេប និងយ៉ាងច្បាស់លាស់អំពី**ការបើកសំដែងនៃសេចក្តីអាថ៌កំបាំងនៃការគោរពប្រណិប័តន៍ព្រះជាម្ចាស់** (១ធីម៉ូថេ ៣:១៦) ឬអំពីប្រធានបទនៃ**ព្រះដ៏ជាកំពូល**នៃព្រះគម្ពីរបរិសុទ្ធ។ ខ្ញុំទទូចជំរុញឲ្យអ្នកពិនិត្យមើលបទគម្ពីរដោយសង្វាត រហូតទាល់តែសេចក្តីពិតបានសំដែងដល់អ្នក។

បន្ទាប់ពិការលើកព្រះយេស៊ូគ្រីស្ទឡើងទៅស្ថានសួគ៌មិនបាន ៣០០ ឆ្នាំផង គ្រីស្ទសាសនាបានក្លាយទៅជាសាសនាអង្គការ ហើយពន្លឺនៃព្រះពិតតែ ១ ក៏បានទៅជាងងឹតភ្លាម ដោយ**ពួកទេវវិទូ ដែលបានអធិប្បាយ និងបានបង្រៀនលទ្ធិសាសនា និងសទ្ធាន្តរបស់អង្គការ** និងទំលាប់របស់មនុស្ស ជាជាងព្រះបន្ទូលនៃព្រះ។ ហេតុនេះហើយ បានជាឥឡូវនេះមានការបកស្រាយខុសៗគ្នាជាច្រើនទៅលើគោលលទ្ធិនៃព្រះដ៏ជាកំពូល (Godhead)។ មួយភាគធំជឿថា ព្រះជាម្ចាស់ គឺជា **ព្រះត្រៃសរណគមន៍ ឬ ព្រះត្រៃឯកមានបីអង្គ** រីឯអ្នកខ្លះជឿថា ទ្រង់មាន២អង្គ។ ហើយមានអ្នកផ្សេងទៀតជឿថា ទ្រង់ជាព្រះ ១អង្គ ប៉ុន្តែបដិសេធភាពជាព្រះនៃព្រះយេស៊ូគ្រីស្ទពួកបរិសុទ្ធនៃសម័យគម្ពីរមិនដែលស្ទង់មើលអំពីព្រះទេ។ ពួកអ្នកជឿក្រោយៗបានចាប់ផ្តើមបាត់បង់គំហើញនៃព្រះបន្ទូលព្រះ និងបោះបង់មូលដ្ឋានគ្រឹះរបស់ព្រះបន្ទូលចោល នៅពេលដែលពួកគេបានរសាត់ចេញពីការដឹកនាំនៃព្រះវិញ្ញាណបរិសុទ្ធ។ បន្ទាប់មក គំនិតមនុស្សបានឈ្នះនិងការស្ទង់មើលអំពីព្រះបានក្លាយទៅជារឿងទូទៅ ។

នៅក្នុងកំឡុងពេល និងក្រោយសតវត្សទី១នៃដំណឹងល្អ ពួកជីហ្វមួយភាគធំ បានកាន់យ៉ាងម៉ត់ចត់ចំពោះជំនឿលើព្រះ១អង្គ ប៉ុន្តែពួកគេមិនបានដឹងថា ព្រះយេស៊ូគ្រីស្ទ គឺជាព្រះជាម្ចាស់ដែលលេចចេញមកក្នុងសាច់ឈាមជាព្រះមែស៊ីរបស់ពួកគេទេ។ អង្គការគ្រីស្ទសាសនា មិនមានការប្រសើរនៅក្នុងជំនឿរបស់ពួកគេទេ។ ពួកគេបានបង្វែរជំនឿលើព្រះតែ១អង្គរបស់អ័ប្រាហាំ ទៅជាព្រះច្រើនអង្គវិញ។ ពួកទេវវិទូរបស់ពួកគេបានយកព្រះនៃអ័ប្រាហាំទៅកាត់ជា៣ចំណែកហើយបន្ទាប់មកទៀត ខំនាំកូនចៅរបស់គាត់ឲ្យកាន់សាសនាគ្រីស្ទ ដោយផ្តល់ចំណែកទី២ដល់ពួកគេ។ ពួកគេក៏នៅតែកំពុងធ្វើការនោះដែរ។

ទោះបីជាគោលលទ្ធិនៃ**ភាព១អង្គនៃព្រះកំពូល** ដែលអ្នកជឿពិតខ្លះបានជឿ និងទទួលថា ជាសេចក្តីពិតក៏ដោយ ក៏មានមនុស្សជាច្រើននៅក្នុងចំណោមពួកគេ ពិតជាបានយល់យ៉ាងច្បាស់លាស់ទេ។

កុំឲ្យគ្រាន់តែស្កប់ចិត្តនឹងអ្វី ដែលអ្នកជឿឡើយ ប៉ុន្តែសូមឲ្យស្កប់ចិត្តនឹងជំនឿរបស់អ្នកគឺជា សេចក្តីពិតដែរ។ មានអ្នកជឿគម្ពីរ ច្រើនណាស់ ដែលមានចំណេះដឹងខ្ពស់ មកពីគ្រូអធិប្បាយជាទីពេញចិត្តរបស់ពួកគេ (តើពួកគេជាសាវក ហោរា គ្រូផ្សាយដំណឹងល្អ គ្រូគង្វាល គ្រូបង្រៀនឬ )នឹងសេចក្តីបង្រៀនរបស់ពួកគេ ប៉ុន្តែមានតិចតួចទេ ដែលពេញដោយព្រះវិញ្ញាណ និងស្កប់ស្កល់ដោយព្រះបន្ទូល ។ កុំនិយាយថា *"ខ្ញុំជឿ"* ទាល់តែអ្នកច្បាស់ថា អ្នកពិតជាបានទទួលការបើកសំដែង ពីព្រះវិញ្ញាណនៃ ព្រះអម្ចាស់:ត្បិតសេចក្តី

ឡូហ្កុស: ការចាប់ផ្ដើមដំបូងនៃការបង្កើតរបស់ព្រះ

ទាំងនោះត្រូវពិចារណាយល់ខាងវិញ្ញាណវិញ (១កូរិថូស ២: ១៤ )។ បើមិនបានប្រទានមកពីលើទេ នោះក៏គ្មានការបើកសំដែងណា ជាការបើកសំដែងពិតដែរ។ *"ឯព្រះទ្រង់សំដែង ឲ្យយើងរាល់គ្នាឃើញសេចក្ដីទាំងនោះដោយសារព្រះវិញ្ញាណទ្រង់ ដ្បិតព្រះវិញ្ញាណនៃទ្រង់ស្ទង់មើលគ្រប់ទាំងអស់ព្រមទាំងសេចក្ដីជ្រាលជ្រៅនៃព្រះដែរ" (១កូរិនថូស ២:១០)។ ដូច្នេះ "សូមឲ្យព្រះបានរាប់ជាពិតហើយគ្រប់ទាំងមនុស្សកុតភរវិញចុះ" (រ៉ូម ៣:៤)។*

ខ្ញុំសូមអធិស្ឋានឲ្យព្រះ ប្រទានពរដល់អ្នក ក្នុងការសិក្សាព្រះបន្ទូលរបស់ទ្រង់។

វីធីត ល.ស.ហ្កាន់

អ្នកនិពន្ធ

ទំនាយ ដែលបានបើកសំដែង

អត្ថបទនេះ ត្រូវបានសរសេរឡើងនៅក្នុងឆ្នាំ ១៩៨៤ ដើម្បីបង្ហាញឲ្យឃើញពីជំនឿខុស ឆ្គងនៃគោលលទ្ធិព្រះត្រៃឯកមានតែឈ្មោះ។ ចាប់តាំងពីនោះមក សេចក្តីពិតនៃបទគម្ពីរសំខាន់ជាក់លាក់ជាច្រើន អំពីប្រធានបទនេះ បានបើកឲ្យឃើញ។ ទោះបីយ៉ាងណាក៏ដោយ ការបើកសំដេរងនៃភាព១អង្គនៃព្រះដ៏ជាកំពូល នៅតែពិតដដែល ។

ចំពេលដែលព្រះដឹកនាំកូនក្រមុំរបស់ ទ្រង់ទៅរកភាពគ្រប់លក្ខណ៍ គ្រប់ពួកបរិសុទ្ធទាំងអស់របស់ព្រះគ្រីស្ទ រំពឹងថា បានយល់ដឹងជ្រៅជ្រះថែមទៀតអំពីសេចក្តីពិតរបស់ព្រះ ។ ដូច្នេះ អ្នក-និពន្ធយល់ថា វាចាំបាច់ត្រូវកែអត្ថបទនេះឡើងវិញសំរាប់ជាប្រយោជន៍ដល់អ្នកជឿសេចក្តីពិត។

អត្ថបទនេះមានគោលបំណងបង្ហាញដល់អ្នកអាននូវការយល់ដឹងពិតទាំងមូលនៃព្រះដ៏ជាកំពូល-សេចក្តីអាថ៌កំបាំងនៃព្រះនៅក្នុងព្រះគ្រីស្ទ។ដោយផ្អែកទៅលើកំរិតនៃពេលវេលា ខ្ញុំមិនបានខ្នះខ្នែងនិយាយឲ្យបាន ក្បោះក្បាយគ្រប់បញ្ហា ដែលកើតមាន ប្រឆាំងនឹងព្រះត្រៃឯកទេ ។

---

*"តែនឹងមានពេលវេលាមក ក៏នៅតែឥឡូវនេះហើយ នោះពួកអ្នកដែលថ្វាយបង្គំ ដោយពិតត្រង់គេនឹងថ្វាយបង្គំព្រះវរបិតា ដោយវិញ្ញាណ និងសេចក្តីពិត ពីព្រោះ ប្រះវរបិតា ទ្រង់រកពួកអ្នកយ៉ាងនោះ ឲ្យបានថ្វាយបង្គំទ្រង់។ ឯព្រះ ទ្រង់ជា វិញ្ញាណ ហើយអ្នកណាដែលថ្វាយបង្គំទ្រង់ នោះត្រូវតែថ្វាយបង្គំដោយវិញ្ញាណនិងសេចក្តីពិតដែរ"។*

-យ៉ូហាន ៤:២៣-២៤

## ឡូហ្គុស

# ការចាប់ផ្តើមដំបូង
# នៃ
# ការបង្កើតរបស់ព្រះ

### ការបង្កើត

*"កាលដើមដំបូងឡើយព្រះបានបង្កើតផ្ទៃមេឃនិងផែនដី"(លោកុប្បត្តិ១: ១)*

វាជារឿង ដែលគេទទួលស្គាល់ទូទៅ និងល្បីល្បាញច១ ដែលថា ស្ថានសួគ៌(មេឃ) និងផែនដី ត្រូវបានបង្កើតឡើង ក្នុងរយះពេល៦ថ្ងៃ។ ប៉ុន្តែផែនដីដែលយើង កំពុងរស់នៅឥឡូវនេះ គឺជាការបង្កើតឡើងវិញ បន្ទាប់ពីព្រះបាន

ឡូហ្កុស: ការចាប់ផ្ដើមដំបូងនៃការបង្កើតរបស់ព្រះ

បង្កើតវាមកជាលើកទី១ បានរយះពេលជាច្រើនលាន ឆ្នាំ ម្ល៉េះ។ មុននឹងបង្កើតជាថ្មី ផែនដី បាននៅក្នុងស្ថានភាពខូច ទទេ នឹងងងឹត។

ហេតុអ្វីបានជាវាទៅជាអញ្ចឹង? ហើយតើវាបណ្ដាលមកពីអ្វី?

**យុគសម័យបុរេប្រវត្តិ**

សូមឲ្យយើងពិនិត្យមើល ការកត់ត្រានៅក្នុងគម្ពីរពីលំដាប់នៃព្រឹត្តការណ៍ ដែលទាក់ទងនឹងស្ថានសួគ៌និងផែនដី ដែលព្រះបានបង្កើតមក។ នៅលោកុប្បត្តិ ១:១ យើងជឿថា ព្រះបានបង្កើតស្ថានសួគ៌និងផែនដី នៅក្នុងកំឡុងពេល១ ហៅថា **កាលដើមដំបូង** ដែលមានរយះពេលរាប់លានឆ្នាំ ក្នុងអតីតកាល ។ នេះគឺជា ***ការចាប់ផ្ដើមដំបូងនៃការបង្កើតស្ថានសួគ៌ និងផែនដី។*** ហោរាអេសាយបាននិយាយថា ព្រះ *"បានសូនធ្វើ ហើយប្រតិស្ថានផែនដី ក៏តាំងឡើង មិនមែនបង្កើតមកឲ្យនៅទទេទេ គឺ បានជួបសូនបង្កើតឲ្យជាទីអាស្រ័យនៅ"* ( អេសាយ ៤៥:១៨)។ ហើយរបកគំហើញខាងបុរាណវិទ្យា បានបញ្ជាក់ប្រាប់យើងថា មានយុគសម័យ១ ដែលដាយណូស័រ និងពួកសត្វដូចមនុស្សត្រាច់ចរនៅលើផែនដី។ វាគឺយុគសម័យ ដែលមានរយះពេលរាប់លានឆ្នាំ មុននឹង *" ផែនដីបានខូច ហើយនៅទទេរ និងមានសុទ្ធតែងងឹតនៅគ្របលើជំរៅទឹក"* ( លោកុ. ១:២ក)។ ជាសាមញ្ញ យើងបានស្គាល់ថាជា **យុគសម័យបុរេប្រវត្តិ។**

## ពួកទេវតា

ផែនដី ដែលបានបង្កើតមកមានស្ថានភាព និងលក្ខណះល្អ ជាទីកន្លែងរស់នៅ សំរាប់ពពួកសត្វទាំងអស់ រស់នៅមានទំនាក់ទំនងជាមួយគ្នានៅក្នុងកំឡុងពេលយុគសម័យបុរេប្រវត្តិនោះ។

ឥឡូវនេះ ចូរយើងចូលមក១ជំហានថែមទៀត ពីលើ ***ការចាប់ផ្ដើមនៃស្ថានសួគ៌និងផនដី*** ទៅ ***ការចាប់ផ្ដើមនៃពួកទេវតា***

ក្នុង យ៉ូប ៣៨៤-៧ ព្រះបានបង្ហាញពីភាពល្ងង់ខ្លៅរបស់យ៉ូប នៅពេលដែលទ្រង់បានសួរគាត់ថា:

*"តើឯងឯណាក្នុងកាលដែលអញចាប់តាំងបង្កផែនដីឡើង ?......ក្នុងកាលដែលផ្កាយព្រឹកបានច្រៀងជាមួយគ្នា ហើយអស់ទាំងកូនព្រះបានស្រែកអរសាទរ?"*

បាទ ពួកផ្កាយរបស់ព្រះ (អ្នកនាំព្រះរាជសារទេវតា) បាននៅទីនោះជាមួយនឹងព្រះ ពេលដែល**ទ្រង់បានដាក់គ្រឹះនៃផែនដី។** គ្រប់កូនព្រះជាពួជ-ព្រះបន្ទូល បាននៅទីនោះ នៅក្នុងគំនិតដ៏គ្មានព្រំដែននៃព្រះ កំពុងតែស្រែកដោយអំណរ ។ [ចំណាំ: ជាញឹកញយ ព្រះបានមានបន្ទូលពីរបស់ ដែលមិនមាន ចាត់ទុកថា បានមាន ( រួចទៅហើយ )រ៉ូម ៤:១៧ ] ។

គ្រប់របស់ ដែលបានបង្កើតមក នៅក្នុងរូបអង្គ នឹងមានភាពដូចជាព្រះ បានទទួលអំណាចក្នុងការជ្រើសរើសខាងត្រូវ នឹងខុសបាន។ គ្មានរបស់ណា ១ ដែលព្រះបានបង្កើត មានកម្មវិធី ជាមនុស្សយន្តទេ។ ពួកទេវតា ដែលមាន រូបអង្គ នឹងមានភាពដូចជាព្រះ ត្រូវតែប្រលង យោងទៅតាមជំរើសរបស់ពួក គេ។ ហើយកន្លែងដ៏ប្រសើរ សំរាប់ឲ្យគេប្រលង គឺ មានតែភពផែនដីទេ។ ឯ ស្ថានសួគ៌មិនបានឲ្យទៅបំរើគោលបំនងណា ១ទេ គឺជាកន្លែង ដែលព្រះ គង់នៅវិញ។

## ទេវតាធ្លាក់ចុះ

សាតាំងបានក្លាយជា**ទេវតាធ្លាក់ចុះ** រួចទៅហើយ នៅពេលវាបានចូលក្នុង **សួនច្បារអេដែន** ដែលបានបង្កើតសំរាប់អ័ដាម និងអេវ៉ា ជាក់ស្តែង វាបាន ប្រលងនៅចំនុចនៃពេលវេលា ក្នុងរយះពេលច្រើនឆ្នាំ កាលពីអតីតកាល ហើយដោយបានប្រលងធ្លាក់ វាក៏ត្រូវបោះទម្លាក់មកដី ដូចបានចែងនៅក្នុង អេសាយ ១៤:១២-១៤ និងអេសេគាល ២៨:១១-១៧។

នៅក្នុង យ៉ូហាន ៨:៤៤ ព្រះយេស៊ូបានមានបន្ទូល ( ទៅពួកយូដា ដែល មិនជឿ ) ថា: "*អ្នករាល់គ្នាមានអារក្សសាតាំងជាឪពុក ហើយអ្នករាល់គ្នាចូល ចិត្តធ្វើតាមតណ្ហា ដែលគាប់ចិត្តដល់ឪពុករបស់អ្នក វាជាអ្នកសំលាប់គេតាំង ពីដើមមក វាមិនបាននៅពោលពាក្យភូតភរ នោះដុះចេញពីចិត្តវាមក ដ្បិតវា ជាអ្នកកំភូត ហើយជាឪពុកនៃសេចក្តីនោះឯង*"

និយាយបែបនេះ ព្រះយេស៊ូមិនបានសំដៅទៅលើការ សំលាប់អេបិល ដោយកាអ៊ីន ដែលជាពូជពស់ ( សត្វដូចមនុស្ស ) ឬក៏ការកុហក ដែលពស់ បានប្រាប់អេវ៉ាទេ ។ ព្រះគ្រីស្ទបានចង្អុលទៅឯកាលដើមដំបូង និងការប្រលង របស់សាតាំង ពេលដែល**វាមានច្បារអេដែនផ្ទាល់ខ្លួន** នៅលើផែនដីដែលនេះ

នៅក្នុងអេសេគាល ២៨ នៅពេលហោរាអេសេគាល កំពុងតែថ្លែងទំនាយ គាត់មិនគ្រាន់តែបន្ទោសស្តេចទីរ៉ុស ជាមនុស្សនៃសិរីល្អ ដែលចូលចិត្តទទួល សិរីល្អ នឹងដំកើងខ្លួនប៉ុណ្ណោះទេប៉ុន្តែក៏បន្ទោសសាតាំងផងដែរ នៅពេលគាត់ និយាយថា "*ពីដើមឯងបានច្បារអេដែនជាសួនរបស់ព្រះ*" ( ខ ១៣ )។ **ប៉ុន្តែ សូមចំណាំដោយប្រុងប្រយ័ត្នថា ច្បារអេដែននេះដែលបានបង្កើតឡើងសំរាប់មេ ទេវតានោះ មុននឹងវាធ្លាក់ចុះ គឺជាសួនច្បារនៃត្បូងដ៏មានតម្លៃ ហើយមិនមែនជា សួនច្បារដាំបន្លែផ្លែឈើទេ។** សួនច្បាររបស់អ័ដាម គឺជាសួនដាំផ្លែឈើ និងរុក្ខ ជាតិផ្សេងៗ។ ពាក្យ "*អេដែន*" មានន័យជាសាញ្ញថា "*សេចក្តីរីករាយខ្លាំង*" ឬ "*ស្ថានបរមសុខ*"។ គ្រប់អ្វីៗទាំងអស់នៅក្នុងសួនច្បារនៃត្បូងដ៏មានតម្លៃនោះ ត្រូវបានបង្កើតឡើង សំរាប់ចេរូប៊ីន ដែលមានប្រេងតាំង គ្រប់ត្បូងដ៏មានតម្លៃ ជាប្រដាប់គ្របបាំងរបស់វា - ជាសិរីល្អរបស់វា។ វាត្រូវបានតាំងឡើងឲ្យមាន

ឡូហ្គុស: ការចាប់ផ្ដើមដំបូងនៃការបង្កើតរបស់ព្រះ

ដំណែងអាជ្ញាធរ-*"ឲ្យឯងបាននៅលើភ្នំបរិសុទ្ធរបស់អញ"* (ខ១៤) វាបានគ្រប់លក្ខណ៍ នៅក្នុងផ្លូវរបស់វា ដរាបដល់វេលា ដែលឃើញមានសេចក្ដីទុច្ចរឹតនៅក្នុងវា (ខ ១៥)។ វាបានប្រលងធ្លាក់ ហើយធ្លាក់ចុះមក។ បន្ទាប់មក លូស៊ីហ្វ័រ (តារាប្រចាំថ្ងៃ) - *កូនផ្កាយព្រឹក* - បានក្លាយទៅជាសាតាំង ជាខ្មាំងសត្រូវរបស់ព្រះ ។

នៅពេលដែលសិ ស្ស៧០នាក់ បានត្រឡប់មកឯព្រះយេស៊ូគ្រីស្ទវិញ បន្ទាប់ពីបេសកម្មដ៏ជោគជ័ យរបស់ពួកគេ ពួកគេបានពេញដោយសចក្ដីសោមនស្សដ៏អស្ចារ្យ បានជាព្រះអម្ចាស់ បានដាស់តឿនពួកគេ ដោយមានបន្ទូលថា *"ខ្ញុំបានឃើញអារក្សសាតាំងធ្លាក់ ពីមេឃមកដូចជាផ្លេកបន្ទោរ"* ( លូកា ១០:១៧-១៨ )។ **បាទ សាតាំងបានដំកើងខ្លួនវា ហើយវាបានធ្លាក់ចុះ** មកពីលក្ខណៈដំបូងរបស់វា ហើយ *"បានផ្ដេកអស់ទាំងនគរឲ្យរាប វាបានត្រូវកាប់រំលំដល់ដីដែរហ្ន"* ( អេសាយ ១៤:១២ )

ជាក់ស្ដែង លូស៊ីហ្វ័រ ដែលពីមុន ធ្លាប់មានអំណាច និងគ្រប់គ្រងលើភពផែនដីបានកំពុងតែ ប្រយុទ្ធយ៉ាងខ្លាំងក្លា ដើម្បីបានផែនដីពីមនុស្សជាអ្នកគ្រប់គ្រងថ្មីដែលបានតាំងឡើងឲ្យគ្រប់គ្រងជំនួសវា តាំងពីការបង្កើតឡើងជាថ្មីមកវិញ ។ វាបានខំប្រឹង ប្រើគ្រប់កម្មវិធី និងមធ្យោបាយ ដើម្បីសំរេចមហិច្ឆិតារបស់វា ។ សេចក្ដីភូតភរ និងផែនការណ៍ដ៏អាក្រក់របស់វា បានបំពេញផែនដីដោយគ្រប់ទំរង់នៃអំពើហឹង្សា និងអំពើបាប។ អូ អារក្សនោះ! វាចេញទៅទាំងស្រុងដើម្បីនឹងបំផ្លាញគ្រប់អ្វីៗ ដែលព្រះបានបង្កើតមក!បាទ វាជាព្រះនៃយុគសម័យដ៏អាក្រក់នេះ!

បាទ លូស៊ីហ្វ័រ បានគ្រប់លក្ខណ៍ នៅពេលវាបានបង្កើតមក ។ ប៉ុន្តែវាមិនបានពេញចិត្តនឹងអ្វីដែលជាកម្មសិទ្ធិ នឹងតំណែងរបស់វាទេ។ វាហាក់ដូចជាធុញទ្រាន់នឹងតំណែងរបស់វា ហើយចាប់ផ្ដើមគិតគូរមហិច្ឆិតាសំងាត់របស់វាដើម្បីឲ្យបានដូចជាព្រះដ៏ខ្ពស់បំផុត (អេសាយ១៤:១២)ព្រះបានជ្រាបដឹងរឿងនោះ ហើយទ្រង់ក៏ចាប់ផ្ដើមចាត់ការវាចេញ។ នោះជាពេលដែលឃើញមានសេចក្ដីទុច្ចរិតនៅក្នុងវា ហើយវាក៏ចាប់ផ្ដើមបណ្ដាលឲ្យមានសង្គ្រាម នៅក្នុងចំណោមពពួកសត្វមានមាឌធំៗនៃផែនដី។ **សំលាប់! ធ្វើឃាត! បំផ្លាញ!** ដូច្នេះហើយ បានជាលូស៊ីហ្វ័រក្លាយទៅជាឃាតករ!

នៅពេលដែលព្រះបានប្រឈមព្រះភក្ត្រនឹងវា ទ្រង់បានមានបន្ទូលពីការកុហកដំបូងរបស់វា វាមិនបានជាប់នៅក្នុងចិត្តសេចក្ដីពិត។ ត្រូវហើយ។ *"វាជាឃាតករតាំងតែពីដើម ហើយមិនបានជាប់នៅក្នុងសេចក្ដីពិតទេ ព្រោះគ្មានសេចក្ដីពិតណានៅក្នុងវា"*។

ផែនដីបាននៅក្នុងស្ថានភាពជ្រួលច្របល់ និងរីករវ។ គ្រប់ទាំងសត្វបានច្បាំងគ្នា ហើយ បានសំលាប់គ្នាដែលបង្ខូច បំផ្លាញបរិស្ថាននៅជុំវិញពួកវា។ ការបំផ្លាញខ្ទេចខ្ទី រួមទាំងសាកសពពុករលួយ បានបណ្តាលឲ្យមានការប្រែប្រួលទៅលើលក្ខខណ្ឌអាកាសធាតុនៃផែនដី ហើយដីគោកបានក្រាលដោយកាកសំណល់។ ទីបំផុត ព្រះបានសំរេចថានឹងបញ្ឈប់ការបំភ្លេចបំផ្លាញដ៏ធំនេះ។ គ្រប់អ្វី ដែលទ្រង់បានធ្វើ គឺ ត្រូវដកចេញពីសិទ្ធិអំណាច និងការគ្រប់គ្រងនៅលើផែនដី ។

អស់ទាំងទេវតា ដែលបានដើរតាមការដឹកនាំ ដ៏អាក្រក់របស់សាតាំង ក៏បានធ្លាក់ចុះជាមួយវាដែរ។ ពួកវាបានចេញពី លក្ខណៈរបស់ពួកវាដោយការជ្រើសរើស។ ពួកទេវតា ដែលបញ្ជាក់ថានៅស្មោះត្រង់ចំពោះព្រះ ក៏នៅខាងព្រះហស្តស្តាំនៃព្រះដដែល ដើម្បីអនុវត្តនិងប្រតិបត្តិផែនការណ៍របស់ទ្រង់។

ពួកទេវវិទូ ដែលមានការអប់រំល្បីល្បាញ មិនអាចយល់សេចក្តីដ៏ជ្រៅដែលបានលាក់ទុកក្នុងព្រះបន្ទូលនៃព្រះទេ។ ព្រះនឹងសំដែងសេចក្តីពិតនេះឲ្យតែពួកកូនង៉ែតយល់វិញ។ បាទ ព្រះបន្ទូលនៃព្រះអម្ចាស់ បានប្រទានមកយើង ច្បាប់មួយម្តងៗ ឃ្លាមួយម្តងៗ មុខនេះបន្តិច ហើយមុខនោះបន្តិច ដើម្បីឲ្យយើងអាចទទួលសេចក្តីពិត។

សូម្បីតែសព្វថ្ងៃនេះ ក៏មានមនុស្ស (ជាពិសេស ពួកអ្នកដែលជឿថា ផែនដីមានអាយុប្រហែល ៦០០០ ឆ្នាំប៉ុណ្ណោះ) ដែលបានបង្រៀនថា ដាយណូស័របានមាននៅសម័យអ័ដាម និងថា ពួកវាទាំងអស់បានស្លាប់ក្នុងទឹកជំនន់លិចផែនដី នៅសម័យណូអេហើយ។ ចំជាឆ្កួតមែន! បើសិនជាដាយណូស័របានមានតែក្នុងសម័យណូអេ ហេតុអ្វីបានជាពួកវាមិនបាននៅក្នុងទូក នៅពេលដែលព្រះបានបញ្ជាក់យ៉ាងជាក់លាក់ ឲ្យណូអេយកគ្រប់សត្វ *"គ្រប់ប្រភេទ១គូៗ"* ទៅជាមួយគាត់ មុននឹងទ្រង់បំផ្លាញពិភពលោកដោយទឹកជំនន់? ហើយបើសិនជាពួកវាត្រូវបាននាំចូលទូកហើយ ហេតុអ្វីបានជាពួកវាមិនបាននៅទីនេះជាមួយយើងសព្វថ្ងៃនេះ? (គ្រូអធិប្បាយខ្លះគិតថា ដោយសារមាឌរបស់ពួកវា ដាយណូស័រ រស់បានតែក្នុងរយៈពេលខ្លីប៉ុណ្ណោះ បន្ទាប់ពីទឹកជំនន់ដោយសារតែខ្វះចំណី។) មុនដំបូង តើដាយណូស័រ និងសត្វស្លាបដ៏ធំសម្បើម *"គ្រប់ប្រភេទ១គូៗ"* ( សូម្បីតែពួកវាទើបតែជំពេញវ័យ ) អាចដាក់នៅក្នុងទូកនោះឬទេ? សូមគិតពីការនេះ។ ទឹកជំនន់នៅជំនាន់លោកណូអេ (ប្រហែល ៤៤០០ ឆ្នាំ មុន) មិនមែនជាហេតុធ្វើឲ្យសត្វដាយណូស័រស្លាប់នោះទេ ។

ខាងបុរាណវិទ្យាបានបញ្ជាក់ថា ពួកវាបានមានរាប់លានឆ្នាំមុន ហើយមិនមែនគ្រាន់តែមាន ៦០០០ ឆ្នាំ ក្នុងយុគសម័យអ័ដាមទេ។ បើសិនជាទឹកជំនន់ជាហេតុធ្វើឲ្យដាយណូស័រ និងពួកសត្វលើដីគោកផុតពូជនោះ អញ្ចឹង

ឡូហ្គុស: ការចាប់ផ្ដើមដំបូងនៃការបង្កើតរបស់ព្រះ

ហេតុអ្វីបានជា Trilobites និងពួក arthropods ផ្សេងៗទៀត ជាពួកសត្វរស់នៅក្នុងសមុទ្រ មិនអាចរួចពីទឹកជំនន់បាន? ដូចម្ដេច និងហេតុអ្វី បានជាពួកវាផុតពូជ នៅក្នុងទឹកជំនន់លិចផែនដី? ចំលើយគឺថា ពួកវាមិនបានមាននៅយុគសម័យរបស់ អ័ដាមទេ ប៉ុន្តែមាននៅយុគសម័យរាប់លានឆ្នាំពីមុននោះទៅទៀត។ ពួកវាបានស្លាប់ទៅ នៅពេលដែលព្រះបានបង្អកផែនដី បន្ទាប់ពីទ្រង់បានកាត់ទោសសាតាំងនិងពួកទេវតាធ្លាក់ចុះនោះ។

ពេលវេលាកំនត់ មិនបានកត់ត្រានៅក្នុង លោកុប្បត្តិ ១:១ ចំពោះការបង្កើតស្ថានសួគ៌ និងផែនដីរបស់ព្រះ ។ ព្រឹត្តិការណ៍ ដែលបានកើតឡើង មិនបានកត់ត្រា នៅក្នុងខមួយនោះទេ។ (ជាក់ស្តែង ដើម្បីលាក់សេចក្តីពិតពីពួកអ្នកប្រាជ្ញ និងពួកឈ្លាសវៃ ។) ជាសាមញ្ញ ដំណឹងនេះអាចមានរយៈពេលរាប់លានឆ្នាំ។

បាទ លូស៊ីហ្វ័រ មានអេដែនរបស់វា ។ អ័ដាមក៏មានអេដែនរបស់គាត់ ។ ហើយក្នុងពេលកែជំនាន់មនុស្សជាថ្មី នៅពេលព្រះអម្ចាស់យេស៊ូគ្រីស្ទនិងគង់លើបល្ល័ង្កនៃសិរីល្អរបស់ទ្រង់ ដើម្បីសោយរាជ្យជាមួយកូនក្រមុំរបស់ទ្រង់ ទ្រង់នឹងមានអេដែនរបស់ទ្រង់ដែរ (ម៉ាថាយ ១៩:២៨ អេសាយ ៦:៥១៨-២៥ )។

## ការបង្កើតឡើងជាថ្មី

ការធ្លាក់ចុះរបស់សាតាំងបានបណ្តោយឲ្យផែនដីមានស្ថានភាពងងឹត ដូចបានចែងនៅក្នុងលោកុ ១:២៥។ គ្មានពន្លឺទេ។ វានៅទទេហើយក្រាលដោយកាកសំណល់។ *"ហើយព្រះវិញ្ញាណនៃព្រះក៏អោរនៅលើទឹក"* ហើយព្រះបានចាប់ផ្តើម បង្កើតផែនដីឡើងវិញ( ក្នុងរយៈពេល៦ថ្ងៃ )ដើម្បី ជាទីស្នាក់អាស្រ័យម្តងទៀត។ ពេលនេះពួកសត្វ ត្រូវបានបង្កើតឡើងតូចជាងមុនវិញ ។

*"ទ្រង់ក៏មានបន្ទូលថា ចូរយើងធ្វើមនុស្សឲ្យដូចជារូបយើង*
*ឲ្យមានភាពដូចយើង..." លោកុ.១:២៦*

ហើយមនុស្សបានទទួលអំណាចឲ្យគ្រប់គ្រងរបស់មានជីវិតទាំងអស់ដែលមានចលនានៅលើផែនដី។ នេះគឺជាការចាប់ផ្តើមនៃមនុស្ស ដែលត្រូវបានបង្កើតឲ្យទាបជាងទេវតាបន្តិច ប៉ុន្តែបានទទួលម្កុដនៃសិរីល្អ នឹងកិត្តិយស នឹងដាក់ឲ្យកាន់កាប់កិច្ចការនៃព្រះហស្តព្រះ។

# ព្រះដ៏ជាកំពូល

នៅក្នុងលោកុប្បត្តិ ១:២៦ ប្រះមិនបានមានបន្ទូល ឬពិគ្រោះជាមួយព្រះ ២អង្គទៀត ដែលមានព្រះនាម ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធនោះទេ ដែលពួកទេវវិទូជឿព្រះត្រៃឯកចង់ឲ្យយើងជឿ ដោយសារតែពាក្យ *"យើង"*។ ផ្ទុយទៅវិញ ខ ខាងក្រោមទៀតចែងថា *"ព្រះបានបង្កើតមនុស្សឲ្យដូចរូបអង្គទ្រង់..."* ការប្រើប្រាស់បុរិសសព្វនាមឯកវចនះ បានគូសបញ្ជាក់ថា ការបង្កើត

គឺជាកិច្ចការរបស់**ព្រះ១អង្គ**។ (សូមមើលយ៉ូហាន១:៣.១០ផងដែរ)។ អញ្ជឹង តើព្រះកំពុងមានបន្ទូលទៅនរណា? គ្មាននរណាទៀតទេ ក្រៅពីពពួកទេវតា ដែលបានល្បួង និងសាហើយ (មើលអេសាយ ៦១-៨)។ ដោយសេចក្តីគោរព ព្រះដ៏អស្ចារ្យបានសំដែងបំនងរបស់ទ្រង់ដល់ពួកគេ។ ទោះបីជាពួកទេវតាមិន បានបង្កើតនិងមិនបានផ្សាយដំណឹងល្អក៏ដោយក៏ពួកគេចាប់អារម្មណ៍នឹងកិច្ច ការរបស់ព្រះដែរ។ ពួកគេជាអ្នកបំរើរបស់ព្រះ ហើយជួនកាលសំដៅទៅលើ "*ពួកមនុស្ស*"(លោកុ.១៨:២២. ១៩:១. កិច្ច. ១:១០)។ គ្មាននរណាម្នាក់បាន បង្រៀន ឬដឹកនាំព្រះឡើយ ប៉ុន្តែព្រះពិគ្រោះជាមួយពួកទេវតា និងមនុស្ស ។ (មើល១ពេត្រុស១:១២, កិច្ច, ១០:១-៨, លោកុ.១៨:១៧-៣៣, ១៩:១, ទំនុក ១០៣:២០ )។

គ្មានរឿងបែបដូចជា ***ព្រះត្រៃឯកនៃព្រះ*** ទេ គ្មានរឿងបែបដូចជា ***បុគ្គលបីអង្គ ឬ តួអង្គ៣នៅក្នុងព្រះមួយអង្គ*** ដែរ។ គម្ពីរមិនមែនជាបង្រៀនពី***សហព្រះ១អង្គនៃព្រះ៣អង្គដែរ ឬ ព្រះដ៏ជាកំពូល "ព្រះ៣អង្គ"*** ដែរ។ ពួកជឿព្រះត្រៃឯក បង្រៀនថា និងហៅវាថា ***សេចក្តីអាថ៌កំបាំង***ពិតមែនហើយ បើពួកគេបង្កើត ទ្រឹស្តីអំពីព្រះតាមបញ្ញា របស់ពួកគេផ្ទាល់ វានឹងនៅតែជាសេចក្តីអាថ៌កំបាំង ដល់ពួកគេជានិច្ច។ ដំបូង សេចក្តីអាថ៌កំបាំងនេះ (ដូចជាពួកគេបានហៅវា នោះ )គឺជាទ្រឹស្តីដ៏អាថ៌កំបាំង បង្កើតដោយគំនិតដែលមានកំនត់ ហើយជាប់ ពាក់ពន្ធ័នឹងការកំនត់នៃព្រះដ៏ជាកំពូលដែរ! ហើយនេះគឺជាទ្រឹស្តីរបស់អ្នកជឿ ព្រះត្រៃឯកម្នាក់ (ខេត អេល ប្រ៊ូក្ស Keith L.Brooks)

"*បើសិនជាគោលលទ្ធិនៃព្រះត្រៃឯក មិនអាចទទួលយកបាន នោះព្រះគ្រីស្ទមិនមែនមានភាពជាព្រះទេ ហើយលក្ខណៈនៃ កិច្ចការប្រោសលោះរបស់ទ្រង់ ត្រូវបានដកចេញទទេ។ បើសិនជាព្រះមានព្រះត្រៃឯក....ហើយការថ្វាយបង្គំមិនរួមព្រះយេស៊ូ និងព្រះវិញ្ញាណបរិសុទ្ធទេ នោះការថ្វាយបង្គំដ៏ត្រឹមត្រូវ ត្រូវបានដកយកចេញពីព្រះដ៏ជាកំពូល ២ភាគ៣ហើយ*"

ព្រះដ៏ជាកំពូល "*ព្រះអង្គរួម១*" គឺជាថ្មជំពប់ធំបំផុតចំពោះពួកយូដា អ៊ីស្លាម និងពួកអ្នក-ស្វែងរកសេចក្តីពិតជាច្រើននាក់ទៀត។ ប៉ុន្តែ គ្រីស្ទានជាច្រើន ដែល ទទួលការបង្រៀនឲ្យជឿលើ "សេចក្តីអាថ៌កំបាំង" មានតែឈ្មោះនេះ បានការពារដោយអំនួត ប៉ុន្តែដោយចំកួត ដោយប្រកាសថាៈ "*ព្រះត្រៃឯក គែជាមេរៀនគ្រឹះនៃសាសនាគ្រីស្ទ ហើយអ្នកណាដែលបដិសេធ គេអាចនឹងបាត់ព្រលឹងរបស់ខ្លួន ដូច្នេះ នរណា ដែលសង្វាតយល់ការនេះ គេអាចបាត់បង់ការយល់!*"

ការបង្រៀនពីព្រះត្រៃឯកគឺជាការប្រឆាំងផ្ទាល់ ចំពោះបទគម្ពីរសាមញ្ញនៃ កូល៉ុស ១:១៩ និង ២:៩ដែលចែងថា ***ដ្បិតមានគ្រប់ទាំងសេចក្តីពោរពេញនៃ***

ឡូហ្គុស: ការចាប់ផ្តើមដំបូងនៃការបង្កើតរបស់ព្រះ

***ព្រះ (ដ៏ជាកំពូល) សណ្ឋិតនៅក្នុងព្រះត្រីស្មូទាំងមានរូបអង្គផង។ ទ្រង់គឺជាគ្រប់ទាំងអស់ដែលព្រះមាន។*** គ្មានរឿងបែបនេះជាសេចក្តីបង្រៀនតាមគម្ពីរ ដែលថាទ្រង់ គឺព្រះដ៏ជាកំពូល ១ភាគ៣ទេ។ អ្នកខ្លះក៏ជឿថា មានបល្ល័ង្ក៣ដោយឡែកនៅស្ថានសួគ៌ ដែលព្រះរាជបុត្រានឹងគង់ (ឬកំពុងតែគង់ហើយ) នៅខាងព្រះហស្តស្តាំនៃព្រះ។ មនុស្សបែបនេះបានកំណត់ព្រះវិញ្ញាណនៃព្រះ ទៅជាទំរង់នៃរូបកាយរបស់មនុស្សវិញ។

អ្នកបរិសុទ្ធ យ៉ូហានបានធ្វើបន្ទាល់ថា *"គ្មាននរណា ដែលឃើញព្រះឡើយ មានតែព្រះរាជបុត្រាតែ១ ដែលគង់នៅក្នុងព្រះឱរាព្រះវបិតាប៉ុណ្ណោះ ទ្រង់បានសំដែងឲ្យស្គាល់ព្រះអង្គ"* (យ៉ូហាន ១:១៨) ត្រឹមត្រូវហើយ។ គ្មានមនុស្សណាធ្លាប់បានឃើញព្រះឡើយ ហើយក៏គ្មាននរណាម្នាក់នឹងឃើញទ្រង់ដែរ-*"ក៏មានតែទ្រង់ប៉ុណ្ណោះ ដែលមិនចេះសុគត ទ្រង់គង់នៅក្នុងពន្លឺ ដែលរកចូលទៅជិតមិនបាន គ្មានមនុស្សណា ដែលឃើញទ្រង់ឡើយ ក៏មើលទ្រង់មិនឃើញផង សូមឲ្យទ្រង់បានល្បីព្រះនាម និងព្រះចេស្តានៅអស់កលល្បិចជានិច្ច អាម៉ែន*(១ធីម៉ូថេ ៦:១៦)។ ព្រះអង្គជាវិញ្ញាណ។ ទ្រង់គង់ក្នុងពន្លឺ ដែលរកចូលទៅជិតមិនបាន ហើយទ្រង់ពីសកន្លែងលាក់អង្គទ្រង់ផ្ទាល់ទ្រង់នៅតែគង់នៅមិនអាចឲ្យឃើញ (អេសាយ ៤៥:១៥, កូល៉ុស ១:១៥)។ អ្នកខ្លះគិតថា លោក ស្ទេផាន បានឃើញព្រះជាម្ចាស់ នៅពេលដែលគេបានចោលដុំថ្ម និងសំលាប់គាត់ ពីព្រោះគាត់ប្រកាសថា គាត់បានឃើញព្រះយេស៊ូឈរនៅខាងព្រះហស្តនៃព្រះ ( កិច្ចការ ៧:៥៥-៥៦ )។ ពាក្យថា *"ព្រះហស្តស្តាំនៃព្រះ សំដែងពីសិរីល្អ និងព្រះចេស្តារបស់ព្រះ។* វាក៏ជាសញ្ញា *សេចក្តីមេត្តាករុណា ព្រះគុណ និងសិទ្ធិអំណាច ដែរវឹង" ព្រះហស្តឆ្វេង* "ជាសញ្ញា ការ*ជំនុំជំរះរបស់ព្រះ"*។ (សូមអាននិកូមនំ ១៥៦ និងម៉ាថាយ ២៥: ៣១-៤៦ ដើម្បីឲ្យយើងបានយល់ថែមទៀត)។ ពេលដែលក្រុមនិយមខាងព្រះច្រើន ជឿថា ស្ទេផានបានឃើញព្រះនោះ នោះពួកគេបាននិយាយផ្ទុយនឹងបទគម្ពីរ ដែលពួកគេបានអះអាងថាជឿហើយ - គឺក្នុងយ៉ូហាន ១:១៨, ១ធីម៉ូថេ ៦ :១៦ កូល៉ុស ១:១៥ ។ល។

នៅក្នុងគម្ពីរ នៅពេលដែលគេឃើញរូប ព្រះយេស៊ូកំពុងតែឈរនោះ គឺទ្រង់កំពុងមានងារឬតួនាទីជាសង្ឃដ៏ខ្ពស់បំផុត ក្នុងការងារទូលអង្វររបស់ទ្រង់។ នេះហើយជាតួនាទីរបស់ទ្រង់ នៅពេលឥឡូវនេះ (រ៉ូម ៨:៣៤ខ)។ ទោះបីយ៉ាងណាក៏ដោយ ទ្រង់នឹងមិនមានតំណែងជាសង្ឃដ៏ខ្ពស់បំផុតរហូតទេ។ នៅថ្ងៃ១ ទ្រង់នឹងជាចៅក្រម នេងជាស្តេច ពេលដែលទ្រង់នឹងគង់លើបល្ល័ង្កនៃសិរីល្អរបស់ទ្រង់ ដើម្បីជំនុំជំរះមនុស្សលោក ។

ដូច្នេះ ស្ទេផានបានឃើញក្នុងនិម្មិតរបស់គាត់ថា ព្រះយេស៊ូ ជាសង្ឃដ៏ខ្ពស់របស់ព្រះ ជាអ្នកកាន់កាប់ព្រះចេស្តា និង អំណាចទាំងអស់របស់ព្រះ

(វិវ. ១:១៣. ម៉ាថាយ ២៨:១៨ )។ ទ្រង់គឺជាសេចក្តីមេត្តាករុណា និងព្រះគុណនៃព្រះ។

**ទស្សនះរបស់អ្នកជឿព្រះត្រៃឯក គឺជាគោលលទ្ធិរបស់ពួកបាប៊ីឡូន។** វាបានបន្តមកជាគ្រឹះគោលលទ្ធិ ពេលក្រុមប្រឹក្សាណៃសិន (នីកូឡាស) ចាប់ផ្តើមឡើង នៅឆ្នាំ ៣២៥ គស ដោយសារក្រុមជំនុំរ៉ូម ដែលជា "*សេចក្តីអាថ៌កំបាំងនៃក្រុងបាប៊ីឡូនដ៏ធំ ជាម្តាយនៃស្រីសំផឹងនិងជាសេចក្តីស្អប់ខ្ពើមនៃផែនដី*"។ ពួកជំនុំរ៉ូម មិនគ្រាន់តែបំបែកព្រះចេញជា ៣ ប៉ុណ្ណោះទេប៉ុន្តែនាងបានធ្វើជាអ្នកទូលអង្វរដល់ពួកបរិសុទ្ធដែលស្លាប់ទៅ ដូចជាដូនតារ៉ូម៉ាំងដែរ។ គ្រីស្ទានដែលបោះបង់ សេចក្តីជំនឿក្នុងព្រះបន្ទូល គ្រាន់តែបានផ្តល់យោបល់លិ្វតល្វង់ អាក្រក់ ប៉ុន្តែ ពិតអញ្ចឹងគោលលទ្ធិ និងការបង្រៀនបានបន្តមកតាមពួកជំនុំភាគច្រើន នៅលើគំនិតសាច់ឈាម និង តាមយោបល់របស់គ្រូអធិប្បាយ ហើយមិនឲ្យគេជឿជាទូទៅ នៅលើព្រះបន្ទូលដើមរបស់ពួកសាវក និងពួកហោរាឡើយ។

ពេលដែលគំនិត ខាងទស្សនវិជ្ជា និងទេវវិទ្យា បានបង្កើតជារូបមន្តត្រសឯក បទគម្ពីរត្រូវបានមើលរំលង និងត្រូវបង្វែន័យទីតាមទំលាប់ និងតាមការស្រមើស្រម៉ៃរបស់ពួកគេវិញ។ អ្វី ដែល ខុស សោះ បែរជាគេទទួលយកថាត្រូវ វិញ ហើយគំនិតត្រឹមត្រូវ បែរជាថា មិនត្រឹមត្រូវវិញ។

**សូមពិចារណាការនេះ** ***អ្នកណាជាព្រះវរបិតារបស់ព្រះយេស៊ូ?*** តើម៉ាថាយជំពូក១ បានចែងថា ម៉ារី "*ដែលគេដឹងថា នាងមានកូនដោយសារព្រះវិញ្ញាណបរិសុទ្ធ*" (ការកើតឡើងដោយសារព្រះវិញ្ញាណបរិសុទ្ធ) ប៉ុន្តែព្រះយេស៊ូនៅតែអះអាងថា ព្រះ ជាព្រះវរបិតារបស់ទ្រង់អញ្ចឹង ព្រះ-ព្រះវរបិតា និងព្រះ-ព្រះវិញ្ញាណបរិសុទ្ធ (ជាពាក្យ ដែលប្រើជាញឹកញយ ដោយពួកគ្រីស្ទាន) គឺតែ១ទេ ហើយជាព្រះវិញ្ញាណដដែល ឬ អញ្ចឹង ព្រះយេស៊ូ មានព្រះវរបិតាដល់ទៅ ២អង្គ។ (ចំណាំៈ គ្មានពាក្យ ព្រហ-ព្រះវិញ្ញាណបរិសុទ្ធ ព្រះ-ព្រះឬាជបុត្រា នៅក្នុងបទគម្ពីរទេ)។ ពាក្យនេះ ត្រូវបានប្រើដោយពួកគ្រីស្ទ ដែលបោះបង់ជំនឿក្នុងព្រះបន្ទូលសំដៅទៅបុគ្គលិកលក្ខណះដាច់ដោយឡែកក្នុងព្រះដ៏ជាកំពូល)

នេះជាការយ៉ាងច្បាស់នៅក្នុង អេភេសូរ ៤:៤ និង យ៉ូហាន ៤:២៤ នៅក្នុង ខ នេះ មាន**តែព្រះវិញ្ញាណ** ១គត់ ។ ព្រះយេស៊ូក៏មានបន្ទូលថា ទ្រង់ និងព្រះវរបិតាទ្រង់ តែ១ ទេមិនមែន២អង្គទេ។ នោះហើយជា **ព្រះតែ**១ទេ!

"*មានព្រះតែ១គឺ ជាព្រះវរបិតានៃទាំងអស់ ដែលទ្រង់ខ្ពស់លើទាំងអស់គង់នៅកណ្តាលទាំងអស់ ហើយសណ្ឋិតនៅក្នុងទាំងអស់*" (អេភេសូរ ៤៥-៦)។ ហើយមានព្រះអម្ចាស់តែ១។

ឡូហ្គុស: ការចាប់ផ្ដើមដំបូងនៃការបង្កើតរបស់ព្រះ

"*គង់តែចាងយើង មានព្រះតែ១ ប៉ុណ្ណោះ គឺជាព្រះវរបិតា ដែលរបស់សព្វសារពើ កើតមកពីទ្រង់ ហើយយើងរាល់គ្នា ក៏សំរាប់ទ្រង់ ក៏មានព្រះអម្ចាស់តែ ១ គឺព្រះយេស៊ូគ្រីស្ទ ដែលរបស់សព្វសារពើកើតមកដោយសារទ្រង់ ហើយយើងដោយសារទ្រង់ដែរ*"។(១កូរិន. ៨:៦)

"*ចូរស្តាប់ចុះ ឱ អ៊ីស្រាអែលអើយ គឺព្រះអម្ចាស់ជាព្រះនៃយើងខ្ញុំ ទ្រង់ជាព្រះអម្ចាស់តែ១អង្គទ្រង់*"(ម៉ាកុស ១២:២៩. ចោទិ. ៦:៤)។

ព្រះបានបង្កើតគ្រប់របស់ទាំងអស់ តាមបំណងព្រះហឫទ័យ (ជំរើស) របស់ទ្រង់ផ្ទាល់ (វិវ ៤:១១)។ តាមគំនិតដែលទ្រង់បានគិតសំរេច ក្នុងព្រះអង្គទ្រង់ ( អេភេ. ១:៩) "*ដែលទ្រង់ធ្វើគ្រប់ការទាំងអស់ តាមដែលគាប់ព្រះហឫទ័យទ្រង់ទេ*។(អេភេ. ១:១១) មិនមែនតាមព្រះដំរិះ(ការប្រឹក្សា) ដែលគាប់ព្រះហឫទ័យ(ព្រះត្រៃឯក)របស់ពួកគេទេ។ វិវ. ១: ៨ អាន "ព្រះអម្ចាស់ដ៏ជាព្រះ ដែលទ្រង់គង់នៅ ក៏គង់នៅតាំងពីដើម ហើយត្រូវយាងមកទៀត គឺជាព្រះដ៏មានព្រះចេស្តាបំផុត "***ហើយមិនមែនយើង ដែលគង់នៅ ក៏គង់នៅតាំងតែពីដើម ជាពួកព្រះដ៏មានព្រះចេស្តាបំផុត***" ហើយដែលត្រូវយាងមកទៀតទេ។ នេះហើយជាការបើកសំដែងនៃព្រះតែ១ មិនមែន៣ទេ។ ព្រះតែ១ ប្រឹក្សាដោយព្រះអង្គទ្រង់ មិនមែនពួកទ្រង់ទេ ។ មានព្រះតែ១ ប៉ុណ្ណោះ។

## ព្រះវិញ្ញាណអស់កល្ប

គ្មានអ្វី ដែលអស់កល្បទេ លើកលែងតែ ព្រះវិញ្ញាណដ៏មានព្រះចេស្តាបំផុត ជាព្រះកំពូលជាព្រះដ៏មានគ្រប់គ្រាន់តែ១។ ទ្រង់ជាព្រះដ៏ធំ ហើយខ្ពស់បំផុត ជាព្រះដ៏គង់នៅអស់កល្បជានិច្ចដែលព្រះនាមទ្រង់ជានាមបរិសុទ្ធ(អេសាយ ៥៧: ១៥. មើល ហេព្រើរ ៩:១៤)។ ឯព្រះដ៏ធំហើយខ្ពស់បំផុតនេះ គឺ **អេឡូហ៊ីម** ប៉ុន្តែយើងបានស្គាល់នាមផ្សេងៗទៀត ជាភាសាហេព្រើរ។ **ទោះជាពាក្យ *អេឡូហ៊ីម* លេចមកទំរង់ជាពហុវចនះក៏ដោយ ក៏មិនបានសំដៅថា មានបុគ្គលពហុវចនះដែរ ប៉ុន្តែអានុភាពដ៏អស្ចារ្យនិងភាពធំឧត្តមកំពូល ដែលមានក្នុងព្រះអង្គទ្រង់**ក៏បានសំដែងឲ្យឃើញលក្ខណៈផ្សេងៗ-មានភាពជាឪពុក អ្នកបង្កើត ជាអ្នកទ្រទ្រង់ អ្នកប្រោសឲ្យជាអ្នកសង្គ្រោះ។ល។ មែនហើយ អេឡូហ៊ីមទាក់ទងនឹងភាពជាព្រះរបស់ទ្រង់-អានុភាពដ៏អស្ចារ្យជាព្រះ។ ទាក់ទងទៅនឹងអេឡូហ៊ីម ពាក្យ ***យ៉ាវ៉េ*** (យហវហ) ក៏ត្រូវបានប្រើដែរ។ ***យ៉ាវ៉េ*** មានន័យថា "***ព្រះដ៏មានគ្រប់គ្រាន់តែ១***" ឬ "***អស់កល្បក្នុងព្រះដ៏គង់នៅ***"។ *ឯយ៉ាវ៉េ* គឺព្រះអង្គទ្រង់ទាក់ទងនឹងមនុស្ស ដែលទ្រង់បានបង្កើតពីធូលីដីនៃផែនដី និងជាការលេចបកនៃ អេឡូហ៊ីម ឲ្យមនុស្សអាចឃើញបាន នៅក្នុង ***ការសំដែងនៃព្រះ*** (Theophany ទីអូហ្វានី) តាមរយៈ ***រូបកាយ-ព្រះបន្ទូល។*** គឺជាព្រះ ***អេឡូហ៊ីម***ដែលសំដែងព្រះអង្គទ្រង់ជា ***យ៉ាវ៉េ***។ ***យ៉ាវ៉េ*** គឺជាព្រះនាមនៃសេចក្តីសញ្ញា

ក្នុងសញ្ញាចាស់ ពេលដែលព្រះអង្គរំដោះរាស្ត្រអ៊ីស្រាអែល **(និក្ខមនំ ៦:១៣)** តាមសេចក្ដីសន្យា ដែលទ្រង់ប្រទានទៅអ័ប្រាហាំ (លោកុ. ១៥:១៣-១៦) អាន ជនគណនា ៦:២២-២៧។ នៅក្នុងសញ្ញាថ្មី ពេល ***យ៉ាវេ*** បានយាងមកសម្ដែងព្រះអង្គទ្រង់ផ្ទាល់នៅក្នុងសាច់ឈាម ទ្រង់បានយកព្រះនាម*យ៉ាសួអា* (យេស៊ូអា)។

ច្រំណាំ ដើម្បីបង្ហាញអានុភាពដ៏អស្ចារ្យនៃព្រះជាច្រើនរបស់ពួកគេ ពួកសាសន៍ដទៃ ក៏បានប្រើពាក្យ *អេឡូហ៊ីម* (ជាពហុវចនះ) ដូចគ្នា ពួកគេមានរូបព្រះជាច្រើនសំរាប់ថ្វាយបង្គំ។ ពួកគ្រីស្ទានជាច្រើន ដែលមានគំនិត ផ្ដោតលើពាក្យហេព្រើរ និងក្រិកចំៗ បានប្រើពាក្យ *អេឡូហ៊ីម* យ៉ាងច្បាស់ថា មានព្រះជាច្រើន នៅក្នុងព្រះដ៏ជាកំពូល។ បើសិនការនេះ ជាពិតមែន ចូរគិតពិពាក្យដែលព្រះអម្ចាស់បានមានបន្ទូលទៅម៉ូសេនៅក្នុងនិក្ខមនំ ៣:២៨

*"ក៏បែរសងាកបែរចេញពីផ្លូវ ដែលអញបានបង្គាប់គេ ហើយសិតធ្វើរូបកូនគោ នាំគ្នាក្រាបថ្វាយបង្គំដល់រូបនោះ រួចបានថ្វាយយញ្ញបូជា ដោយប្រកាសថា នែ ពួកអ៊ីស្រាអែលអើយ នេះហើយជាព្រះ (ពាក្យហេព្រើរ អេឡូហ៊ីម) នៃឯង ដែលបាននាំឯងចេញពីស្រុកអេស៊ីពមក"។*

ជាការពិត ព្រះបានដឹងថា មានតែកូនគោមាសតែ១ទេ។ ពួកអ៊ីស្រាអែលបែរចេញពីជំនឿ គេបានសូនកូនគោមាសតែ១ទេ ហើយគេបានថ្វាយបង្គំរូបនោះ (និក្ខមនំ ៣:២៤ )។ តើអាចមានគ្រីស្ទានខ្វាក់មើលមិនឃើញ ដោយជឿថា មានកូនគោមាសច្រើនជាង**១**ឬ?

ការសិក្សាអំពី វាក្យសព្ទ គឺជាការល្អហើយ ប៉ុន្តែវាក្យសព្ទនោះមិនតែងតែនាំឲ្យយើងមានការបើកសំដែងនៃសេចក្ដីពិតទេ ការបើកសំដែងពិត បានមកដោយសារតែការបើកសំដែង ពីព្រះវិញ្ញាណបរិសុទ្ធ ពេលដែលទ្រង់បំភ្លឺព្រះបន្ទូលរបស់ទ្រង់។

ចូរពិចារណាការបង្រៀន ពីសេចក្ដីស្លាប់លើកទី២ គ្មានទីបញ្ចប់ ដ៏ឈឺចាប់ ដល់ពួកមនុស្សអាក្រក់ក្នុងបឹងរហូតតទៅ។ ពាក្យ *"រហូតតទៅ"* ឬ *"អស់កល្ប"* ភាសាក្រិក [Grk: aionios] ដែលប្រើដើម្បីពិពណ៌នាអំពីបឹងភ្លើមានមកដោយសារពួកទេវវិទូជាច្រើន ខាងគម្ពីរ និងគ្រីស្ទានជាច្រើន បានជឿថា ពួកព្រលឹងមនុស្សអាក្រក់ត្រូវតែឆេះរហូតៗទៅគ្មានទីបញ្ចប់។ បើសិនជាការបង្រៀននេះ ពិតជាត្រឹមត្រូវក្នុងគម្ពីរមែន នោះសេចក្ដីស្លាប់មិនមែនជាសេចក្ដីស្លាប់ទៀតឡើយ ។ តើពួកអាក្រក់អាចរស់រហូតគ្មានទីបញ្ចប់-ក្នុងបឹងភ្លើងឬ?

ពិតមែន បើគ្មានព្រះវិញ្ញាណនៃព្រះដ៏បរិសុទ្ធនោះក៏គ្មានជីវិត ដែលរស់នៅរហូតដែរ។ សេចក្ដីស្លាប់ គឺជាសេចក្ដីស្លាប់ វាគឺ ជាការបញ្ចប់នៃជីវិត ។

ឡូហុស: ការចាប់ផ្តើមដំបូងនៃការបង្កើតរបស់ព្រះ

មនុស្សអាក្រក់ទាំងអស់ *"នឹងមានចំណែកនៅក្នុងបឹងភ្លើង ដែលឆេះជាភ្លើង និងស្ពាន់ធ័រ គឺជាសេចក្តីស្លាប់ទី២វិញ"* (វិ.២១:៨) ព្រលឹងមនុស្សនឹងឆេះនៅក្នុងបឹងភ្លើងក្នុងរយៈពេល អាស្រ័យទៅលើការកាត់ទោសដ៏សុចរិតនៃព្រះអង្គដ៏បរិសុទ្ធរបស់អ៊ីស្រាអែលប៉ុណ្ណោះ។

សូមឲ្យខ្ញុំគូសបញ្ជាក់ៈ គ្មានអ្វី បានអស់កល្បពីអតីតកាលទេ គឺមានតែ **ព្រះវិញ្ញាណអស់កល្បដ៏បរិសុទ្ធ-អេឡូហ៊ីម។** ទ្រង់បានមានបន្ទូលទៅអេសាយដែលកត់ត្រា (នៅក្នុងខ មួយចំនួន ក្នុងអេសាយ ជំពូក ៤៣ និង ៤៤) ចែងថា ក្រៅពីទ្រង់ គ្មានព្រះឯណាទៀតទេ។ ហើយ *"ត្បិតគឺដោយសារទ្រង់ហើយ ដែលយើងរាល់គ្នាបានរស់ កំរើក ហើយមាននៅផង"* (កិច្ចការ ១៧:២៨ )។

*"ព្រះយេហូវ៉ា ទ្រង់មានបន្ទូលថា ឯងរាល់គ្នាជាស្មរបន្ទាន់របស់អញ ហើយជាអ្នកបំរើដែលអញបានរើសតាំង ដើម្បីឲ្យបានស្គាល់ ហើយជឿដល់អញ ព្រមទាំងយល់ថា គឺអញនេះហើយ ឥតមានព្រះណាកើតមកមុនអញទេ ហើយក្រោយអញក៏គ្មានដែរ"* ( អេសាយ ៤៣:១០-១១ )។

***"អស់កល្ប"*** **មានន័យថា ម៉ោងនិងកំឡុងពេលមិនកំនត់។** គឺគ្មានការចាប់ផ្តើម និង ការបញ្ចប់ទេ។ គឺបានមានពីដើម មាននៅបច្ចុប្បន្ន និងអនាគតជានិច្ច។ ដូច្នេះ ***ដែលហៅថាយេស៊ូ ថាជាបុត្រា អស់កល្ប នៃព្រះនោះ មិនត្រឹមត្រូវទេ*** ដ្បិតគ្រប់កូនទាំងអស់ មានការចាប់ផ្តើម។ ពាក្យ *បុត្រាអស់កល្ប* គឺពួកជឿព្រះត្រៃឯក ជាអ្នកបង្កើតទេ។ **ព្រះយេស៊ូ គឺជាព្រះបុត្រារបស់ព្រះបង្កើត** (ហេព្រើរ ១:៦ )។ សូមមើលពាក្យទំនាយនៃទំនុកដំកើង ២:៧

*"អញនឹងថ្លែងប្រាប់ពីច្បាប់នេះ គឺព្រះយេហូវ៉ាទ្រង់មានបន្ទូលថា ឯងជាកូនអញ អញបានបង្កើតឯងនៅថ្ងៃនេះ"* ។

ពាក្យ *"ថ្ងៃនេះ"* (ឬ សព្វថ្ងៃនេះ) មិនទាក់ទងនឹងពាក្យអស់កល្បទេ ។បាននិយាយពីពេលវេលា។ ប៉ុន្តែព្រះវិញ្ញាណដ៏មានព្រះចេស្តាបំផុត គង់នៅអស់កល្ប។ ទ្រង់គ្មានទំរង់ ឬរូបកាយ ដែលអាចកំនត់ទ្រង់បានទេ។ ទ្រង់ជាព្រះអាទិករ និងជាព្រះសព្វញ្ញូញ្ញាណ បានជាទ្រង់គង់នៅគ្រប់កន្លែងបាន។ ទ្រង់ជាព្រះដ៏មើលមិនឃើញ (កូល៉ុស ១:១៥, ១ ធីម៉ូថេ ១:១៧ ១:១៦) ហើយមនុស្សរស់មិនអាចមើលឃើញទ្រង់ទេ (យ៉ូហាន ១:១៨, និក្ខមនំ ៣៣:២០)។ អញ្ចឹង តើពួកជឿព្រះត្រៃឯកអាចឃើញព្រះ ជាព្រះវរបិតាដែលគង់នៅលើបល្ល័ង្កក្នុងស្ថានសួគ៌ដោយរបៀបណា? តើលោក យ៉ូសែប ស្ម៊ីត ( និកាយម័រមិន ) អះអាងថា បានឃើញព្រះវរបិតានិងព្រះយេស៊ូគ្រីស្ទ ម៉េចទៅបាន ។

អ្នកខ្លះអាចមានសំនួរថា *"អញ្ចឹង តើពួកបរិសុទ្ធនៃសញ្ញាចាស់ដូចជា អ័ប្រាហាំ ម៉ូសេយ៉ូស្វេ បានឃើញ ឬនិយាយជាមួយនរណា នៅពេលពួកគេ*

*និយាយថា បានឃើញព្រះ ឬនិយាយមុខទល់នឹងមុខ?"* (ឧ. និក្ខមនំ ៣៣:១១, ២៤:៩-១១, យ៉ូសេ ៥:១៣-១៥, លោកុ១៧:១)

ដើម្បីឲ្យបានចំលើយ យើងត្រូវតែមើលនៅក្នុងបទគម្ពីរជាច្រើន ហើយដកស្រង់ចេញពីកន្លែងផ្សេងៗ។ ឥឡូវនេះ យើងដឹងថា ជាញឹកញាប់ បទគម្ពីមានន័យរួម និងថា ព្រះមានបំនងព្រះហឫទ័យលាក់សេចក្តីពិត ដល់ពេល ព្រះសំដែងវិញ។ ការប្រើពាក្យរបស់ពួកហោរា និងពួកសាវក ពិសេសៗនិងជាក់លាក់ ***ជាសេចក្តីជ្រាលជ្រៅរបស់ព្រះ*** បានលាក់ទុកក្នុងពាក្យដែលបានចែងមក និស្ស័យរបស់មនុស្សមិនអាចយល់បានទេ។ សូម្បីព្រះយេស៊ូគ្រីស្ទ បានមានបន្ទូលបែបដូចនេះដែរ *"ដើម្បីឲ្យបទគម្ពីរបានសំរេច"* ( ឧ. អាន យ៉ូហាន ២:១៩, ៦:៥៣-៥៨ ១៣:១៨ )។

ចូរមើលនិក្ខមនំ ៣៣:១៤

*"នោះទ្រង់មានបន្ទូលថា វត្តមានរបស់អញ ( ពាក្យហេព្រើរ គឺព្រះភក្ត្រព្រះ ) នឹងទៅជាមួយនឹងឯង"*។

ឥឡូវនេះ តើ ***"វត្តមានរបស់អញ"*** (ឬ ***"មុខអញ"***) មានន័យដូចម្តេច? អេសាយ៦៣:៩ ចែងថា: *"ក្នុងគ្រប់ទាំងសេចក្តីទុក្ខរបស់គេ នោះទ្រង់ក៏រងទុក្ខដែរ ហើយទេវតាដែលនៅចំពោះ ( ឬព្រះភក្ត្រទ្រង់ ) ទ្រង់បានសង្គ្រោះគេ"*។

វត្តមានរបស់ព្រះអម្ចាស់ **មានតែ១គត់** ដែលទ្រង់បានយាងទៅជួបអ័ដាម និងអេវ៉ា នៅសួនច្បារអេដែន (លោកុ ៣:៨) *"ទេវតានៃវត្តមានរបស់ទ្រង់"* ដែល *"បានសង្គ្រោះ"* អ៊ីស្រាអែល គឺជាអ្នកសង្គ្រោះរបស់ពួកគេហើយ ពួកគេដឹងថា ពួកគេមាន**អ្នកសង្គ្រោះតែ១គត់។** ដូច្នេះ ពួ*កបរិសុទ្ធទាំងនេះ* ត្រូវតែឃើញ និងនិយាយជាមួយព្រះមែស៊ី គឺជាព្រះភក្ត្រ ឬ វត្តមានដែលអាចមើលឃើញបាន របស់ព្រះដែលមានព្រះចេស្តាបំផុត ទ្រង់តែ១គត់ *"នឹងយាងទៅមុនឯង"* *"បានលើកគេ ហើយបីគេ"* ហើយ *"សង្គ្រោះគេ"*។

ក្នុងនិក្ខមនំ ២៣:២០-២៣

*"មើលអញចាត់ទេវតា១ (ពាក្យហេព្រើរៈ អ្នកនាំព្រះរាជសារ) ឲ្យនាំមុខឯងដើម្បីនឹងជួយទំនុកបំរុងឯងតាមផ្លូវ ហើយនឹងនាំទៅដល់ទីកន្លែង ដែលអញបានរៀបចំទុកឲ្យ ចូរប្រយ័ត្ននឹងស្តាប់តាមទ្រង់ ដ្បិតទ្រង់មិនអត់ទោសការរំលងរបស់ឯងរាល់គ្នាទេ ពីព្រោះឈ្មោះអញ នៅក្នុងទ្រង់ បើឯងប្រុងស្តាប់បង្គាប់ទ្រង់ ហើយប្រព្រឹត្តសេចក្តីដែលអញ បង្គាប់ដល់ឯងទាំងប៉ុន្មាននោះ អញនឹងធ្វើជាសត្រូវដល់ពួកសត្រូវរបស់ឯង ហើយជាអ្នកតតាំងនឹងអស់អ្នកដែលតតាំងនឹងឯង ដ្បិតទេវតាអញ នឹងទៅមុខឯង ហើយនឹងនាំឯងទៅពួកសាសន៍ អាម៉ូរី សាសន៍ហេត សាសន៍ពេរីស៊ីត សាសន៍កាណាន សាសន៍ហេវី និងសាសន៍យេប៊ូស ហើយអញនឹងធ្វើឲ្យសាសន៍ទាំងនេះសាបសូន្យទៅ"...*

ឡូហ្គុស: ការចាប់ផ្តើមដំបូងនៃការបង្កើតរបស់ព្រះ

ខ នេះបានបង្ហាញយ៉ាងច្បាស់ថា ព្រះដ៏មានចេស្តាបំផុត មានអ្នកនាំព្រះរាជសារ ដែលធ្វើចំពោះព្រះហទ័យរបស់ព្រះ។ ទ្រង់បានធ្វើជាអ្នកជំនួសព្រះ ហើយជាព្រះ។ ព្រះបានព្រមាន ពួកអ៊ីស្រាអែលថា ឲ្យស្តាប់បង្គាប់តាមសំលេងរបស់ទ្រង់ ហើយកុំតតាំងនឹងទ្រង់។ បើស្តាប់សំលេងរបស់ទ្រង់មានន័យថា បានធ្វើគ្រប់ទាំងព្រះបន្ទូល ដែលទ្រង់បានមានបន្ទូល (តាមរយៈអ្នកនាំព្រះរាជសារ) ពីព្រោះ ព្រះនាមរបស់ព្រះបាននៅក្នុងទ្រង់។ ហើយមានតែបុគ្គលម្នាក់ទេ នៅស្ថានសួគ៌ និងផែនដី ដែលមានព្រះនាមរបស់ព្រះនៅក្នុងទ្រង់។ ក្រៅពីព្រះយេស៊ូគ្មាននរណាទៀតទេជាព្រះរាជបុត្រានៃព្រះដ៏មានជន្មរស់

*"ខ្ញុំបានមកក្នុងព្រះនាមនៃព្រះវរបិតារបស់ខ្ញុំ" ( យ៉ូហាន ៥:៤៣ )*

*"ព្រះវរបិតាទ្រង់មិនជំនុំជំរះអ្នកណាទេ ទ្រង់បានប្រគល់គ្រប់ការជំនុំជំរះដល់ព្រះរាជបុត្រវិញ ដើម្បីឲ្យមនុស្សទាំងអស់បានគោរពប្រតិបត្តិដល់ព្រះរាជបុត្រា ដូចជាគោរពប្រតិបត្តិដល់ព្រះវរបិតា អ្នកណាដែលមិនគោរពប្រតិបត្តិដល់ព្រះរាជបុត្រា នោះដូចជាមិនគោរពដល់ព្រះវរបិតា ដែលចាត់ឲ្យទ្រង់មកដែរ"* (យ៉ូហាន ៥:២២-២៣)

អញ្ចឹង តើនេះមានន័យថា មុននឹងទ្រង់យាងមកលើផែនដី ព្រះយេស៊ូមានមុនរួចហើយឬ? តើនរណាជាវត្ថុមានដ៏មើលឃើញ របស់ព្រះ ដែលកាន់ព្រះនាមនៃព្រះ ក្នុងទ្រង់ និងជាអ្នកជួយសង្គ្រោះរបស់អ៊ីស្រាអែល?

## ព្រះវិញ្ញាណដ៏មើលមិនឃើញព្រះបន្ទូលដ៏មើលឃើញ

មានចំលើយខុសៗគ្នាជាច្រើន ទៅនឹងសំនួរនេះ ទាក់ទងនឹងការមានរួចហើយរបស់ព្រះយេស៊ូ បានបណ្តាលឲ្យមានការភាន់ច្រលំនៅក្នុងចំណោមអ្នកជឿគម្ពីរមែនទែន។ ក្រៅពីពួកជឿព្រះត្រៃឯកជាច្រើននាក់ និងមិនមែនពួកជឿព្រះត្រៃឯកខ្លះ ដែលជឿថា ព្រះយេស៊ូបានមានរួចហើយ មុនជីវិតនៅផែនដីទៅទៀត។ [ចំណាំៈ ពេលខ្លះ ចំលើយហាក់ដូចជាពិត នឹងត្រឹមត្រូវអាចគ្រាន់តែបង្កើតចេញថា ជាចំលើយប៉ុណ្ណោះ។ ឧទាហរណ៍ ជាទូរទៅ ចំពោះគ្រីស្ទានជាច្រើនយោងទៅលើខ នៃបទគម្ពីរ ដែលចែងពី ព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិហារបរិសុទ្ធ និងសង្ខេបសង្ខេបភ្លាមថា ព្រះគឺជា *ព្រះត្រៃឯកមានបុគ្គល៣*នៅក្នុងបុគ្គល១។ ឧទាហរណ៍ផ្សេងទៀត គឺការប្រើរូបមន្តនៃពិធីជ្រមុជខុស ក្នុងពិធីជ្រមុជទឹក។ ជំនួសឲ្យរូបមន្ត ដែលបានចែងមុន យ៉ាងច្បាស់លាស់ ក្នុងកិច្ចការ ២:៣៨ ពួកជុំនុំជាច្រើន ឆាប់ដើរតាម*បញ្ជា* ក្នុងម៉ាថាយ ២៨:១៩ ដោយគ្មានការយល់ដឹងត្រឹមត្រូវនៃអត្ថន័យពិត។ ហេតុនេះហើយ បានជាមានការបកស្រាយខុសៗគ្នា ជាច្រើន អំពីព្រះដ៏ជាកំពូល និងគោលលទ្ធិផ្សេងទៀតនៃគម្ពីរ។]

**ទេ ព្រះយេស៊ូមិនបានមានពីមុន ជាបុគ្គលដោយឡែកពីព្រះ ឬទ្រង់មានពីមុនជាព្រះរាជបុត្រានៃព្រះ នៅពេលណាមួយ មុនបេថ្លេហិមនោះទេ ។** ទោះបីយ៉ាងណាក៏ដោយ **វិញ្ញាណនៃប្រះបុត្រានៃព្រះ** គឺជា**ព្រះបន្ទូល។** នោះគឺជាលក្ខណះនៃព្រះបន្ទូល ដែលលេចមកក្នុងព្រះយេស៊ូ ។ បើគ្មានវិញ្ញាណនៃព្រះបុត្រាក្នុងព្រះបន្ទូល ក៏គ្មានព្រះបុត្រាដែរ ។ ប៉ុន្តែ និយាយបែបនេះខុសទេ ថាព្រះយេស៊ូ គឺព្រះបន្ទូល និងថាទ្រង់មានតាំងពីមុនមក ។ ច្រំណាំ សូមឲ្យអានកថាខណ្ឌចុងក្រោយ ដែលមានចំណងជើងថា **និស្ស័យ២យ៉ាង** ឃ្លាស្រដៀងគ្នានេះ មានគំនិត ឆ្លើយសំនួរះ តើព្រះសុគតជំនួសបាបយើងឬ?] ២ សហសវត្សមកហើយ ព្រះគ្រីស្ទ បានជាសេចក្តីអាថ៌កំបាំងដ៏ធំនៃព្រះ សំរាប់មនុស្សគ្រប់សម័យ។ សេចក្តីអាថ៌កំបាំងនៃទំនាក់ទំនងនៃព្រះបិតា និងបុត្រាត្រូវបានលាក់ទុក។ ព្រះយេស៊ូដែលគង់នៅក្នុងព្រះឱរ៉ា ព្រះបានចាត់មកប្រកាសអំពីព្រះបិតាជាព្រះវរបិតារបស់ទ្រង់និងជារបស់យើង ជាព្រះរបស់ទ្រង់ និងជាព្រះយើង (យ៉ូហាន២០:១៧)

ពួកស្ងួនភ្ងាអើយ យើងត្រូវតែយល់ដឹងឲ្យបានត្រឹមត្រូវ អំពីអាថ៌កំបាំងដ៏ធំបានលាក់ទុកក្នុងព្រះបន្ទូល ដែលគង់នៅជាមួយនឹងព្រះ។ យើងមិនត្រូវធ្វើអ្វីតាមអ្នកបកប្រែគម្ពីរ និងកាត់ស្រាយគម្ពីរខ្លះដែលធ្វើឲ្យព្រះបន្ទូលផ្ទាល់ស្មើនឹងព្រះយេស៊ូ។ ពួកគេបាននិយាយថា *"ព្រះបន្ទូលគឺជា ព្រះយេស៊ូ"* ជំនួសឲ្យ *"ព្រះបន្ទូល គឺជាព្រះ"*។ នេះគឺជាផ្នែក១នៃការកាត់ស្រាយតាមទំលាប់បុរាណនៅចំណោមពួកជឿព្រះត្រៃឯក។ បើនេះគឺជាការកាត់ស្រាយពិតមែន នោះសាវកយ៉ូហាន នឹងបានសរសេរតាមរបៀបនោះហើយ។ ការបកស្រាយខុសជាច្រើននេះ បានប្រើព្រះបន្ទូលនៅក្នុងយ៉ូហាន ១:១៤ *"ហើយព្រះបន្ទូលបានត្រឡប់មកជាសាច់ឈាម ...."*។ ប៉ុន្តែ ខ នេះមិនទាក់ទងនឹងកំនើតនៃព្រះយេស៊ូ នៅបេថ្លេហិមទេ ឬ កំនើតរបស់ទ្រង់ក្នុងផ្ទៃរបស់ម៉ារីទាក់ទងនឹងព្រះបន្ទូលលេចមកក្នុងជីវិត (សាច់ឈាម) របស់ព្រះយេស៊ូ ក្នុងពន្ធ័កិច្ចរបស់ទ្រង់ បន្ទាប់ពីព្រះមកគង់ក្នុងទ្រង់ នៅទន្លេយ័រដាន់។ ចាំទេ ព្រយេស៊ូ គឺជាព្រះបុត្រានៃព្រះតែ១គត់មិនមែនព្រះបុត្រាអស់កល្ប។

បទគម្ពីរ១នេះ ពួកក្រុមជឿព្រះត្រៃឯកចូលចិត្តប្រើ ១យ៉ូហាន៥ ខ ៧ *"មានសាក្សី៣អង្គ ដែលធ្វើបន្ទាល់នៅស្ថានសួគ៌ គឺជាព្រះវរបិតា១ ព្រះបន្ទូល១និងព្រះវិញ្ញាណបរិសុទ្ធ១ តែទាំង៣ អង្គនេះ រួមមកតែ១ ទេ"*។

និស្សិតគម្ពីរយ៉ាងហ្មត់ចត់ បានដឹងថា ខ នេះមិនមែនជាផ្នែក នៅក្នុងគម្ពីរបរិសុទ្ធទេ។ គម្ពីរដើមពីមុន បានចាប់ផ្តើមមកគ្មានឃើញពាក្យនេះទេ។ ទោះបីយ៉ាងណា យោបល់ល្ងង់ល្ងើបានកើតឡើងក្នុងចំណោមពួកជឿព្រះត្រៃឯកដែលពួកគេខំបញ្ជាក់ថា ព្រះត្រៃឯកមានក្នុងខ នេះ ដោយពាក្យ *"ទាំង៣*

ឡូហ្ការុស: ការចាប់ផ្តើមដំបូងនៃការបង្កើតរបស់ព្រះ

*អង្គ រួមមកតែ"។* ប៉ុន្តែ *"ទាំង៣ អង្គនេះ គឺតែ១"* មិនមែន *"ទាំង៣អង្គព្រម ព្រៀងគ្នាតែ១ទេ"។* នេះមិនបានថា *"ទាំង៣អង្គ នៅក្នុង ១ទេ ឬ ព្រះ អង្គ រួមគ្នាជាព្រះដ៏ជាកំពូល"* ទេ ។

(ចំណាំ ចំពោះ ពួកប្តឹងផ្តល់ថា ព្រះយេស៊ូ បានគង់នៅមុនបេថ្លេហិម ពីព្រោះ បទគម្ពីរបានចែងថា "ព្រះវរបិតាបានចាត់ព្រះរាជបុត្រា *"ពួកគេគួរតែបានបង្ហាញថា យ៉ូហាន-បាទីស្ទពិតជាមនុស្សរួចហើយ ពីមុនកំណើតកើតដូចបទគម្ពីរបានចែងមកថា" មាននុស្សម្នាក់ ឈ្មោះយ៉ូហាន ដែលព្រះបានចាត់ឲ្យមក"។* មានពាក្យឲ្យមកថា ព្រះបន្ទូលបាននាំចេញ ក្នុងការចាប់ផ្តើម គឺព្រះរាជបុត្រាតែ១គត់។ យើងត្រូវតែនិយាយថា អ័ដាម ជាបុត្រាតែ១គត់ដែរ ពីមុនកំណើតរបស់គាត់មកក្នុងពិភពលោក ពីរូបកាយធ្វើពីដី។ ដូចជាវិញ្ញាណរបស់អ័ដាម **រូបកាយ-ជាព្រះបន្ទូល** មានទាំងប្រុស និងស្រី។ អ័ដាម ដែលមានរូបរាងជាវិញ្ញាណ មានទាំងប្រុស និងស្រីមិនអាចហៅថាជាកូនប្រុសទេ លក្ខណៈថា ជាកូនប្រុសស្រីរបស់ព្រះ បាននៅខាងឯវិញ្ញាណ។ គឺមានបុរសមុនហើយបន្ទាប់មក គឺប្រពន្ធរបស់បុរស(ស្ត្រី)។ ដូចគ្នាដែរ ព្រះបុត្រាលក្ខណៈរបស់ព្រះ ដូចជាពួកជំនុំជារបស់ផងទ្រង់ (កូនក្រមុំខាងវិញ្ញាណ) បាននៅក្នុងតែព្រះបន្ទូល ដល់ពេលរូបកាយសាច់ឈាម បានមានរូបរាងឡើង ដើម្បីឲ្យព្រះវិញ្ញាណគង់នៅខាងក្នុង។ ដំបូងមានមនុស្សជា ព្រះគ្រីស្ទយេស៊ូ ហើយបន្ទាប់មកកូនក្រមុំរបស់ទ្រង់(ពួកជំនុំ)បានដកចេញពីឆ្អឹងជំនីរទ្រង់នៅភ្នំកាល់វ៉ារី។ រូបកាយវិញ្ញាណរបស់ព្រះយេស៊ូប្រឆាំងនឹងរូបកាយអ័ដាម ជាមនុស្ស។)

ពីមុនកូនប្រុសបានកើតមក វាជាពូជនៅក្នុងឪពុករបស់វាហើយ។ ប៉ុន្តែកូនប្រុសមិនទាន់មានឡើង ជាបុគ្គលដាច់ចេញពីឪពុកនៅឡើយ ប៉ុន្តែគឺជាពូជក្នុងឪពុក។ សូមចាំ ព្រះវិញ្ញាណដ៏មានព្រះចេស្តាបំផុត មានលក្ខណៈជាច្រើន អ្នកបង្កើត អ្នកប្រោសឲ្យជា អ្នកសង្គ្រោះ អ្នកច្បាំងអ្នកការពារ។ល។ លក្ខណៈទាំងអស់នេះនៅក្នុងពូជដែលបាននាំចេញឈ្មោះក្នុងគ្រួសារ។ ដើម្បីបង្ហាញចេញលក្ខណៈនេះ ព្រះបានបង្ហាញចេញការងារ ប្រកាសក្នុងព្រះបន្ទូលរបស់ទ្រង់និងសំដែងក្នុងនាមរបស់ទ្រង់ (យ៉ូហាន៥:១៧.១៧:៣-១០ ) ក្នុងព្រះប្រាជ្ញ (អេភេសូរ១:១១) ទ្រង់បានដំរូវទុក ក៏ដំកើងឡើង ហើយបានហៅរបស់ទាំងអស់នេះ មិនទាន់និងមាន ថាមានរួចហើយ (រ៉ូម៤:១៧) ។ ហើយព្រះយេស៊ូ គឺ ជាពូជក្នុងព្រះវិញ្ញាណអស់កល្ប នៅក្នុងព្រះឧរាព្រះវរបិតាបន្ទាប់មក ទ្រង់បានចេញជាព្រះបុត្រាតែ១គត់ ដើម្បីសំរេចផែនការ ដំរូវទុករបស់ព្រះ (យ៉ូហាន ១:១៨)។

មានតែព្រះយេស៊ូទេ បានមានបន្ទូលជាទំនាយជាពាក្យចំថា ព្រះអង្គដែលត្រូវយាងមកក្នុងសញ្ញាចាស់ ហើយព្រះវរបិតាតែងតែទំនាក់ទំនងជាមួយព្រោះទ្រង់ជាព្រះបន្ទូលដែលយាងមករំដោះ និងលេចមកនៅពេលផ្សេងៗទៀត ក្នុងលក្ខណះបុព្វបុរសតាមពួកហោរា(ហេព្រើរ១:១)។ ទ្រង់តែ១គត់បានមានឡើងនៅក្នុងគំនិតរបស់ព្រះ នៅពេលចាប់ផ្តើម ថាជាព្រះបន្ទូលនិងនំប៉័ងដែលក្រោយមកបានចុះពីស្ថានសួគ៌ជាព្រះរាជបុត្រានៃព្រះ (យ៉ូហាន ៦)។ ហើយពេលសំរេចកំនត់បនាមកដល់ ព្រះបានចាត់ព្រះរាជបុត្រានៃព្រះ ឲ្យកើតឬ(ត្រូវបានបង្កើត) ពី ព្រហ្មចារី។ ព្រះយេស៊ូគ្រីស្ទជាព្រះរាជបុត្រាតែ១គត់របស់ព្រះ ប៉ុន្តែបានកើតពីនាងព្រហ្មចារី។ មារីបានបង្កើតកូនប្រុស១ មុនគេជាព្រះរាជបុត្រាតែ១គត់របស់ព្រះ ។ ព្រះយេស៊ូគ្រីស្ទ គឺជាបងច្បងនៅក្នុងពួកបងប្អូនជាច្រើន [រ៉ូម ៨:២៩]

ព្រះអង្គដែលមើលឃើញ គឺជាទេវតានៃព្រះ មិនមែនព្រះ និងអ្នកសង្រ្គោះណា១ទៀតទេដ្បិតព្រះបានប្រកាសថាៈ

*"ចូរថ្លែងប្រាប់ហើយសំដែងហេតុចេញនេះ ត្រូវឲ្យប្រឹក្សាគ្នាផង តើអ្នកណាបានប្រាប់ពីការនេះចាប់តាំងពីចាស់បុរាណមក តើនរណាបានទាយទុកតាំងពីយូរមកហើយ តើមិនមែនអញជាយេហូវ៉ាទេឬអី ក្រៅពីអញ គ្មានព្រះឯណាទៀត ដែលជាព្រះសុចរិត ហើយជាព្រះអង្គសង្គ្រោះទេ គ្មានណា១ក្រៅពីអញឡើយ" (អេសាយ ៤៥:២១)។*

ក្នុងចំណោមអ្នកសិក្សាព្រះគម្ពីរយល់ថា នេះជាព្រះមើលឃើញ បានលេចនៅក្នុងសញ្ញាចាស់ទៅដល់ពួកហោរា ក្រៅពៅ ***ទីអូហ្វានី*** បានលេចមកថា ជាព្រះ។ គឺជាព្រះបន្ទូលនៃព្រះ ជា ការគិត និងគំនិតនៃព្រះ ដែលនិយាយចេញ និងបើកសំដែងក្នុងរបៀប ឬទំរង់ជាច្រើន។

សូមយើងមើលឲ្យច្បាស់ក្នុងព្រះបន្ទូលរបស់ព្រះ នៅក្នុងបទគម្ពីរ ហើយត្រូវសំរេចអ្វីជាព្រះវិញ្ញាណអស់កល្បដ៏ធំ បានប្រឹក្សា ហើយព្រះហឬទ័យរបស់ទ្រង់ត្រូវតែធ្វើ។

## សែន(ពូជ)តែ១គត់

## ការចាប់ផ្តើមនៃការបង្កើតរបស់ព្រះ

ក្នុងការបកប្រែគម្ពីរ របស់ បាក្លេ ក្នុងដំណើរល្អរបស់យ៉ូហាន ៥ ខ។

*"ពេលដែលពិភពលោកបានចាប់ផ្តើម ព្រះបន្ទូលបានគង់នៅរួចហើយ។ ព្រះបន្ទូល បានគង់នៅជាមួយនឹងព្រះ។ ធម្មជាតិទាំងអស់ គឺព្រះបន្ទូល ដូចគ្នាដែរ ធម្មជាតិទាំងអស់នេះ គឺជាព្រះ។*

*ព្រះបន្ទូលបានគង់នៅជាមួយនឹងព្រះតាំងពីដើមមក។*

ឡូហ្គុស: ការចាប់ផ្ដើមដំបូងនៃការបង្កើតរបស់ព្រះ

*របស់ទាំងអស់បានគ្រប់គ្រងដោយព្រះបន្ទូល និងគ្រប់អ្វីៗទាំងអស់ បានមានឡើង។ គ្មានព្រះបន្ទូល គ្មានរបស់អ្វី១ បានមានឡើងទេ។*

*ព្រះបន្ទូលនេះហើយ ជាច្បាប់ជីវិតនៅក្នុងរបស់កើតឡើងទាំងអស់ ហើយជីវិតនោះ គឺជាពន្លឺនៃមនុស្ស។*

*ពន្លឺបន្តចាំងនៅក្នុងទីងងឹត ហើយងងឹតមិនដែលអាចពន្លត់ពន្លឺបានទេ"*

**ព្រះបន្ទូល** (ពាក្យក្រិកៈ **ឡូហ្គុស**) ជាភ្នាក់ងារ ដែលគ្រប់របស់បានមានឡើង។ បើពុំគ្មានព្រះបន្ទូលទេ ក៏គ្មានអ្វី មានឡើង ឬកើតមកដែរ។ ***"ដ្បិតព្រះបន្ទូល គឺជាព្រះហើយ"។*** គ្មានព្រះបន្ទូល គ្មានអ្វីៗទាំងអស់ **ព្រះបន្ទូល**បានចាប់ផ្ដើមជាមួយនឹងព្រះ។ ដោយមិនសង្ស័យ ជីវិតបាននៅក្នុងព្រះបន្ទូល។ គឺនៅតែដដែល។ ព្រះយេស៊ូបានបន្ទូលថា *"គឺជាវិញ្ញាណ ដែលឲ្យមានជីវិត រូបសាច់គ្មានប្រយោជន៍អ្វីទេ ឯពាក្យដែលខ្ញុំនិយាយនឹងអ្នករាល់គ្នានោះត្រូវខាងវិញ្ញាណនិងជីវិតវិញ"* យ៉ូហាន ៦:៦៣។

តាំងពីគ្រប់របស់ទាំងអស់បានមកដោយសារព្រះបន្ទូល (អ្វីដែលជាជីវិត) ដែលបានចាប់ផ្ដើមជាមួយនឹងព្រះ យើងអាចនិយាយយ៉ាងសាមញ្ញថា ព្រះបន្ទូល គឺជាពូជនៃជីវិត។ យើងក៏ ហៅព្រះបន្ទូលថា ជាពូជរបស់ព្រះ។ ហើយបើយើងស្គាល់បទគម្ពីរយើងនឹងបានដឹងព្រះបន្ទូលនេះតាមរយៈមេកុលសម្ព័ន្ធ (ពាក្យក្រិកៈ*អ៊ីន*) គ្រប់ហោរាទាំងអស់នៅក្នុងសញ្ញាចាស់ *"ក្នុងការបើកសំដែងដោយឡែកជាច្រើន- ដែលនាំចេញជាផ្នែកនៃសេចក្ដីពិត-នឹងតាមបែបផ្សេងៗជាច្រើន"* ( ហេព្រើរ ១១ គម្ពីរ Amplified )។ ប៉ុន្តែព្រះ *"បានមានបន្ទូលដល់យើងនៅថ្ងៃចុងក្រោយនេះ តាមរយៈព្រះរាជបុត្រារបស់ទ្រង់ ដែលជាភាពភ្លឺនៃសិរីល្អរបស់ទ្រង់ និងជារូបភាពផ្ទាល់នៃបុគ្គលរបស់ទ្រង់ (ពាក្យក្រិកៈ* ***ហ៊ីលប៉ូស្តាស៊ីស-សារធាតុ,អ្វីដែលមាននៅ,និស្ស័យពិត។*** *ពាក្យ "បុគ្គល" គឺជាការបកប្រែខុស )....."*(ហេព្រើរ ១:២-៣)។

ត្រូវហើយ ព្រះបន្ទូលរបស់ព្រះបានបើកសំដែងនៅសញ្ញាចាស់តាមហោរារបស់ព្រះ ជាច្រើនដងច្រើនបែបផ្សេងពីគ្នាមិនគ្រាន់តែនិយាយចេញ ឬពុំ ប៉ុន្តែបានលេចមក ហើយឲ្យឃើញតាមពួកបរិសុទ្ធរបស់ព្រះ ហើយក្នុងការបើកសំដែងនិមួយៗរបស់ព្រះ,ព្រះបន្ទូលបានសំដែងតាមរបៀប ផ្សេងៗពីគ្នាឲ្យនាំមកឃើញរូបរាងឬ មានគំរូនៃព្រះគ្រីស្ទ (ព្រះយេស៊ូ) ដែលត្រូវយាងមកជាសេចក្ដីពោរពេញនៃព្រះបន្ទូលត្រូវមកសំរេចទាំងអស់ក្នុងបទគម្ពីរ (ព្រះបន្ទូល) បានមានបន្ទូលអំពីទ្រង់។ ដូច្នេះ នៅក្នុង***សេនតែ១*** គឺជាវិញ្ញាណនៃភាពជាព្រះរាជបុត្រា (ពូជបង្កើត) ដែលក្រោយមកបានលេចមកក្នុងព្រះយេស៊ូ គឺជាព្រះរាជបុត្រាតែ១គត់។

*"កាលដើមដំបូង មានព្រះបន្ទូល ព្រះបន្ទូលក៏គង់នៅជាមួយនឹងព្រះ ហើយព្រះបន្ទូលនេះឯងជាព្រះ"* យ៉ូហាន១:១ ។

ពាក្យ ***"កាលដើមដំបូង"*** មិនមានន័យថា ***"ក្នុងអស់កល្ប"*** ឬ ***"មិនមានការចាប់ផ្តើម"។*** ដូចជាស្ថានសួគ៌ និងផែនដី ហើយពួកទេវតា ក៏មានការចាប់ផ្តើមដែរ ***"ព្រះបន្ទូល"*** ក៏មានការចាប់ផ្តើម ។ ហើយព្រះបន្ទូលនេះ បន្ទាប់មកក៏ត្រឡប់មកជាសាច់ឈាម ស្នាក់នៅចំណោមមនុស្ស។

ពាក្យថា ***"ព្រះបន្ទូល"*** បានពីពាក្យក្រិត **"ឡូហ្គុស"** ដែលជាគំនិតដែលសំដែងនៃព្រះហើយមកគ្រាន់តែជាការគិតនៃគំនិតទេ ពាក្យក្រិក ណូអ៊ីម៉ា ឬការផ្តល់ហេតុផល (ពាក្យក្រិកៈ ឌីឡូគីសម៉ុស) គ្មាននរណាអាចញែកមនុស្សចេញពីគំនិតរបស់គាត់បានទេ (ពាក្យក្រិកៈណូន) ដែលគំនិតទាំងអស់បាននៅក្នុងនោះហើយ។ ដូច្នេះ បើមានព្រះដ៏មានចេស្តាបំផុត គំនិតព្រះ នៅក្នុងទ្រង់។

ចាប់តាំងពីអស់កល្បមក ពីមុនរបស់ទាំងអស់បានមានមក មានតែព្រះដ៏មានព្រះព្រះចេស្តាបំផុត។ ទ្រង់ ជា**ព្រះមិនខ្វះអ្វីទាំងអស់**។ ព្រះអង្គគិតទាំងអស់នៅក្នុងគំនិតរបស់ទ្រង់។ ប៉ុន្តែ មិនទាំងបានសំដែងចេញនៅឡើយ ។ ព្រះបន្ទូលមិនទាន់បានលេចមកនៅឡើយ។ គឺគ្រាន់តែនៅក្នុងគំនិតរបស់ទ្រង់

ការគិត គឺជាពាក្យ មិនទាន់បាននិយាយចេញ ឬសំដែងចេញ។ វាគ្រាន់តែនៅក្នុងគំនិត។ ផ្ទុយទៅវិញ ពាក្យ គឺការគិត ដែលសំដែងចេញ ឬនិយាយចេញ។ ហើយការសំដែងចេញ គឺជាពាក្យ ឬសកម្មភាព។ ដូច្នេះ ឡូហ្គុស គឺជាគ្រាន់តែ**ការគិត បូកនឹង ការសំដែងចេញ** (ឬការបើកសំដែង)។ ជាសមញ្ញ **ឡូហ្គុស**តំណាងឲ្យ**ព្រះបន្ទូល ដែលថ្លែងចេញ**តាមក្រោយ។

បើមានគំនិតយ៉ាងនេះ យើងអាចឃើញហេតុអ្វី លោកយ៉ូហានបានសរសេរ ***"កាលដើមដំបូង មានព្រះបន្ទូល (ឡូហ្គុស)"។*** ពីមុន ពេលវេលាកាលដើមដំបូងឡើយ ពេលនោះ គឺមានតែ ព្រះដ៏មានព្រះចេស្តាបំផុត និងការគិតរបស់ទ្រង់ (មិនមែន*ឡូហ្គុស* ទេ)។ប៉ុន្តែបន្ទាប់មកទ្រង់បានប្រឹក្សាជាមួយនឹងអង្គទ្រង់ផ្ទាល់ចប់ហើយ ហើយមានព្រះហឬទ័យក្នុងគំនិតរបស់ទ្រង់ទ្រង់បានចាប់ផ្តើមថ្លែងចេញតាមផ្នែកនិមួយៗ *"បន្ទាប់ពីប្រឹក្សាមក (ពាក្យក្រិកៈ បូល) ព្រះហឬទ័យរបស់ទ្រង់"* អេភេសូរ ១:១១។ នោះហើយ ជាការចាប់ផ្តើមនៃឡូហ្គុស ឬពាក្យថ្លែងចេញ នៅក្នុងការគិតរបស់ទ្រង់។ **អេឡូហ៊ីម** បានចាប់ផ្តើមធ្វើ**រូបកាយខាងវិញ្ញាណ** ហៅថា**ព្រះបន្ទូល** ជារូបកាយ ដែលស្រដៀងនឹងពួកទេវតា ដែលត្រូវបានបង្កើតមក នៅពេលក្រោយទៀត ប៉ុន្តែមិនដូចរូបកាយខាងវិញ្ញាណរបស់ពួកទេវតាទេរូបកាយខាងវិញ្ញាណនោះ ដែលចេញមកពីអេ**ឡូហ៊ីម គឺជីវិតផ្ទាល់** ពីព្រោះបានបន្តក្នុងការបើកសំដែងនៃព្រះបន្ទូលរបស់ព្រះ

ឡូហ្គុស: ការចាប់ផ្តើមដំបូងនៃការបង្កើតរបស់ព្រះ

គឺជាជីវិតហេតុនេះ "នៅក្នុងទ្រង់មានជីវិត" យ៉ូហាន១:៤ ។ ហើយព្រះក៏ចាប់ផ្តើមមានបន្ទូលជាការគិតទៅរូបកាយព្រះបន្ទូលរបស់ទាំងអស់បានមានមក។

(ចំណាំៈ ពួកទេវវិទូ ដែលបានជឿថាមានព្រះ២ បានបង្រៀនថា ព្រះបន្ទូល *"ព្រះ" ក្នុងឃ្លា "ព្រះបន្ទូលក៏គង់ជាមួយនឹងព្រះ"* យ៉ូហាន ១:១ បានមកជា ***យ៉ាវេ*** ក្នុងភាសាហេព្រើរ ហើយពីព្រោះពាក្យ យ៉ាវេប្រើជំនួស *"អេឡូហ៊ីម"* ពួកគេបានដកចេញ កាលដើមដំបូងហើយចាត់ទុកថា ឡូហ្គុស បានចេញពីព្រះវិញ្ញាណ ជាអ្នកស្មើនឹងព្រះវិញ្ញាណដ៏មានព្រះចេស្តាបំផុត (អេឡូហ៊ីម) ពី *"អស់កល្ប"*។ ដូចជាពួកជឿព្រះត្រៃឯក ពួកគេបានហៅព្រះពុទ្ធឡូហ្គុស ជាសមាជិកទី២ ក្នុងគ្រួសារ អេឡូហ៊ីម។ យើងនឹងឃើញបន្តមក ហេតុអ្វីបានគោលលទ្ធិព្រះច្រើនមិនបានឆ្លុះបញ្ចាំងពីគំរូនៃរោងឧបោសថម៉ូសេ។)

## ព្រះបន្ទូល និងព្រះយេស៊ូ

ខ្ញុំអធិស្ឋានឲ្យអ្នកបានយល់ការបើកសំដែង នៅលើ២យ៉ាង អំពីព្រះយេស៊ូ និងព្រះបន្ទូល។ អ្នកសិក្សាខាងគម្ពីរជាច្រើន បាននាំឲ្យយើងជឿថា កាលដើមដំបូង ព្រះបន្ទូល គឺជាព្រះយេស៊ូហើយទ្រង់បានត្រឡប់មកជាសាច់ឈាម ជាង២ សហសវត្សមកហើយ។ ប៉ុន្តែ បើនិយាយថាព្រះបន្ទូល គឺជាព្រះយេស៊ូ ពួកគេបានប្រាប់មកយើង ការចាប់ផ្តើមឡើង ជីវិតគង់អស់កល្បជានិច្ច (ឬ ក្នុងកំឡុងពេលនោះ គឺ *"កាលដំបូង"* យ៉ូហាន ១១)។ គឺមានព្រះ២ អង្គ គឺព្រះវរបិតា និងព្រះរាជបុត្រា។ ព្រះបន្ទូលមិនមែនជាព្រះយេស៊ូទេ។ ព្រះបន្ទូលគឺជាព្រះ។ ទោះបីយ៉ាងណាក៏ដោយ ព្រះយេស៊ូ គឺជាព្រះបន្ទូលរបស់ព្រះដែលលេចមកក្នុងសាច់ឈាម។ ព្រះយេស៊ូ មិនមែនគង់នៅជាមួយនឹងព្រះ ពីកាលដើមដំបូងទេ ហើយព្រះបន្ទូលទេ (ដែលបានលេចមកក្នុងមនុស្សយេស៊ូ) គឺជាព្រះ។ ហើយព្រះបន្ទូល គឺជា *"សែនតែ១"* (ពូជ) គឺបានចេញមកពីព្រះសំដែងផ្ទាល់។ ព្រះបន្ទូលមានការចាប់ផ្តើម ប៉ុន្តែព្រះបន្ទូលបានមកពីព្រះវិញ្ញាណអស់កល្ប ព្រះបន្ទូលមាននមក គឺជាអស់កល្ប ពីព្រោះ ព្រះបន្ទូល គឺជាព្រះ ប៉ុន្តែ មនុស្សយេស៊ូ គឺជាព្រះបុត្រាតី១គត់ គឺមិនមែនអស់កល្បទេ។

ព្រះបន្ទូល គឺជាគំរូរូបភាពពោរពេញរបស់ព្រះគ្រីស្ទ ដែលបានចេញមកពីគំនិតរបស់ព្រះ**ដើម្បីសំដែងពីទ្រង់ ជាព្រះដ៏ជាកំពូលអស់កល្ប។ កាលដើមដំបូង ព្រះវិញ្ញាណដ៏មានព្រះចេស្តាបំផុត** ព្រះដ៏មើលមិនឃើញ ហើយរូបកាយព្រះបន្ទូល មើលឃើញ (ពាក្យក្រិកៈ *ឡូហ្គុស*)ហើយមិនមែនព្រះបិតា និងព្រះបុត្រាទេ។

បើអ្នកគ្មានការបើកសំដែងទេនោះអ្នកគ្រាន់តែគិតថាព្រះបន្ទូល *(ឡូហ្គុស)* គឺជាព្រះយេស៊ូ ជាព្រះរាជបុត្រានៃព្រះ នៅកាលដើមដំបូង។ ប៉ុន្តែព្រះយេស៊ូ ដែលជា ព្រះបន្ទូលនៃព្រះ (រោងឧបោសថ និងបានលេចមក) ក្នុងសាច់ឈាម (ប្រហែល ២០០០ ឆ្នាំមកហើយ) គឺបានបង្ហាញចេញពេលនោះហើយ នៅក្នុងឡូហ្គុស។ ពីព្រោះលក្ខណៈ របស់ព្រះវរបិតា នៅក្នុងព្រះ**ត្រូវតែមានព្រះបុត្រា។ ហើយឡូហ្គុសនៃព្រះ បានមកក្នុងវិញ្ញាណជាព្រះបុត្រា បង្ហាញចេញជាព្រះរាជបុត្រានៃព្រះ** ដែលត្រូវតែយាងមក។ (សូមចាំ បុត្រា កើតមក ហើយក៏យកត្រកូលនៃគ្រួសារ)។ ហេតុនេះ វិញ្ញាណព្រះរាជបុត្រា គឺជាព្រះយេស៊ូគ្រីស្ទ នៅក្នុងផ្នែកឡូហ្គុស បាននាំចេញមកពីព្រះ ក៏ជាលក្ខណៈរបស់ព្រះដែរ។ ព្រះយេស៊ូ គឺជាពូជតែ១គត់ (ពូជព្រះបុត្រា) នៃព្រះ ដែលបានបង្ហាញនូវរូបកាយ-ព្រះបន្ទូល។ ទ្រង់គឺជាវិញ្ញាណ និងព្រលឹងរបស់ព្រះ ។ ក្រោយមក ឡូហ្គុស មកក្នុងរោងឧបោសថ គឺព្រះយេស៊ូ ជាព្រះរាជបុត្រានៃព្រះ គឺជាបុត្រា និយាយតាមរូបភាពបន្តៗមក ។ តាមតែព្រះសព្វព្រះហឫទ័យ ព្រះបានដំកើងទ្រង់ ជាព្រះរាជបុត្រានៃព្រះ នៅក្នុងព្រះបន្ទូល (យ៉ូហាន ១៧៥ )។ ហើយព្រះបានឆ្កាងសំលាប់ទ្រង់ដូចជាចៀម ពីមុនកំណើតលោកីយ៍ (វិវរណៈ ១៣:៨)។ អេឡូហ៊ីម មានព្រះហឫទ័យ នឹងព្រឹក្សាដោយអង្គទ្រង់ផ្ទាល់ (អេភេសូរ ១:១១) ហើយនិយាយពីរបស់ ដែលមិនទាន់មាន ចាត់ទុកថា មានហើយ (រ៉ូម ៤: ១៧)។ នេះជាតម្លៃសងថ្លៃលោះរបស់ព្រះ យើងត្រូវបានរើសទុកមកហើយ ហើយបានសំអាត នៅក្នុងព្រះគ្រីស្ទពីមុនកំណើតលោកីយ៍ ព្រះបានឃើញយើងនៅក្នុងសេចក្តីស្រលាញ់ (អេភេសូរ ១:៤) ។យើងជាផ្នែក (ភាពជាកូន) នៃព្រះបន្ទូលនោះ ពីព្រោះយើងជាផ្នែកនៃរូបកាយព្រះគ្រីស្ទ ។ យើងជា *"ពូជជាច្រើន"* បង្កើតចេញពី *"សែនតែ១"* (ពូជ) គឺបាននិយាយនៅក្នុងសញ្ញាចាស់ ហើយបានសំរេចនៅក្នុងសញ្ញាថ្មី តាមផែនការដ៏ធំរបស់ព្រះ ។ ពីព្រោះយើងបានទៅជាភាពជាកូនខាងវិញ្ញាណ ហើយយើងបានកើតខាងសាច់ឈាម (មនុស្សលោក) និងត្រូវកើតជាថ្មីម្តងទៀត ជាកូនប្រុសស្រីរបស់ព្រះ។ លើសពីនេះទៅទៀត យើងបានដំកើងឡើងនិងខ្ជាប់ខ្ជួនក្នុងគំនិតរបស់ព្រះ និងព្រះបន្ទូលនៃព្រះ (រ៉ូម ៨២៩៣០) ។ មែនហើយ ដោយសារទ្រង់ស្គាល់ជាមុន និងបានដំរូវទុក ហើយបានតាំងឡើងក្នុងផែនការការប្រោសលោះរបស់ទ្រង់។ សូម្បីតែ ឈ្មោះកូនប្រុសស្រីរបស់ព្រះបានសរសេរទុកក្នុងបញ្ជីជីវិតនៃកូនចៀម ពីមុនកំណើតលោកីយ៍ (វិវរណៈ ១៣:៨)។

ដំបូង អ័ដាមដែលបានកើតខាងវិញ្ញាណ មិនទាន់ជាកូនព្រះនៅឡើយ ។ ហេតុដល់ពេលគាត់មានរូបកាយជាសាច់ឈាមកើតនៅក្នុងលោកីយ៍នេះ ទើបគាត់អាចជាកូនព្រះ។ ក្នុងទំរង់ ខាងវិញ្ញាណ គាត់មានលក្ខណៈនៃភាពជាកូនប៉ុណ្ណោះ។ អ្នកជឿគម្ពីរខ្លះជឿថា ដូចជាអ័ដាមដែរ មនុស្សទាំងអស់

ឡូហ្គុស: ការចាប់ផ្តើមដំបូងនៃការបង្កើតរបស់ព្រះ

(ឬគ្រាន់តែជាពូកកូនប្រុសស្រីពិតរបស់ព្រះ) ត្រូវបានបង្កើតហើយ ហើយបានមាននៅជាវិញ្ញាណ ពីមុនពួកកេកើតទៀត ។ ខ គម្ពីរ ដែលគេចូលចិត្តសំរាប់គាំទ្រគំនិតនេះ គឺយ៉ូប ៣៨:៤-៧ *"តើឯងនៅឯណាក្នុងកាលដែលអញចាប់តាំងបង្កផែនដីឡើង?.....ក្នុងកាលដែលផ្កាយព្រឹកបានច្រៀងជាមួយគ្នា ហើយអស់ទាំងកូនព្រះ បានស្រែកអរសាទរ?"* តើពួកគេចង់មានន័យថា វិញ្ញាណនៃមនុស្សផ្សេងទៀត ទាំងអស់(ឬអស់ទាំងពួកកូនព្រះ)ត្រូវបានបង្កើតរួចទៅហើយ ជាមួយវិញ្ញាណអ័ដាម ពីមុនផែនដីកើតមកឬអី? ហើយមុនផែនដីមានមកវិញ្ញាណរបស់អេវ៉ាមានមកក្នុងចំណោមវិញ្ញាណស្រី ឬ នាងជាផ្នែករបស់អ័ដាមជាវិញ្ញាណ?

កូនទាំងអស់របស់ព្រះ *"(រួមទាំងកូនស្រី) បានមានឡើងតែ១គត់ក្នុងគំនិតរបស់ព្រះដ៏មានព្រះចេស្តាបំផុត"*។ ពួកគេបានជាផ្នែករបស់ឡូហ្គុស ជាពូជជាច្រើន (កូនរបស់ព្រះ) ដែលបានចេញមកដោយសារតែពូជតែ១គត់ (ព្រះរាជបុត្រានៃព្រះ)។ ពេលដែលទ្រង់ប្រគល់ជីវិត របស់ទ្រង់នៅលើផែនដី (យ៉ូហាន ១២២៤) ។ពូជជាច្រើនបាននៅជាមួយពូជតែ១គត់(ឧ ពូជស្វាយជាច្រើន បានកើតមកដោយសារមានពូជតែ១) គឺវាមិនមែនកើតមកមានលក្ខណៈជាវិញ្ញាណទេ។ "ពួកកូនព្រះ" បាននៅក្នុងឡូហ្គុស។

យើងបានដឹងហើយថា ព្រះជាអ្នកបង្កើត ប៉ុន្តែទ្រង់មិនមែនជាអ្នកបង្កើតទេ ទាល់តែមានរបស់បានបង្កើតមក នៅក្នុងគំនិតរបស់ព្រះតែ១គត់។ ទ្រង់ត្រូវបង្កើតចេញហើយបង្ហាញចេញក្នុងរបស់អ្វីៗ ដែលទ្រង់បង្កើត ហើយទ្រង់បានហៅថា ជាអ្នកបង្កើត។ យើងដឹងថា ទ្រង់ជាអ្នកសង្គ្រោះយើង ប៉ុន្តែបើគ្មានមានអ្នកបាបណា១ ដើម្បីឲ្យទ្រង់សង្គ្រោះទេ នោះទ្រង់មិនអាចជាអ្នកសង្គ្រោះរបស់យើងទេ។

ទំនាក់ទំនងរវាងបិតា-កូនរវាង ព្រះ និងអ័ដាម ត្រូវតែបាននិយាយចេញហើយលេច ចេញមក។ ដំបូង អ័ដាមបានកើតមកជាវិញ្ញាណ(ប្រុសនិងស្រី) គាត់មិនដូចជាឡូហ្គុស គឺជារូបកាយព្រះបន្ទូលនៃទ្រង់។ ទ្រង់ចេញមកពីព្រះដែលបានបង្កើត ដោយសារព្រះបន្ទូលផ្ទាល់។ អ័ដាម គ្រាន់តែជាផ្នែកនៃរូបកាយព្រះបន្ទូលទេ។ លក្ខណៈនៃភាពជាកូនរបស់អ័ដាមបាននៅក្នុង**វិញ្ញាណនៃអ័ដាម ប៉ុន្តែត្រូវតែលេចចេញមកឲ្យឃើញជាបុគ្គល** (ជាមនុស្សលោក) មុននឹងអាចហៅថាជាកូនពិតព្រះ។ អ័ដាមត្រូវតែមានរូបកាយចេញពីធូលីណានៅលើផែនដីនេះ។ (តើអ្វីជាបុគ្គល? មើលចំនុច **បុគ្គល នឹងបុគ្គលិកលក្ខណៈ**)។ បន្ទាប់ពីរូបកាយធូលីដីបានមានរូបរាងហើយ។ ព្រះបានយកវិញ្ញាណអ័ដាមទៅក្នុងរូបកាយពីធូលីដី ហើយអ័ដាមក៏បានទៅជាមានព្រលឹងរស់ឡើង ជាបុគ្គល (ជាមនុស្សលោក) ជាមួយនឹងជីវិត ជាអំណាចនៃអ្នកបង្កើតរបស់គាត់

(លោកុប្បត្តិ ២:៧)។ អ័ដាមត្រូវបានបង្ហាញ ពីជីវិតរបស់ព្រះនៅក្នុងគាត់។ ( ព្រលឹងរស់ឡើង គឺជាការលេចមកនៃវិញ្ញាណ )។ ទោះបីតែអ័ដាមជាកូនរបស់ព្រះ ការស្គាល់នៃទំនាក់ទំនងរបស់ព្រះបិតា-កូន មិនបានបង្ហាញនៅក្នុងសញ្ញាណចាស់។ ការទំនាក់ទំនងរវាងព្រះជាមួយនឹងអ័ដាម នឹងអ៊ីស្រាអែល គឺជា**ទំនាក់ទំនង-បំរើចៅហ្វាយ**។ ការបើកសំដែង នៃទំនាក់ទំនងព្រះបិតា-បុត្រា បានមក បន្ទាប់ពីព្រះយេស៊ូបានចាត់មកជាព្រះរាជបុត្រាប៉ុណ្ណោះ ហើយបានទៅជាអ្នកសងថ្លៃលោះបាបយើង (១ យ៉ូហាន ៤:១០)។

គំនិតខាងវិញ្ញាណរបស់អ័ដាមគឺជាការសំដែងចេញពីវិញ្ញាណនៃព្រះដ៏មានព្រះចេស្តាបំផុតដូច្នេះហើយ វាគឺជាផ្នែកនៃរូបអង្គនៃព្រះ។ វិញ្ញាណ(ភាពជាកូន) នៃអ័ដាមមានទាំងប្រុសទាំងស្រី។ ហើយបើអ័ដាមនៅក្នុងទំរង់នោះនៅឡើយ គាត់មិនអាចលេចមកជាកូននៃព្រះបានទេ។ គឺបានលេចមកបន្ទាប់ពីអ័ដាមក្លាយជាបុគ្គល ជាមនុស្សប៉ុណ្ណោះ។ បន្ទាប់មក ផ្នែកស្ត្រី ត្រូវបានដកចេញពីចំហៀងរបស់គាត់ដើម្បីបង្កើតជាស្ត្រី។ ដូចគ្នាដែរ ពេលដែលព្រះបន្ទូលបានបង្កើត ចេញក្នុងបុគ្គលនៃព្រស៊ូគ្រីស្ទ យើងឃើញការបង្ហាញចេញទាំងប្រុសទាំងស្រី ។ ព្រះគ្រីស្ទ គឺជាប្រុស *"កូនកំលោះ"* ហើយពួកជំនុំជាស្រី *"កូនក្រមុំ"* ដែលបានដកចេញមកពី ចំហៀងរបស់ទ្រង់នៅភ្នំ កាល់វ៉ារី

ទេវតាគ្មានវិញ្ញាំភាពជាកូនទេ ទោះជាពួកគេត្រូវបានបង្កើតមកក្នុងរូបអង្គនៃព្រះ (ជាវិញ្ញាណក្នុងទំរង់) និងភាពដូច (លក្ខណៈពិសេសដែលអាចមើលឃើញ) ក៏ដោយ។ ពួកគេមិនអាចកើតជាមនុស្សបានទេ។ ពួកគេមិនអាចជាបុគ្គលទេ ពួកគេមិនអាចជាបុគ្គលទេ ទោះបីជាពួកគេអាចលេចមក (អេន ម៉រហ្វី) ដូចជាមនុស្សក៏ដោយ។ ពួកគេមិនអាចជាកូនព្រះទេ។ ពួកគេ ត្រូវបានបង្កើតមកយ៉ាងសាមញ្ញ និងបានតាំងឡើងជាវិញ្ញាណបំរើប៉ុណ្ណោះ។

អ្នកនាំព្រះរាជសារ-ហោរា វីល្លាម ប្រាណ បាននិយាយថាៈ

*"ព្រះអស់កល្បដ៏ធំចាប់ផ្តើមទំរង់អង្គទ្រង់ឆ្ពោះទៅសាច់ឈាម ក្នុង ទីអូហ្វានី (រូបកាយមិនចេះស្លាប់ ) ហៅថា ព្រះបន្ទូល ជារូបកាយ១។ អញ្ចឹង នេះជាអ្វី ដែលទ្រង់បានគង់ក្នុង នៅពេលដែលទ្រង់បានជួបអ័ប្រាហាំៈ ទ្រង់ហៅថាម៉ិលគីស្សាដែក ។ទ្រង់បានគង់នៅក្នុងទំរង់នៃទីអូហ្វានី"*។

*"វិញ្ញាណដ៏ធំអស្ចារ្យនេះ បានចាប់ផ្តើមរូបរាង (ក្នុងរបស់ដែលបានកើតឡើង) គឺ ឡូហ្គុសបាននាំចេញមកនូវព្រះបន្ទូល គឺជាព្រះរាជបុត្រានៃព្រះ។ គឺជារូបរាងទីអូហ្វានី មានន័យថា ជារូបកាយហើយរូបកាយនេះដូចជាមនុស្ស"*

*"ឥឡូវនេះ គ្មាននរណាបានឃើញព្រះវរបិតាសោះឡើយ។ គ្មាននរណាអាចឃើញព្រះ ពីព្រោះព្រះមិនមែនជាទំរង់រូបកាយ។ ព្រះជាវិញ្ញាណ បន្ទាប់មក ក្រោយមកខ្ញុំចាប់ផ្តើមឃើញពន្លឺពិសិដ្ឋម្តងបន្តិចៗ ដែលចាប់ផ្តើមមានរូបរាង ដូចជាបង្គោលភ្លើង ឬអ្វី១ ។ អ្នកគ្រាន់អាចឃើញដោយភ្នែកខាងវិញ្ញាណ*

ឡូហ្គុស: ការចាប់ផ្តើមដំបូងនៃការបង្កើតរបស់ព្រះ

*តើនោះគឺជាអ្វី? នោះហៅថា តាមអ្នកអានក្នុងគម្ពីរ ជាឡូហ្គុស ឬ "ម្នាក់មានប្រេងតាំង" ឬ "អ្នកកំពុងតែមានប្រេងតាំង ផ្នែករបស់ព្រះបានចាប់ផ្តើមវិត្តក្នុងអ្វីៗ ដូចជាមនុស្សមានមក បានទៅជាផ្នែកនៃគំនិតនៅក្នុងព្រះបន្ទូល។ នោះហើយគឺជាព្រះបន្ទូលនៃព្រះ"។*

ព្រះគឺជា*វិញ្ញាណ* ទ្រង់ហើយជាអញ្ចឹងមែន។ តាមព្រះបន្ទូល ព្រះបន្ទូលជាព្រះ តែទាំងអស់របស់ព្រះមិនមែនជាព្រះបន្ទូលទេ។ ទ្រឹស្តីទេវវិទូ ពួកគេនិយាយថា ព្រះវិញ្ញាណ គឺជា**អេឡូហ៊ីម** ជាផ្នែកដ៏ធំ ក្នុងព្រះបន្ទូលរបស់ទ្រង់ក៏ជាផ្នែកតូចជាង (បន្តមក បានចេញពីទំរង់ពីមុន)។នេះជាផ្នែកតូចជាងគេដែលអាចមើលឃើញខាងឯព្រះ (បានហៅថា ព្រះបន្ទូល) បានមកជាមនុស្ស។ ហេតុនេះ ព្រះបន្ទូល គឺជាព្រះអម្ចាស់ ដែលចេញពីស្ថានសួគ៌មក (១កូរិថូស ១៥:៤៧ , យ៉ូហាន ៣:១៣)។ ហើយព្រះបន្ទូលបានលេចចេញមកក្នុងបុគ្គលនៃព្រះយេស៊ូគ្រីស្ទ។

**ការគិត និងការសំដែងចេញរបស់ព្រះ-គឺព្រះបន្ទូល-ចេញមកពីទ្រង់ ក្នុងរូបកាយ-ខាងវិញ្ញាណ ជាការចាប់ផ្តើមនៃការបង្កើតរបស់ព្រះ ( អ្នកចាប់ផ្តើម ឬម្ចាស់នៃការបង្កើតនៃព្រះ) ជាបងច្បងក្នុងរបស់ ដែលកើតឡើង ហើយនិងបងច្បងបានកើតឡើងក្នុងចំណោមបងប្អូន។**មានមកដោយសារព្រះបន្ទូល របស់អ្វីៗទាំងអស់របស់ព្រះ បានមានឡើង។

*"ដ្បិតគឺទ្រង់ហើយ ដែលបង្កើតគ្រប់ទាំងអស់ ទាំងរបស់នៅស្ថានសួគ៌ និងនៅផែនដី ទាំងរបស់ដែលមើលឃើញ ហើយ ដែលមើលមិនឃើញផង ទោះបីជារាជ ឬអំណាចជាព្រះអម្ចាស់ឬអំណាចគ្រប់គ្រង ឬអំណាចណាក៏ដោយ នោះសុទ្ធតែកើតមកដោយសារទ្រង់ ហើយសំរាប់ទ្រង់ទាំងអស់។ ទ្រង់គង់នៅមុនទាំងអស់ ហើយរបស់ទាំងអស់ក៏នៅ ស្ថិតស្ថេរដោយសារទ្រង់"* (កូល៉ុស ១:១៦-១៧)

*"ហើយឲ្យខ្ញុំបានបំភ្លឺដល់គ្រប់មនុស្សទាំងអស់ ពីសេចក្តីប្រកបក្នុងការអាថ៌កំបាំង ដែលលាក់ទុកក្នុងព្រះ តាំងពីអស់កល្បរៀងខ្លួនមក ជាព្រះដែលទ្រង់បង្កើតរបស់សព្វសារពើ (ដោយសារព្រះយេស៊ូគ្រីស្ទ)"* អេភេសូរ ៣៩ ឃ្លាក្នុងវង់ក្រចក មិនមែនមានពីរដើមទេ។

**ព្រះបន្ទូល**នៃព្រះ បានមកជារូបកាយ-ព្រះបន្ទូល។ ព្រះបានមានបន្ទូលទៅទ្រង់ ហើយនិយាយថា *"ចូរឲ្យមានពន្លឺឡើង"* ហើយពន្លឺក៏មានឡើង *"ចូរឲ្យមានត្រីឡើង"* ត្រីក៏បានមានឡើង។ ទ្រង់គឺជា**មនុស្សមានបន្ទូល**របស់ព្រះ។ ហើយតាមរយៈ**ព្រះបន្ទូល**នៃប្រះ ឬ(វិញ្ញាណ) រូបកាយ គឺជាព្រះវិញ្ញាណនៃព្រះ *"អេន ម៉ហ្វី"* ទ្រង់ផ្ទាល់បានក្លាយទៅជាមើលឃើញទៅដល់ពួកបាវបំរើរបស់ទ្រង់ គឺពួកហោរា។ យើងបានហៅថា **ទីអូហ្វានី** ដែលសំដែងឲ្យឃើញ ។

# ទីអូហ្វានី

ឥឡូវនេះ បានចេញមកជា ឡូហ្កុស (មកពីព្រះ) ដើម្បីសំដែងបំណងព្រះហឫទ័យនៃព្រះបានសំដែងក្នុងរូបរាងជាមនុស្ស។ ឡូហ្កុស បានសំដែងជារូបកាយខាងវិញ្ញាណ (បានហៅថា ជា ព្រះបន្ទូល)។ ពេលណា ដែលឡូហ្កុសបានចេញពីព្រះមក ទ្រង់ត្រូវតែវិញទៅឯព្រះវិញ បន្ទាប់ពីបញ្ចប់បេសកកម្មរបស់ព្រះរួច។ ទ្រង់បានលេចមក ដូចជាមនុស្ស ឬ នៅក្នុងមនុស្ស ដែលអាចមើលឃើញ (មើលឃើញ) មិនមែនជារូបកាយប៉ះមិនកើត។ គ្រប់ពេល រូបកាយទីអូហ្វានី បានលេចមកឲ្យឃើញជាគំរូនៃព្រះគ្រីស្ទ ហើយគ្រាន់តែបណ្ដោះអាសន្នឲ្យទៅកន្លែងនីមួយៗ។ យើងក៏បានអាចថា ទ្រង់ជាម៉ិលគីស្សាដែក សង្ឃដ៏ខ្ពស់បំផុតរបស់ព្រះម្ដងមកហើយ។ បន្ទាប់មក ទ្រង់ជាចៅក្រម អ្នកសង្គ្រោះរបស់ពួកអ៊ីស្រាអែល ហើយមកត ទ្រង់ជាមិត្តសំលាញ់របស់អ័ប្រាហាំ ដែលទ្រង់បានរួមអាហារជាមួយនឹងគាត់។

អ័ប្រាហាំបានដឹងថា ម៉ិលគីស្សាដែក បានឲ្យពរទៅគាត់ ពីព្រោះ ជាសង្ឃដ៏ខ្ពស់បំផុតរបស់ព្រះ ហើយគាត់ថ្វាយដង្វាយ ១ភាគ១០ ពីរបស់ដែលគាត់មាន (លោកុប្បត្តិ ១៤:១៧-២០)។ គាត់បានដឹងថា ទ្រង់គឺជាព្រះបន្ទូលនេះហើយ ។ម៉ិលគីស្សាដែក មិនមែនជាអង្គយេស៊ូទេ ប៉ុន្តែជារូបគំរូនៃព្រះគ្រីស្ទនៅក្នុងការងារសង្ឃដ៏ខ្ពស់បំផុតរបស់ព្រះ។ លោកប៉ូល បាននិយាយថាម៉ិលគីស្សាដែក "គ្មានបិតា គ្មានមាតា គ្មានកូនចៅ គ្មានថ្ងៃកើត ឬថ្ងៃស្លាប់ដែរ" (ហេព្រើរ ៧:៣)។ ប៉ុន្តែមិនបានដូចអញ្ចឹងទេ ចំពោះព្រះយេស៊ូគ្រីស្ទ ទ្រង់បានកើតមកជារូបកាយ ដែលមានធាតុនៃផែនដី ហើយមាន "ម្ដាយ" គឺនាងព្រហ្មចារីម៉ារី ។ ដូច្នេះ ម៉ិលគីស្សាដែក អាចគ្រាន់តែជាផ្នែកមើលឃើញនៃព្រះ ជាព្រះបន្ទូល គឺការគិតរបស់ព្រះបានសំដែងចេញ ដែលលេចមកឲ្យអ័ប្រាហាំឃើញ។ តាំងពីព្រះបន្ទូលជាព្រះ លោកប៉ូលអាចនិយាយចំៗថា ម៉ិលគីស្សាដែក "គ្មានមាតា"។ ការពិត ការទំនាក់ទំនងព្រះបិតា-បុត្រា រវាងព្រះ និងព្រះបន្ទូលមិនបានមានទេ។

ក្រោយមកត ពេលរស់នៅស្រុកម៉ាមរេ មានមនុស្ស៣នាក់ បានមកលេងអ័ប្រាហាំ។ ២នាក់គឺជាវិញ្ញាណទេវតាមើលមិនឃើញ (ជាពួកទេវតា) ដែលមាន អេន ម៉ហ្វើ ដើម្បីឲ្យពួកគេអាចមកទៅជាមនុស្សមើលមិនឃើញបាន រូបកាយនេះបានកើតមក មានធាតុនៃផែនដី។ អ័ប្រាហាំបាន ស្គាល់មនុស្សទី៣ហៅទ្រង់ថា **ព្រះអម្ចាស់។ ព្រះបន្ទូលនៃព្រះអម្ចាស់** បានមកឲ្យឃើញម្ដងទៀតហើយ (ទីអូហ្វានី) ដើម្បីមកប្រកប និងទទួលអាហារជាមួយអ័ប្រាហាំ (មើលលោកុប្បត្តិ១៨)។ គឺជាមនុស្សដដែល ជាទេវតា (អ្នកនាំព្រះរាជសារ) របស់

ឡូហ្គុស: ការចាប់ផ្តើមដំបូងនៃការបង្កើតរបស់ព្រះ

ព្រះអម្ចាស់ ដែលបានលេចមកនៅពេលផ្សេងៗទៀត ដែលបានស្លៀកពាក់ខុសពីគ្នា ទៅដល់ពួកហោរាឯទៀតៗ ហើយអ្នកបំរើរបស់ព្រះអម្ចាស់ នៅសម័យរបស់ពួកគេ។ លក្ខណៈរបស់ព្រះ គឺជាអ្នកសង្គ្រោះ អ្នកការពារ អ្នកទូលអង្វរ មិត្តសម្លាញ់ ចៅក្រម អ្នកជំនួយ។ល។

ឥឡូវនេះ មនុស្សនេះបានឃើញដោយពួកបរិសុទ្ធរបស់ព្រះ មានរូបរាងដែលមានព្រះភក្ត្រដដែល។ ព្រះភក្ត្រនោះ គឺជាព្រះភក្ត្ររបស់ព្រះយេស៊ូគ្រីស្ទ គឺមានព្រះភក្ត្ររបស់ព្រះតែ១គត់គឺជាព្រះអម្ចាស់នៃស្ថានសួគ៌។ ឡូហ្គុស អាចលេចមកក្នុងព្រះភក្ត្រនោះប៉ុណ្ណោះ ពីព្រោះព្រះត្រូវតែបង្ហាញចេញ "ព្រះរាជបុត្រា" របស់ទ្រង់ ដែលត្រូវយាងមកសំរេចគ្រប់ទាំងអស់ ដែលបានថ្លែងទុកពីទ្រង់ ។ ព្រះយេស៊ូបានមានបន្ទូលទៅពួកយូដាថា "*លោកអ័ប្រាហាំ ជាព្ធយុកោអ្នករាល់គ្នា លោកបានត្រេចអរដោយឃើញគ្រាខ្ញុំ លោកក៏បានឃើញមែន ហើយមានសេចក្តីរីករាយ*" ( យ៉ូហាន៨៥៦ )។ **ហេតុនេះ ព្រះយេស៊ូ គឺជាវិញ្ញាណនៃភាពជាកូននោះបានលេចមកក្នុងឡូហ្គុស នសព្រះ ដែលត្រូវតែកើតមកក្នុងលោកីយ៍នេះ ជាព្រះរាជបុត្រាតែ១គត់នៃព្រះដើម្បីមកសំរេចលក្ខណៈផ្សេងៗរបស់ព្រះ ដែលបានបង្ហាញដល់ពួកមនុស្សបរិសុទ្ធទាំងនោះ។**

## ការបើកសំដែងផ្ទាល់ ដែលអាចបង្កើតអ្វីៗបាន របស់ទ្រង់

ឥឡូវនេះយើងបានយល់ថា *ព្រះបន្ទូល* នៃព្រះ (ពាក្យក្រិតះ *ឡូហ្គុស* ពាក្យហេព្រើរគឺ *ដេបារ*) គឺច្រើនលើសពីការបន្លឺសំលេងចេញតាមមាត់ទៀត វាជា ***ការបើកសំដែងផ្ទាល់ ដែលអាចបង្កើតអ្វីៗបាន របស់ទ្រង់ "ជាផ្នែកនៃព្រះដែលបានបែរមកឯមនុស្សលោក"។*** យើងក៏យល់តាមរយៈ ការបង្ហាញ របស់អ្នកបរិសុទ្ធ យ៉ូហានថា ឡូហ្គុស មិនមែនជាគោលណ៍ការបង្កើត អបុគ្គលិកខ្វាក់ ឬ កំលាំងជីវិតទេ ប៉ុន្តែ គឺជា*ការសំដែងផ្ទាល់នៃព្រះដ៏មានព្រះជន្មរស់*នៅក្នុងព្រះយេស៊ូគ្រីស្ទ។ ព្រះយេស៊ូ គឺជាតំណាងនៃ*ឡូហ្គុស*របស់ព្រះ ជាការសំដែងនៃ**ពន្លឺពីព្រះ ជីវិត សិរិល្អ និងសេចក្តីពិត** នៅក្នុងបុគ្គលិកលក្ខណៈជាមនុស្ស ( យ៉ូហាន ១:៤.៩ សូមមើល យ៉ូហាន ១:១-៤ )។

ដូចជាខ្ញុំបាន និយាយហើយថា ព្រះបន្ទូលមិនមែនជាព្រះយេស៊ូទេ។ ហើយតាមយ៉ូហានព្រះបន្ទូលគឺជាព្រះ។ ព្រះយេស៊ូ "*ដែលជារូបអង្គនៃព្រះដ៏មើលមិនឃើញ*" គឺជាព្រះបន្ទូល ដែលសំដែងចេញ។ ទ្រង់គឺជាការបើកសំដែងនៃព្រះ។ **ព្រះយេស៊ូ គឺជាគ្រឹះអ្វី ដែលព្រះបន្ទូលមាន។ ទ្រង់ជាព្រះគ្រីស្ទ ជាការបើកសំដែងនៃព្រះ ដែលបានសំដែងដល់ពួកបរិសុទ្ធ។** ទ្រង់ជា*ពូជ* របស់ព្រះ ជា *ពូជ(សែន)តែ១* របស់ព្រះ ជាបុត្រា**តែ១**របស់ព្រះ ដែលបាននៅក្នុងព្រះឱរាព្រះវរបិតា ដែលបានសំដែង នៅក្នុង*ឡូហ្គុស* ទូទាំងសញ្ញាចាស់ ។

**ដោយសារព្រះយេស៊ូគ្រីស្ទ គឺជារូបគំរូ ក្នុងសញ្ញាចាស់ ដូច្នេះទ្រង់បានលេចមក និងសំដែង នៅក្នុងសញ្ញាថ្មី។ នៅក្នុងសញ្ញាចាស់ទ្រង់គឺជាវិញ្ញាណ "ភាពជាកូន" ដែលមានខាងក្នុងឡូហ្គុស បានសំដែងចេញនៅក្នុងសញ្ញាថ្មី ទ្រង់គឺជាព្រះរាជបុត្រានៃព្រះគឺជាឡូហ្គុស មកគង់នៅក្នុង។ នៅក្នុងសញ្ញាចាស់ (រូបកាយខាងវិញ្ញាណ) និងសញ្ញាថ្មី (រូបកាយមនុស្ស) ឡូហ្គុស នៃព្រះមានព្រះភក្ត្រតែ១គត់ គឺជាព្រះភក្ត្ររបស់ព្រះយេស៊ូគ្រីស្ទ។** (១យ៉ូហាន ៤:២-៣)

*ព្រះបន្ទូល* មិនមែនជា *ព្រះវិញ្ញាណដ៏មានព្រះចេស្តាបំផុត* ១ទៀត ឬ*ព្រះ* ១ទៀតទេ។ ក្នុងការប្រឹក្សាដោយអង្គទ្រង់ផ្ទាល់ ព្រះជាវិញ្ញាណដ៏មានព្រះចេស្តាបំផុតពិតតែ១ បានមានបំណងនៅក្នុងព្រះអង្គទ្រង់ ដើម្បីបង្កើតពួកកូនៗ(នៃព្រះ) មកឯព្រះអង្គទ្រង់។ ដូច្នេះហើយ ត្រូវតែមាន **ព្រះបន្ទូល-ពូជ** ដើម្បីបង្កើត នឹងនាំចេញឲ្យជីវិតមានឡើង។ *រូបកាយព្រះបន្ទូល* គឺជាបណ្តាញដែលព្រះលេចមក និងសំដែងអង្គទ្រង់។ **ព្រះវិញ្ញាណនៃព្រះនិងព្រះបន្ទូល គឺតែ១ទេ**នេះគឺជាការរួបរួមផ្គួបនៃព្រះដ៏ជាកំពូល គឺជា**អេឡូហ៊ីម។** យើងដឹងថាពូជ១នឹងនាំចេញទៅជាប្រភេទផ្ទាល់របស់វា។ នោះជាច្បាប់ (លោកុ ១១-១២ , ២១,២៤-២៥)។ ឧ ពូជផ្លែប៉ោម នៅពេលយកទៅដាំ នឹងនាំចេញជាដើមប៉ោម ដែលនឹងបង្កើតផ្លែប៉ោមដែលមានពូជផ្លែប៉ោមនៅក្នុងវានោះ។ ហើយពូជផ្លែនោះ (ដែលបានចូលទៅក្នុងដី) បានមានដើមកំណើតនៅក្នុងផ្លែប៉ោម (មេបា)របស់វា។ ដូច្នេះ តាមគំរូនេះ យើងយល់ថា ***ព្រះបន្ទូលគឺជាសែនតែ១(ពូជ) នៃព្រះហើយវាជាព្រះហើយ-ដ្បិតអ្វីដែលកើតពីវិញ្ញាណ គឺជាវិញ្ញាណ***

## គ្មានពូជ, គ្មានជីវិត

ពេលដែលយើងយកពូជផ្លែប៉ោមធ្វើឲ្យវាដុះឡើង ត្រូវតែយកទៅដាំសិន វានឹងផុសឡើងជាពន្លក សន្លឹក ដើម ហើយមែក ហើយដុះតទៅទៀត។ បន្ទាប់មក មានផ្កាលេចចេញមក ក៏បាត់ទៅវិញទៅ។ ក្តីបវា ក៏ចាប់ធំឡើងម្តងបន្តិចៗ បានទៅជាផ្លែប៉ោម គឺមានផ្នែកដូចជាពូជបានដាំពីដើម។ ពូជបានចាប់ផ្តើមបង្កើតឡើង តាមការលេចមកផ្សេងពីគ្នាក្នុងដំណាក់កាល ចូលទៅដល់ទីបញ្ចប់ លេចឡើងជាពូជទៀតហើយ។ ដូច្នេះ យើងយល់ថា ឡូហ្គុស **ជាពូជរបស់ព្រះគឺបានចាប់ផ្តើមពីការបង្កើតរបស់ព្រះ** ក៏បានលេចមកក្នុងព្ទយុកោរបស់យើង និងហោរា ក្នុងពេលខុសពីគ្នាជាច្រើនបែបច្រើនសារមកហើយ "នៅថ្ងៃចុងក្រោយ" (ហេព្រើរ ១:២) បានបង្ហាញតាមព្រះរាជបុត្រាតែ១គត់ (ពូជ(សែន)តែ១គត់របស់ព្រះវរបិតា)។ គ្រប់ទាំងអស់នៅក្នុងឡូហ្គុសរបស់ព្រះ ក៏បាននៅក្នុងព្រះរាជបុត្រា។ ដូច្នេះហើយព្រះយេស៊ូ គឺជាព្រះបន្ទូល (ឡូហ្គុស)របស់ព្រះ។ ទ្រង់ហើយជាការបើកសំដែងរបស់ព្រះ ដល់មនុស្សលោក (១ ពេត្រុស ១:២៣-២៥)។

ឡូហ្គុស: ការចាប់ផ្តើមដំបូងនៃការបង្កើតរបស់ព្រះ

ដោយ ឡូហ្គុស គឺជាពូជតែ១គត់ (សែនតែ១គត់) របស់ព្រះ គឺព្រះបាននាំចេញពីឧរា បានបង្ហាញលក្ខណះរបស់ព្រះ ជាព្រះបិតា គ្មានអ្វីទៀតក្រៅពីព្រះបុត្រាតែ១គត់របស់ព្រះបិតា ជាការចាប់ផ្តើមនៃការបង្កើតរបស់ព្រះ ជារូបអង្គនៃព្រះដ៏មើលមិនឃើញ ជារបស់កើតមកមុនគេ ហើយជាបងច្បងនៅចំណោមបងប្អូនឯទៀត។ អេឡូហ៊ីម បង្កើតចេញដោយទ្រង់ផ្ទាល់ ជាគ្រួសារនេះជាលក្ខណះ " អាថ៌កំបាំងរបស់ព្រះ ព្រះបានលេចមកក្នុងសាច់ឈាម បានរាប់ជាសុចរិត ដោយព្រះវិញ្ញាណ ពួកទេវតាបានឃើញទ្រង់ មានគេប្រកាសដល់ពួកសាសន៍ដទៃ មានគេជឿដល់ទ្រង់ ហើយបានលើកឡើងតៅក្នុងសិរីល្អ "ដែលបានគិតទុកក្នុងគំនិតរបស់ព្រះដ៏មានព្រះចេស្តាបំផុត មុនរបស់អ្វីៗ ដែលកើតមានឡើង។ ហើយបាននាំមកនៅក្នុងព្រះអម្ចាស់យេស៊ូគ្រីស្ទនៃយើង។ ព្រះយេស៊ូគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះបានមកក្នុងសាច់ឈាម ទ្រង់គឺជាព្រះបន្ទូលនៃព្រះ លេចមកក្នុងសាច់ឈាមមនុស្ស។ ក្នុងគ្រប់ទាំងអស់ ទ្រង់មានមុនគេ។

ឥឡូវនេះ តាំងពិ "*ព្រះបន្ទូល បានគង់ជាមួយនឹងព្រះ*" យ៉ូហាន១:១។ ទ្រង់គង់ជាមួយព្រះវិញ្ញាណដ៏មានព្រះចេស្តាបំផុត គង់នៅក្នុងពន្លឺ (បង្គោលភ្លើង) ដែលមិនអាចចូលទៅជិតបាន (១ ធីម៉ូថេ ៦:១៦)។ ទ្រង់គង់ក្នុងឧរា (ព្រះទ័យ) របស់ព្រះ។ ព្រះជាបិតា បានដាក់ព្រះបន្ទូលក្នុងស្នូកហើយចាពូជជាព្រះបុត្រា។ វិញ្ញាណនៃភាពជាកូន (ព្រះយេស៊ូ ជាព្រះរាជបុត្រា)បាននៅក្នុងបន្ទូល។ ព្រះយេស៊ូជាព្រះរាជបុត្រានោះ ដែលបានសំដែងនៅក្នុងរូបកាយព្រហបន្ទូល។ ដូច្នេះហើយ ព្រះបន្ទូល ជាព្រះរាជបុត្រា គឺជាព្រះបន្ទូលនៃជីវិតនៅក្នុងការបង្កើត និងការប្រោសលោះ (យ៉ូហាន ១:៤ ,១យ៉ូហាន ១:១) ដោយសារព្រះមែសី(អ្នកសង្គ្រោះ) ត្រូវមកជាមនុស្ស *ព្រះបន្ទូល* ត្រូវប្រដាប់ដោយសាច់ឈាមជាមនុស្ស ។ ដើម្បីធ្វើការនេះ ព្រះត្រូវតែនាំចេញការបង្កើតថ្មី១ សំរាប់កន្លែងគង់នៅនៃ*ព្រះបន្ទូល-****"ជារូបកាយដែលទ្រង់រៀបចំឲ្យទូលបង្គំ"*** (ហេព្រើរ១០៥ខ) បាទ រូបកាយនៃសាច់ឈាម (*មិនមែន រូបកាយនៃកូនជ័តទេ* ) ត្រូវបានរៀបចំសំរាប់ព្រះបន្ទូលនៃព្រះ ដើម្បីលេចមកឲ្យឃើញ។ គឺជារូបកាយ ដែលមិនបានប៉ះពាល់ដោយសែនរបស់មនុស្ស។ រូបកាយនោះ ***គឺជារូបកាយនៃព្រះយេស៊ូ។*** ហើយព្រះបានគង់ជាមួយទ្រង់ ដោយរៀបចំទ្រង់សំរាប់ព្រះបន្ទូល ដើម្បីគង់នៅក្នុងទ្រង់ នៅពេលដែលទ្រង់ចូលមកដល់អាយុ (លូកា ១:៨០, ២:៤០, ៥២ យ៉ូហាន ១:១៤)។ [ចំណាំ ដំណឹងល្អនៃលូកានិយាយពីព្រះយេស៊ូ ជាកូនមនុស្ស ភាពជាមនុស្សរបស់ទ្រង់ ហើយដំណឹងល្អនៃយ៉ូហាននិយាយពីព្រះយេស៊ូ ជាព្រះរាជបុត្រានៃព្រះ អំណាចជាព្រះ និងភាពជាព្រះរបស់ទ្រង់ ។]

នៅពេលដែលទារកយេស៊ូ បានកើតមកនៅបេថ្លេហិម ព្រះបានផ្លុំខ្យល់ដង្ហើមចូលទៅក្នុងទ្រង់ នូវវិញ្ញាណនៃភាពជាកូន (ដែលបានសំដែងក្នុងរូបកាយខាងវិញ្ញាណនៃ*ព្រះបន្ទូល*)។ ទារកយេស៊ូកើតថ្មី បានត្រឡប់ទៅជាមានព្រលឹងរស់ឡើង និងចំរើនឡើង ដើម្បីសំដែងពីជីវិតនៃព្រះតាំងពីនោះមក លែងមានការសំដែងចេញនៃរូបកាយ (ព្រះបន្ទូល) ខាងវិញ្ញាណទៀតហើយ។ **ទីអូហ្វានី លែងមាន ប៉ុន្តែព្រះបន្ទូលនៅជាមួយព្រះនៅឡើយ។** ទោះជាព្រះយេស៊ូគ្មានបាបសោះឡើយ ក៏មាននិស្ស័យមកពីព្រះ ដូចជាអ័ដាមមាន ពីមុនដួលចុះក្នុងអំពើបាប ព្រះយេស៊ូ ក៏មិនមែនមានរូបកាយ (ព្រះ)។ ទាល់តែទ្រង់បានទទួលជា "កូនចិញ្ចឹម" (កាឡាទី ៤:៥ សូមមើលអត្ថបទ ហ៊ុសតាស៊ី) ទ្រង់ក៏មិនអាចបានទៅជាម្នាក់ដែលមានប្រេងតាំងដែរ។ ដល់ពេលទ្រង់បានទទួលប្រេងតាំង *"នៅពេលទ្រង់ទទួលពិធីជ្រមុជទឹក"* ទ្រង់មិនអាចមានពោរពេញនៃព្រះបន្ទូល។ ហើយទាល់តែពេលទ្រង់មាន ព្រះបន្ទូលមកសណ្ឋិតទ្រង់មិនអាចជារូបកាយ ហើយក៏មិនអាចឲ្យព្រះគង់ខាងក្នុងទេ។

ដូចជាគ្រប់របស់ទាំងអស់មានជីវិត របស់នៅទាំងសត្វទាំងមនុស្ស បានទទួលវិញ្ញាណជីវិតមកពីព្រះមានព្រះជម្មរស់ មានតែកូនប្រុសកូនស្រី តំរូវទុករបស់ព្រះ បាននៅជាមួយនឹងព្រះក៏ជាផ្នែកនៃព្រះបន្ទូលនៃព្រះក្នុងផែនការតំរូវទុករបស់ព្រះ។ ព្រះយេស៊ូមានបន្ទូលថា:

*"អស់អ្នកណា ដែលព្រះវរបិតាប្រទានមកខ្ញុំ..."*(យ៉ូហាន ៦:៣៧ក)។

*"ប៉ុន្តែអ្នករាល់គ្នាមិនជឿ ដ្បិតអ្នករាល់គ្នាមិនមែនជាចៀមរបស់ខ្ញុំទេ ដូចជាខ្ញុំបានប្រាប់ស្រេចហើយ ចៀមខ្ញុំទាំងប៉ុន្មានវាស្គាល់ខ្ញុំ ហើយមកតាមខ្ញុំ ខ្ញុំក៏ស្គាល់វាដែរ ខ្ញុំឲ្យជីវិតអស់កល្បជានិច្ចដល់វា វាមិនត្រូវវិនាសនៅអស់កល្បជៀងទៅ ក៏គ្មានអ្នកណាឆក់វាយកពីដៃខ្ញុំបាន ព្រះវរបិតា ដែលប្រទានវាមកខ្ញុំ ទ្រង់ធំលើសជាងទាំងអស់ គ្មានអ្នកណា អាចឆក់យកវាចេញពីព្រះហស្តរបស់ព្រះវរបិតាខ្ញុំបានឡើយ"*(យ៉ូហាន ១០: ២៦-២៩)។

*"ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា បើគ្រាប់ស្រូវដែលធ្លាក់ចុះពីដីមិនងាប់ទេនោះនឹងនៅតែដដែល តែបើងាប់វិញ នោះនឹងបង្កើតផលជាច្រើនឡើង"*(យ៉ូហាន ១២:២៤)

ព្រះយេស៊ូគ្រីស្ទ ព្រះបន្ទូលនៃជីវិត គឺជា "ស្រូវ" ជាពូជរបស់ព្រះបានងាប់ទៅនោះក៏បង្កើតផលជា *"ច្រើនឡើង"* ជាពួកកូនប្រុសស្រីរបស់ព្រះ។ (សូមចាំពូជតែ១ វាក៏អាចបង្កើតពូជជាច្រើន)។ ទោះបីយ៉ាងណាក៏ដោយ មានតែពូជតំរូវទុកជាច្រើន បានទទួលវិញ្ញាណភាពជាកូន ជាមួយពួកគេ ហើយពួកគេបានកើតនៅក្នុងលោកីយ៍កំពុងមានបាប។ សាវកបានសរសេរថា

ឡូហ្គុស: ការចាប់ផ្តើមដំបូងនៃការបង្កើតរបស់ព្រះ

*"តែឯព្រះទ្រង់សំដែងសេចក្តីស្រឡាញ់របស់ទ្រង់ដល់យើងរាល់គ្នាឲ្យឃើញច្បាស់ ដោយព្រះគ្រីស្ទបានសុគតជំនួសយើងរាល់គ្នា នោះក្នុងកាលដែលយើងនៅមានបាបនៅឡើយផង"* (រ៉ូម៥:៨)។

*"ប៉ុន្តែព្រះដែលទ្រង់មានសេចក្តីមេត្តាករុណាដ៏លើសលប់ដោយព្រោះសេចក្តីស្រលាញ់ជាខ្លាំង ដែលទ្រង់មានដល់យើងរាល់គ្នា ក្នុងកាលដែលយើងនៅស្លាប់ក្នុងការរំលងនៅឡើយ នោះទ្រង់បានប្រោសឲ្យយើងរាល់គ្នាបានរស់ជាមួយនឹងព្រះគ្រីស្ទ គឺដោយព្រះគុណដែលអ្នករាល់គ្នាបានសង្គ្រោះ ហើយទ្រង់បានប្រោសឲ្យយើងរស់ឡើងវិញ ក៏ឲ្យយើងអង្គុយជាមួយនឹងព្រះគ្រីស្ទ នៅស្ថានដ៏ខ្ពស់ដែរ ដើម្បីឲ្យទ្រង់បានសំដែងឲ្យអស់តាំងកល្បខាងមុខបានឃើញព្រះគុណដ៏ខ្ពស់លើសលប់របស់ទ្រង់ ដោយសេចក្តីសប្បុរស ដែលទ្រង់ផ្តល់មកយើងក្នុងព្រះគ្រីស្ទយេស៊ូ ដ្បិតគឺ ដោយសារព្រះគុណដែលអ្នករាល់គ្នាបានសង្គ្រោះ ដោយសារសេចក្តីជំនឿ ហើយសេចក្តីនោះ ក៏មិនមែនកើតពីអ្នករាល់គ្នាដែរ គឺជាអំណោយទានរបស់ព្រះវិញ ក៏មិនមែនដោយការប្រព្រឹត្តដែរក្រែងអ្នកណាអួតខ្លួន ដ្បិតយើងរាល់គ្នាជាស្នាដៃ ដែលទ្រង់បង្កើតក្នុងព្រះគ្រីស្ទយេស៊ូ សំរាប់ការល្អ ដែលព្រះបានរៀបចំទុកជាមុន ឲ្យយើងរាល់គ្នាប្រព្រឹត្តតាម"* ( អេភេសូរ ២:៤-១០)។

*"ដ្បិតព្រះបានបង្កើតអ្នករាល់គ្នាជាថ្មី មិនមែនជាពូជ ដែលតែងតែពុករលួយនោះទេ គឺពូជដែលមិនចេះពុករលួយវិញ គឺជាព្រះបន្ទូលដ៏រស់ ហើយនៅជាប់លាប់"* (១ពេត្រុស១:២៣)។

នេះច្បាស់ណាស់ថា ព្រះយេស៊ូ ជាព្រះរាជបុត្រានៃព្រះ មិនបានឆ្លងផុតពីរូបកាយវិញ្ញាណ(ព្រះបន្ទូល)។ គឺទ្រង់ជាពូជតែ១គត់ ត្រូវជាវិញ្ញាណភាពជាកូនក្នុងរូបកាយព្រះបន្ទូល ។ ទ្រង់បានយាងមកពីព្រះបន្ទូលចំ ហើយព្រះបានគង់ខាងក្នុង ពេលដែលទ្រង់ទទួលបុណ្យជ្រមុជទឹកនៅទន្លេយ័រដាន់។ ពេលនោះហើយ ទ្រង់តៅជា *"ព្រះបន្ទូលបានកើតមកក្នុងសាច់ឈាម"* ដែលពួកកូនប្រុសកូនស្រីដមរូវទុករបស់ព្រះ បានទៅជា *"ផលផ្លែ"* មកពីពូជតែ១គត់ ដែលត្រូវឆ្លងផុតរូបកាយ(វិញ្ញាណ) ព្រះបន្ទូល *"ហើយពីព្រោះជីវិតទាំងឡាយបានចុះចូលនឹង សេចក្តីឥតប្រយោជន៍ ដែលមិនមែនដោយស្មគ្រ័ពីចិត្ត គឺដោយព្រោះព្រះអង្គ ដែលទ្រង់បញ្ចុះបញ្ចូលវិញដោយសង្ឃឹម។"* (រ៉ូម៨:២០) *"ទីជំរៅហៅរកទីជំរៅផងគ្នា"*(ទំនុកដំកើត ៤២:៧)។ ពូជដំរូវទុកជាច្រើនបានទទួលខុសត្រូវក្នុងការបើកសំដែងព្រះបន្ទូល ពីព្រោះ ពួកគេបាននៅក្នុងផ្នែកពូជតែ១គត់នៃព្រះបន្ទូល។ ពួកគេជាផ្នែកនៃរូបកាយរបស់ពូជ (ព្រះគ្រីស្ទ) ដែលបានងាប់។ ពួកគេជា *"ផល"* របស់ទ្រង់ ដែលបានចេញមកពីទ្រង់ ដូច

ជាពូជ "ស្រូវ" បានងាប់ (នៅឯភ្នំកាលវ៉ារី)។ ពួកបរិសុទ្ធបានមាននៅក្នុងកូននៃព្រះយេស៊ូគ្រីស្ទ។

ដូចជាព្រះយេស៊ូបានកើតជាកូនង៉ែត (មិនមែនជាព្រះរាជបុត្រាទេ) ពីផ្ទៃនាងមារី ពូជរើសតាំងជាច្រើន ក៏បានកើតជាកូន (មិនមែនជាពួកកូនព្រះ) ចេញពីផ្ទៃម្តាយរបស់ពួកគេ។ ដូចព្រះយេស៊ូ ដែលត្រូវទទួលសេចក្តីពោរពេញនៃ*ព្រះបន្ទូល* ដើម្បីក្លាយទៅជាព្រះរាជបុត្រានៃព្រះ ពូជរើសតាំងក៏ត្រូវការទទួលព្រះបន្ទូលដើម្បីក្លាយជាកូនរបស់ព្រះដែរ។

## ដូចព្រះវរបិតា ដូចព្រះរាជបុត្រា

អ្វីក៏ដោយ ដែលថ្លែងពីព្រះនៅសញ្ញាចាស់ ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងព្រះយេស៊ូ។ យើងអានពីព្រះ ដែលចែងថា ទ្រង់ជាស្តេច (ទំនុក ៥:២ យេរេមា ១០:១០ សាការី៩:៩)។ នៅពេលព្រះយេស៊ូបានយាងមកលោកីយ៍ ទ្រង់ត្រូវគេថ្វាយបង្គំដូចជាស្តេច (ម៉ាថាយ២:២) ហើយនឹងក្លាយជាស្តេចនៅក្នុងថ្ងៃពេលដែលទ្រង់នឹងគង់នៅលើបល្ល័ង្កនៃសិរីល្អរបស់ទ្រង់ (ម៉ាថា២៥:៣១-៣២ មើល១ធីម៉ូថេ ១:១៧ វិវរណៈ ១១:១៧. ១៥:៣)។ យើងអានពីព្រះថាជាចៅក្រម (ទំនុក ៥៨:១១ អេសាយ៣៣:២២) ហើយព្រះយេស៊ូគឺជាចៅក្រម (យ៉ូហាន៥:៣០,វិវរណៈ ១៩:១១)។ ព្រះជាអ្នកប្រោសលោះ (ទំនុក ១៩:៤ អេសាយ៤៣:១៤ ) ព្រះយេស៊ូក៏ជាអ្នកប្រោសលោះដែរ (កាឡាទី៣:១៣, ហេព្រើរ៩:១២)។ ព្រះជា "ព្រះដ៏ជាព្រះ" (និគូមន៍៣:១៣-១៤, អេសាយ ៤៤:៦ខ) ព្រះយេស៊ូ ក៏អះអាងថាទ្រង់ក៏បានជា "ព្រះដ៏ជាព្រះដែរ" (យ៉ូហាន ៨:២៤, ៥៧-៥៨ វិវរណៈ ១:១៧-១៨ )។

ឧទាហរណ៍ទាំងអស់នេះ និងផ្សេងទៀតនៅក្នុងបទគម្ពីរមិនមែនជាបន្ទាល់នៃព្រះ២ទេ។ ផ្ទុយទៅវិញ វាបានបង្ហាញថា ព្រះអម្ចាស់យេស៊ូ គឺជាព្រះផ្ទាល់គង់ក្នុងសាច់ឈាម។ បទគម្ពីរបានគូសបញ្ជាក់ថាមានព្រះតែ១ គឺជាព្រះវរបិតា ដែលបានបង្កើតរបស់ទាំងអស់ ហើយក៏មានមានព្រះអម្ចាស់តែ១ គឺព្រះយេស៊ូគ្រីស្ទ ដែលរបស់ទាំងអស់មាននៅ (ឬឈរទាំងអស់គ្នា)។ ទាក់ទងនឹងព្រះយេស៊ូគ្រីស្ទ ប៉ូលបានសរសេរថា:

"*ដ្បិតគឺទ្រង់ហើយ ដែលបង្កើតគ្រប់ទាំងអស់ ទាំងរបស់នៅស្ថានសួគ៌និងនៅផែនដី ទាំងរបស់ដែលមើលឃើញ ហើយដែលមើលមិនឃើញផង ទោះបីជារាជ ឬអំណាចជាព្រះអម្ចាស់ឬអំណាចគ្រប់គ្រង ឬអំណាចណាក៏ដោយ នោះសុទ្ធតែកើតមកដោយសារទ្រង់ ហើយសំរាប់ទ្រង់ទាំងអស់។ ទ្រង់គង់នៅមុនទាំងអស់ ហើយរបស់ទាំងអស់ក៏នៅស្ថិតស្ថេរដោយសារទ្រង់*" (កូល៉ុស ១:១៦-១៧)

ឡូហ្គុស: ការចាប់ផ្ដើមដំបូងនៃការបង្កើតរបស់ព្រះ

វាច្បាស់ហើយថា ព្រះយេស៊ូគ្រីស្ទ គឺជាមូលហេតុរបស់ព្រះ សំរាប់ការបង្កើត។ ព្រះយេស៊ូគឺជាបងច្បងក្នុងការគូរគ្រោង ការបង្កើត និងផែនការដំរូវទុកជាមុនរបស់ព្រះ។ ទ្រង់ជាប្រធានគ្រឹះនៃសិរីល្អរបស់ព្រះ។ ព្រះជាអ្នកនិពន្ធដែលបានគិតនៅស្ថានសួគ៌ និងផែនដី ក្នុងព្រះគ្រីស្ទ។

*"គង់តែខាងយើង មានតែព្រះតែ១ប៉ុណ្ណោះ គឺជាព្រះវរបិតា ដែលរបស់សព្វសារពើកើតមកពីទ្រង់ ហើយយើងរាល់គ្នាក៏សំរាប់ទ្រង់ ក៏មានព្រះអម្ចាស់តែ១ គឺព្រះយេស៊ូគ្រីស្ទ ដែលរបស់សព្វសារពើកើតមកដោយសារទ្រង់ ហើយយើងក៏ដោយសារទ្រង់ដែរ"* (១កូរិនថូស៨:៦)។

អាម៉ែន **ព្រះ**ជាព្រះវរបិតា គឺជាព្រះ ហើយព្រះរាជបុត្រា ដែលជា**ព្រះអម្ចាស់** ក៏ជាព្រះផងដែរ (កិច្ចការ២:៣៦,កូឡូស១:១៩,វិវរណៈ៤:១១,២២:១)

## ព្រះគ្រីស្ទ

ក្នុងការខំបញ្ជាក់ពីគោលលទ្ធិនៃព្រះត្រៃឯក អ្នកជឿព្រះត្រៃឯកខ្លះ ក៏បានយកពាក្យ ថា *"ព្រះគ្រីស្ទ"* ក្នុង១កូរិនថូស១០:១-៤ (ដែលប៉ូលបានហាមពួកជំនុំកូរិនថូស កុំឲ្យធ្វើដូចជាកូនចៅអ៊ីស្រាអែល ដែលល្បួងព្រះគ្រីស្ទ) ហើយនិយាយថា ព្រះយេស៊ូបានមានពីមុនរួចមកហើយ ព្រោះទ្រង់គឺជា *"ថ្មខាងវិញ្ញាណនោះ"*ដែលតាមកូនចៅអ៊ីស្រាអែល។

ពាក្យថា *"ព្រះគ្រីស្ទ"* នៅក្នុងបទគម្ពីរមិនមែនតែងតែចង្អុលទៅមនុស្សគ្រីស្ទយេស៊ូទេការនេះអាចផ្ទៀងផ្ទាត់ ដោយអាន ម៉ាថាយ ២៤៥ (ហើយខ បទគម្ពីរស្រដៀងគ្នាជាច្រើន) ដែលព្រះយេស៊ូមានបន្ទូលពីព្រះគ្រីស្ទក្លែងក្លាយជាច្រើន ឬអ្នកមានប្រេងតាំងក្លែងក្លាយជាច្រើនដែលនឹងចូលមកក្នុងលោកីយ៍នេះ។ មិនតែប៉ុណ្ណោះ មានមនុស្សជាច្រើននៅលើលោកីយ៍នេះដែលមានឈ្មោះ *"យេស៊ូ"* ប៉ុន្តែមានតែ១ទេ ដែលហៅថា**ព្រះគ្រីស្ទ**។

ពាក្យក្រិត សំរាប់**ព្រះគ្រីស្ទ** គឺ**គ្រីស្តូស** ដែលមានន័យថា **ដែលមានប្រេងតាំង**។ពួកអ្នកជាហោរារបស់ព្រះ ហៅថា *ហយគ្រីស្តុយ ទីអូ* ដែលមានន័យថា អ្នក*ដែលមានប្រេងតាំងរបស់ព្រះ*។ ការចាក់ប្រេងតាំង បានមកពីព្រះវិញ្ញាណ ***(ឡូហ្គុស)***នៃព្រះប៉ុណ្ណោះ។

ក្នុងកិច្ចការ ២៣៦ ពេត្រុសបាននិយាយថា *"ព្រះបានលើកព្រះយេស៊ូនេះ ដែលអ្នករាល់គ្នាបានឆ្កាង ឲ្យទ្រង់ធ្វើជាព្រះអម្ចាស់ និងជាព្រះគ្រីស្ទផង"*។ មែនហើយ ហេតុអ្វីបានជាចាំបាច់ឲ្យព្រះលើកព្រះយេស៊ូឲ្យធ្វើជា***ព្រះអម្ចាស់ និងជាព្រះគ្រីស្ទផង*** បើព្រះយេស៊ូបានគង់នៅពីមុនរួចមកហើយ ជាវិញ្ញាណហៅថា **ព្រះគ្រីស្ទ?** ហើយបើព្រះយេស៊ូបានមានពីមុនរួចមកហើយជាវិញ្ញាណផ្ទាល់ខ្លួនដាច់ដោយឡែក *(ជាបុគ្គលទី២នៃព្រះដ៏កំពូល យោងទៅតាមពួកអ្នកជឿព្រះត្រៃឯក)* ពីព្រះ (ព្រះវរបិតា) តើតួនាទី*ព្រះគ្រីស្ទ*នៅលើ

វិញ្ញាណនោះ ដែលជាព្រះ មិនទៅជា *ការផ្ទុយគ្នាទេឬអី?* ព្រះគ្រាន់តែចាក់ប្រេងតាំង ទ្រង់មិនមែនទទួលការចាក់ប្រេងតាំងទេ។ មានតែពួកមានតួមានជីវិត និងរបស់ដែលបានបង្កើតមកប៉ុណ្ណោះ ទទួលការចាក់ប្រេងតាំង។ ដូច្នេះមនុស្ស យេស៊ូ បានទទួល ការចាក់ប្រេងតាំងពីព្រះជាព្រះវរបិតារបស់ទ្រង់។

ដូចនេះ *ថ្មខាងឯវិញ្ញាណនោះ* គ្មាននរណាទៀតទេក្រៅពីដេបារ *(ព្រះបន្ទូល)* ដែលមានប្រេងតាំង ដែលបានហូរចេញពីព្រះវិញ្ញាណដ៏មានព្រហចេស្តាបំផុតនៃព្រះ ដើម្បីផ្តល់អាហារ និងគ្រឿងផឹក ដល់កូនចៅអ៊ីស្រាអែលនៅក្នុងទីរហោស្ថាន។ *ថ្មនោះ*គឺជា *ព្រះគ្រីស្ទដែល (ព្រះបន្ទូលដែលមានប្រេងតាំង)* នៃព្រះ ដែលគ្រប់អ្នកជឿសតាំងពិតទាំងអស់កំពុងតែរួមចំណែកក្នុងពេលឥឡូវនេះ។ ជាការពិត ព្រះបន្ទូលដែលមានប្រេងតាំងនោះ បានមកឯបួកអ៊ីស្រាអែល តាមរយៈទេវតា (អ្នកនាំព្រះរាជសារ ទូត) របស់ព្រះដែលបានមានព្រះនាមនៃព្រះ។ ទ្រង់ជា*ព្រះបន្ទូល* នោះដែលដឹកនាំកូនចៅអ៊ីស្រាអែល ។ ទ្រង់ជាព្រះភក្ត្រ(**វត្តមាន**) នៃព្រះអម្ចាស់ដ៏ជាព្រះ

## ការមកគង់នៅខាងក្នុង

ឥឡូវនេះ សូមកត់សំគាល់ដោយប្រុងប្រយ័ត្ន យ៉ូហាន ១:១៤

*"ព្រះបន្ទូលក៏ត្រឡប់ជាសាច់ឈាម ហើយបានស្នាក់នៅជាមួយនឹងយើងរាល់គ្នា......"*

ជារឿយៗ គេនិយាយថា *"ព្រះវិញ្ញាណត្រឡប់ជាសាច់ឈាម"* ឬ *"ព្រះក្លាយជាសាច់ឈាម"*។ ប្រយោគបែបនេះ ដែលជាធម្មតា គេយកដោយមិនគិតថាខុស ឬត្រូវទេ មានបំណងដឹកនាំគ្រីស្ទានជាច្រើនឲ្យសង្ខេបខុសថា ព្រះវិញ្ញាណដ៏មានព្រះចេស្តាអស្ចារ្យ បានយកនិស្ស័យជាមនុស្ស ។ ទស្សនះគួរឲ្យភ្ញាក់ផ្អើលស្មើគ្នារបស់ព្រះត្រៃឯក ចង់និយាយថា អង្គព្រះវិញ្ញាណទី២ដែលហៅថា *"ព្រះរាជបុត្រា"* បានបំលែងអង្គទ្រង់ ទៅជាអំប្រីយ៉ុងមនុស្ស នៅក្នុងផ្ទៃនាងព្រហ្មចារីម៉ារី ដើម្បីកើតជា *"ព្រះរាជបុត្រានៃព្រះ"*។ ក៏ចង់មានន័យថា ព្រះបន្ទូល (ដែលគេបកស្រាយថា ជាព្រះយេស៊ូគ្រីស្ទផ្ទាល់) បានក្លាយទៅជាគតិនៅក្នុងផ្ទៃនាងម៉ារី ហេតុនោះហើយទារកមនុស្សនោះ ជាព្រះលក្ខណះព្រះ(កូន)។ ពួកគ្រីស្ទានគេជឿទស្សនះយ៉ាងនេះ ថាព្រះរាជបុត្រា បានកើត។ ពួកគេក៏ជឿទៀតថា ព្រះ(បិតា) មកចាប់កំណើតនៅក្នុងបុត្រាបន្ទាប់ពីបានទទួលបុណ្យជ្រមុជទឹកនៅទន្លេយ័រដាន់។ ការបង្រៀនបែបនេះគ្មានគ្រឹះក្នុងបទគម្ពីរបរិសុទ្ធ។ (ចំណាំ ពាក្យ ចាប់កំណើតនេះ (Incarnate) បានយកមកប្រើពីពាក្យឡាតាំង គឺមានន័យថា សំលៀកបំពាក់ជាសាច់ឈាម)។

តើបុគ្គលណាជឿថា ព្រះវិញ្ញាណ បានផ្លាស់ប្តូរមកនៅក្នុងសាច់ឈាមជាអំប្រីយ៉ុង ដែលលូតលាស់នៅក្នុងផ្ទៃនាងម៉ារី? តើអ្នកណាមួយជឿថា ព្រះជា

ឡូហ្គុស: ការចាប់ផ្ដើមដំបូងនៃការបង្កើតរបស់ព្រះ

វិញ្ញាណ បានក្លាយមកជាមនុស្សវិញមានរូបកាយមនុស្ស សូនមកពីធូលីដី? តើអ្នកណាបានអះអាងថា *"អូ ព្រះអាចធ្វើគ្រប់សព្វទាំងអស់បាន ព្រោះទ្រង់ជាព្រះ?"* ចំជាបុគ្គលល្ងីល្ងើជាច្រើន អាចបង្កើតផ្ទាំងថ្មធំ សូម្បីតែព្រះផ្ទាល់មិនអាចលើករួចឬ។

សូមគិតពីការនេះឲ្យបានហ្មត់ចត់។ តើវាសមហេតុផលទេ គំនិតមានអំណាចមានគត៌ក្នុងផ្ទៃម៉ារីរស់នៅក្នុងស្បូនឬទេ? ពេលដែលព្រះយេស៊ូ កើតមកជាទារក ទារកនេះស្រែកយំដូចជាទារកផ្សេងៗអញ្ចឹង តើសំលេងទារកយំនេះ ជាព្រះទារកឬ? ពេលដែលទារកយេស៊ូ បានបៅដោះម៉ារី តើនេះជាព្រះដែលបៅដោះឬ? ពិតជាមិនមែនទេ ព្រះជាវិញ្ញាណ។ ទ្រង់មិនមែនជាមនុស្ស។ ព្រះមិនបានមកជាសាច់ឈាមទេ។ ដ្បិត *"របស់អ្វីដែលកើតពីសាច់ឈាម នោះជាសាច់ឈាម ហើយជារបស់អ្វី ដែលកើតពីវិញ្ញាណ នោះគឺជាវិញ្ញាណវិញ"* យ៉ូហាន ៣:៦ ។

**គឺជាព្រះបន្ទូលរបស់ព្រះ គឺការបើកសំដែងផ្ទាល់ដ៏មើលឃើញរបស់ទ្រង់** គឺជាព្រះបន្ទូលនោះហើយ ដែលត្រឡប់មក **(បានបង្ហាញក្នុង)** សាច់ឈាម។ គឺជារូបកាយព្រះបន្ទូល បានចេញមកពីព្រះ ក៏បានលេចឲ្យពួកបរិសុទ្ធឃើញនៅសញ្ញាចាស់ ជាច្រើនដង ជាទំរង់រូបកាយទីអូហ្វានីបណ្ដោះអាសន្នទ្រង់លែងបង្ហាញទៀត ពេលដែលនៅបេថ្លេហិម ពីព្រោះឡូហ្គុសត្រូវតែយកទំរង់មនុស្សបណ្ដោះអាសន្ន។

"ដ្បិតមានបុត្រ ១ កើតដល់យើង ព្រះទ្រង់ប្រទានបុត្រ១មកយើងហើយ" អេសាយ ៩៦

*"ព្រះបន្ទូលក៏ត្រឡប់ជាសាច់ឈាម ហើយបានស្នាក់នៅជាមួយនឹងយើងរាល់គ្នា យើងរាល់គ្នាបានឃើញសិរីល្អទ្រង់ គឺជាសិរីល្អនៃព្រះរាជបុត្រាតែ១ដែលមកពីព្រះបិតា មានពេញជា ព្រះគុណនឹងសេចក្ដីពិត"*។ យ៉ូហាន ១: ១៤

***"ព្រះបន្ទូលបានបង្ហាញខាងសាច់ឈាម"*** ទាល់តែពេលព្រះផ្ទាល់មកគង់ខាងក្នុងមនុស្សយេស៊ូ ពេលទ្រង់បានទទួលពីធីជ្រមុជទឹកក្នុងទន្លេយ័រដាន់នៅមុខមនុស្សជាច្រើន ក៏បានសំរេចនៅក្នុងម៉ាឡាគី ៣:១:

*"...ហើយព្រះអម្ចាស់ ដែលឯងរាល់គ្នា ស្វែងរកនោះ ទ្រង់នឹងលតែមក ដល់ព្រះវិហារទ្រង់ភ្លាម ឯទូតដែលនាមសេចក្ដីសន្យាមក ជាសេចក្ដីសន្យាដែលឯងរាល់គ្នា ចង់បានទាំងម្ល៉េះនោះ..."*

ពេលនោះហើយ ដែលសេចក្ដីពោរពេញនៃព្រះបន្ទូលរបស់ព្រះ មកគង់ព្រះគ្រីស្ទ។

ទំនាយ ដែលបានបើកសំដែង

*"កាលព្រះយេស៊ូបានទទួលបុណ្យជ្រមុជទឹកហើយ នោះទ្រង់យាងឡើងពីទឹកភ្លាម ស្រាប់តែមេឃក៏បើកឡើង ឲ្យទ្រង់ឃើញព្រះវិញ្ញាណនៃព្រះយាងចុះមកដូចជាសត្វព្រាប ក៏សណ្ឋិតលើទ្រង់ នោះក៏មានលឺសំលេងចេញពីលើមេឃថា នេះជាកូនស្ងួនភ្ងាអញ ជាទីពេញចិត្តអញណាស់"* ម៉ាថាយ ៣:១៦-១៧។

*"ដ្បិតព្រះបានសព្វព្រហឫទ័យ ឲ្យគ្រប់ទាំងសេចក្តីពោរពេញបានស្ថិតនៅក្នុងទ្រង់"* (កូឡូស ១:១៩ យ៉ូហាន ១៤:១០ កូឡូស ២:៩។)

ចំណាំ ទំនាយនៅក្នុងអេសាយ ៩:៦ ថា បុត្រមិនមែនទារក ដែលបានប្រទានមកជាដង្វាយបូជា សំរាប់បាប យ៉ូហាន ៣:១៦-១៨។ ហេតុនេះមនុស្សម្នាក់ ដែលមានប្រេងតាំង គឺព្រះយេស៊ូ ដែលហៅថា អ័ដាមចុងក្រោយ ឬមនុស្សទី២ ដូចភាពង័ដាមពីដើម ក៏ជាមនុស្សមុនគេដែលបង្កើតមក ហើយក៏ជាមនុស្ស ជាកូនរបស់ព្រះ មិនមែនជាទារក។ ដូចគ្នាដែរ ព្រះមិនដែលលេចមកក្នុងពេលណា១ ជាទារកទីអូហ្វានី ជាទារក ឬយុវជនទេ ពីព្រោះរូបកាយព្រះបន្ទូល តែងតែលេចជាបុគ្គលពេញលេច។

*"ព្រះបន្ទូលក៏ត្រឡប់ជាសាច់ឈាម ហើយបានស្នាក់នៅជាមួយនឹងយើងរាល់គ្នា ហើយយើងរាល់គ្នាបានឃើញសិរីល្អទ្រង់ គឺជាសិរីល្អនៃព្រះរាជបុត្រាតែ១ ដែលមានពេញដោយសេចក្តីពិត"* (យ៉ូហាន ១:១៤)។

ពាក្យដែលសាវកនិយាយនេះបានបង្ហាញច្បាស់ណាស់ថា មិនមែននិយាយអំពីទារកយេស៊ូ ដែលបៅបោះ ឬទោះបីជាទ្រង់ពេញវ័យជាយុវជន ក៏មិនទាន់មានព័ន្ធកិច្ចនៅឡើយ។ ជាងនេះទៅទៀត គាត់និយាយពីសិរីល្អបង្ហាញក្នុងជីវិត និងព័ន្ធកិច្ចជាព្រះរាជបុត្រា បន្ទាប់ពីបានទទួលពីធីជ្រមុជទឹកវិញ។ គ្មានសង្ស័យទេ ដែលយ៉ូហាន (ហើយអ្នកដើរតាមព្រះគ្រីស្ទ) បានឃើញសិរីល្អ (ព្រះនាម ព្រះបន្ទូល នឹងការងារ យ៉ូហាន១៧) ជាបិតាអស់កល្ប ក្នុងជីវិតព្រះគ្រីស្ទ និងពន្ធ័កិច្ច។ បាទ គេបានឃើញសិរីល្អទ្រង់ ពេលដែលព្រះបន្ទូល ***"បង្ហាញក្នុងសាច់ឈាម"*** នោះជាព្រះបន្ទូល ដែលបង្ហាញក្នុងបុគ្គលយេស៊ូគ្រីស្ទ ក្នុងសាច់ឈាម។

ជាគំរូ ព្រះយេស៊ូ គឺដូចជាពូជ។ ជាពូជត្រូវតែចាស់ និងដើម្បីឲ្យមានកំរិតដុះទៀត ទៅជាជីវិត ដូច្នេះពេលវា *"ដាប់"* វានឹងអាចបង្កើតផលបានជាច្រើន (បើវាមិនចាស់ទុំទេ វាក៏មិនអាចជាពូជដុះទៅទៀតដែរ)។ ដូចគ្នាដែរ ព្រះបុត្រាក៏ត្រូវតែធំឡើងពីតារក ហើយពេញវ័យក្នុងមនុស្សធំ។ បន្ទាប់មក ទ្រង់បាន *'ទទួលជាកូនចិញ្ចឹម' ហើយក៏ប្រទានអំណាចព្រះបន្ទូលនៃជីវិត* (លូកា ៤:១៨-១៩ )។ ព្រះរាជបុត្រា បានមកជាអ្នកបំរើ ជាមួយពន្ធ័កិច្ចនៃទំនាយ ត្រូវបំរើពីមនុស្សលោក (អេសាយ៤២:១ ម៉ាថាយ១២:១៧-២១ ២០:២៨)។ ហេតុ

ឡូហ្គុស: ការចាប់ផ្ដើមដំបូងនៃការបង្កើតរបស់ព្រះ

នេះ មុខងារ១ជាកូនមនុស្ស។ ទ្រង់ក៏ជាម្នាក់មានប្រេងតាំងនាំព្រះបន្ទូលរបស់ព្រះ។

*"ព្រះវិញ្ញាណព្រះអម្ចាស់សណ្ឋិតលើខ្ញុំ ពីព្រោះទ្រង់បានចាក់ប្រេងតាំងខ្ញុំ ឲ្យផ្សាយដំណឹងល្អដល់មនុស្សទ័លក្រ ទ្រង់បានចាត់ខ្ញុំឲ្យមកដើម្បីនិងប្រោស មនុស្សដែលមានចិត្តសង្រេង ហើយប្រកាសពីសេចក្ដីប្រោសលោះដល់ពួក ឈ្លើយ និងសេចក្ដីភ្លឺឡើងវិញដល់មនុស្សខ្វាក់ ហើយដោះមនុស្ស ដែលគេជិះ ជាន់ឲ្យរួច ព្រមទាំងប្រកាសពីឆ្នាំ ដែលព្រះអម្ចាស់កំនត់ទុក"* លូកា ៤:១៨-១៩ អេសាយ ៤២:៦-៧ ៦១:១។ (សូមអានយ៉ូហាន ១:៣២ ៣:៣៤)

ព្រះបន្ទូលមកគង់ក្នុងទ្រង់។ ព្រះយេស៊ូក៏អាចដាក់ជីវិតទ្រង់ចុះ ហើយនាំឲ្យកើតពូជផលផ្លែជាច្រើន។

*"ព្រះយេស៊ូមានបន្ទូលទៅនាង ខ្ញុំជាសេចក្ដីរស់ឡើងវិញ ហើយជាជីវិត អ្នកណាដែលជឿដល់ខ្ញុំ ទោះបីបានស្លាប់ហើយ គង់តែនឹងរស់ឡើងវិញដែរ អ្នកណាដែលរស់នៅហើយជឿខ្ញុំនោះមិនត្រូវស្លាប់ឡើយ"* យ៉ូហាន ១១:២៥-២៦ ។

ព្រះយេស៊ូមិនគ្រាន់តែជាព្រលឹងរស់ទេទ្រង់ *"ជាវិញ្ញាណដែលប្រោសឲ្យរស់វិញ"*ជាជីវិតដែលព្រះវិញ្ញាណប្រទានមក (១កូរិ ១៥៤៥)។

**ឯសេចក្ដីពោរពេញនៃព្រះដ៏ជាកំពូល បានសណ្ឋិតក្នុងព្រះគ្រីស្ទយេស៊ូ ទាំងមានរូបអង្គផង មិនមែនមានន័យថា នៅស្ថានសួគ៌ទាំងមូល ព្រះវិញ្ញាណដ៏មានព្រះចេស្ដាហូរចុះទាំងស្រុង។** ព្រះដែលជាព្រះវិញ្ញាណ នៅតែជាព្រះគង់នៅគ្រប់ទីកន្លែង (ពីព្រោះទ្រង់ជាសព្វញ្ញូណ និងជាព្រះអាទិករ)។ ដូច្នេះ មិនមែនព្រះទាំងអស់ មកគង់នៅក្នុងព្រះគ្រីស្ទយេស៊ូទេ។ប៉ុន្ដែរបស់ទាំងអស់របស់ព្រះមកគង់ក្នុងព្រះគ្រីស្ទព្រះយេស៊ូ។ រូបកាយព្រះគ្រីស្ទ គឺគ្រាន់តែចាកន្លែង(វិហារ) គង់នៅរបស់ទ្រង់ ហើយជាតំណាងគ្រប់ទាំងអស់(សិរីល្អ) របស់ព្រះ។ ម្យ៉ាងទៀត ព្រះបានប្រទានព្រះវិញ្ញាណគ្មានកំរិតនៅក្នុងព្រះរាជបុត្រា។ អញ្ជឹង ព្រះយេស៊ូគឺជាការសំដែងលក្ខណះទាំងអស់របស់ព្រះ។

ពាក្យសំខាន់បំផុត ដែលព្រះយេស៊ូបានអធិស្ឋាន បង្ហាញឲ្យឃើញថា ពេលទ្រង់អធិស្ឋាននៅក្នុងយ៉ូហាន ១៧:៣។ ទ្រង់មានបន្ទូលថា:

*"នេះជាជីវិតនៅអស់កល្បជានិច្ច គឺឲ្យគេបានស្គាល់ដល់ទ្រង់ដ៏ជាព្រះពិតតែ១ និងព្រះយេស៊ូគ្រីស្ទ ដែលទ្រង់បានចាត់ឲ្យមកផង"*។

នៅក្នុងឃ្លានេះ បានគាំទ្រយ៉ាងច្បាស់ នៅក្នុងសេចក្ដីពិតនៃព្រះពិតតែ១ ហើយថា ព្រះយេស៊ូ បានចាត់មក ដើម្បីសំដែងចេញផ្ទាល់ពីព្រះ។ ព្រះយេស៊ូគ្រីស្ទ គឺជាជីវិតរបស់ព្រះទ្រង់ក៏ជាព្រះបន្ទូលនៃជីវិត។

ទំនាយ ដែលបានបើកសំដែង

*"ឯអ្នកណាដែលជឿដល់ព្រះរាជបុត្រាវិញ នោះមានជីវិតដ៏រស់នៅអស់កល្បជានិច្ចហើយ តែអ្នកណាដែលមិនព្រមជឿដល់ព្រះរាជបុត្រាវិញ នោះមិនឃើញជីវិតសោះឡើយ"* (យ៉ូហាន ៣:៣៦ ហេព្រើរ ១:៣ )

**ឥឡូវនេះ ព្រះយេស៊ូគ្រីស្ទបានបង្ហាញជារូបអង្គរបស់ព្រះ (កូល៉ុស ១:១៥) ហើយទាំងសេចក្តីពោរពេញនៃព្រះបានសណ្ឋិតក្នុងទ្រង់ ទាំងមានរូបអង្គផង (កូល៉ុស ២:៩)។ ដូច្នេះហើយ គឺមិនអាចឲ្យព្រះសំដេងអង្គទ្រង់ក្រៅពីព្រះយេស៊ូទែ (ដោយមិនយកចេញភាពដើម ហើយបន្តការ**
***គិតរបស់ទ្រង់ ជាបំណោងរបស់ទ្រង់***)។






## សាច់ឈាម-និស្ស័យមនុស្ស

"*ព្រះបន្ទូលបានត្រឡប់មកជាមនុស្ស ហើយក៏បានរស់នៅរយៈពេលក្នុងចំណោមយើង*" យ៉ូហាន ១:១៤ (គម្ពីរបារខ្លេ អង់គ្លេស )។

ចូរគិតអំពីសំនួរនេះម្ដងទៀត តាំងពីព្រះបន្ទូលគឺជាព្រះ តើនេះមានន័យថា រូបកាយខាងសាច់ឈាម(របស់ព្រះយេស៊ូ)គឺជាព្រះឬ?

**ទេ** រូបកាយព្រះយេស៊ូគ្រីស្ទដូចមនុស្សឯទៀតៗដែរ តែបានកើតមកពីនាងព្រហ្មចារី និងគ្មានបាបសោះ។ សាវកប៉ូលបាននិយាយថា តែទ្រង់បានរៀបចំរូបកាយឲ្យទូលបង្គំវិញហេព្រើរ ១០:៥។ **សាច់ឈាមមិនមែនជាព្រះទេ តែជារូបកាយរបស់ព្រះ-កន្លែងទ្រង់គង់នៅ។**

ព្រះបានមានបន្ទូល គ្រប់ទាំងអស់បានមកដោយសារព្រះបន្ទូលដែលថ្លែងចេញ (**ឡូហ្កុស**) របស់ព្រះ។ ក្នុងលោកុ យើងបានអានថា អ្វីៗបានចេញជារបស់មក ពេលដែលទ្រង់មានបន្ទូលចេញភ្លាម "*ចូរឲ្យមានពន្លឺឡើង ពន្លឺក៏មានឡើង"។*ល។ ព្រះបន្ទូលដែលថ្លែងចេញ បានបង្កើតឡើង(ហេព្រើរ ១១:៣)។ ដោយសារសញ្ញាដដែលនេះ ព្រះដ៏មានព្រះចេស្ដាបំផុត មានបន្ទូលចេញ (បានបង្កើត) មេជីវិតបុរស (កោសិកាស្ពែម៉ាតូសូអ៊ីត) និងពងនៃជីវិត (កោសិកាពង)ហើយយកមកបញ្ចូល។ ទ្រង់បានដាំអំប្រីយ៉ុង (កំនកូន) ក្នុងស្បូព្រហ្មចារីរបស់ម៉ារី។នៅពេលដែលទារកបានកើតមក វិញ្ញាណភាពជាកូនដែលនៅក្នុងឡូហ្កុស បានចូលតៅក្នុងទារកនោះ។ ហើយទ្រង់ក៏ត្រឡប់ជាមានព្រលឹងរស់ឡើងវិញ។ ឡូហ្កុសមកបន្តនៅក្នុងទារកនេះ ពេលដែលទ្រង់ចូលមកអាយុជាព្រះបុត្រា (អេសាយ ៩:៦) ហេព្រើរ ១:១ គឺបានបង្ហាញដល់បួកមនុស្សបរិសុទ្ធនៅសញ្ញាតាមរបៀបផ្សេងៗ ហើយបន្ទាប់មកក៏បានបង្ហាញដល់ពួកអ៊ីស្រាអេល ហើយក្នុងលោកីយ៍ ជារូបកាយដែលអាចប៉ះបានថែមទៀត នៅក្នុងរូបកាយជាមនុស្សសាច់ឈាម បានកើតពីនាងព្រហ្មចារី (១យ៉ូហាន ៤:២-៣)។ មនុស្ស គឺជាព្រះយេស៊ូគ្រីស្ទ។ ទ្រង់គឺជាសេចក្ដីពោរពេញនៃការបើកសំដែងរបស់ព្រះ ទៅដល់មនុស្សលោក។ ទ្រង់ជាវិហារនៃព្រះដ៏មានព្រញជន្មរស់ ដោយគ្មានកំរិតទេ ។ គឺមិនមែនជាអេម៉ាញូអែល ដោយរូបកាយទីអូហ្វាទីទេ ប៉ុន្តែ អេម៉ាញូអែល ដោយការចាប់កំណើត ។មនុស្សយេស៊ូ បានកើតមកជា (មនុស្ស ពាក្យហេព្រើរអ័ដាម) មិនមែនទីអូហ្វានីទេ។ តើបានឃើញភាពខុសគ្នាហើយ ឬនៅ? ព្រះបន្ទូលបានលេចមកយកនិស្ស័យមនុស្ស (ពាក្យហេព្រើរ អ័ដាម) មិនមែនជាលក្ខណះរបស់ព្រះទេ ហើយព្រះក៏មិនមែនជាមនុស្សដែរ(ជនគណនា ៣១៩)។ និស្ស័យមនុស្ស គឺជាលក្ខណះដែលព្រះបានបង្កើត មកជា (មនុស្ស បាក្យហេព្រើរ អ័ដាម)។ ពេលដែលអេម៉ាញូអែលបានលេចមកក្នុងរូបកាយទីអូហ្វានី រូបកាយទីអូហ្វានី មិនបានកើតទេ គឺជាព្រះវិញ្ញាណ(រូបកាយព្រះបន្ទូល)។ប៉ុន្តែព្រះយេស៊ូ ជាព្រះរាជបុត្រានៃព្រះ បានបង្កើតមកជាមនុស្ស (ពាក្យហេព្រើរ អ័ដាម) ទ្រង់បានមានគភ៌ដោយសារព្រះវិញ្ញាណបរិសុទ្ធ នៅក្នុងផ្ទៃនាងម៉ារី ហើយក៏កើតក្នុងលោកីយ៍នេះ។

ចំណាំ ក្នុងចំណោមពួកនិកាយនិយម មានគេបង្រៀនថា ព្រះយេស៊ូបានកើតពីពងនៃមេជីវិតរបស់នាងម៉ារី និងមេជីវិត ដែលបង្កើតដោយសារព្រះ

ឡូហ្កុស: ការចាប់ផ្តើមដំបូងនៃការបង្កើតរបស់ព្រះ

វិញ្ញាណបរិសុទ្ធ។ ពួកគេពេញចិត្តណាស់ថា នោះហើយចាំបាច់ឲ្យព្រះយេស៊ូគ្រីស្ទពិតប្រាកដជាមនុស្សសាច់ឈាម។ ការបង្រៀនបែបនេះ ដកចេញសេចក្តីពិតដ៏ជ្រៅបំផុត ថាព្រះយេស៊ូគ្រីស្ទជាព្រះរាជបុត្រា (សែនតែ១) នៃព្រះ។ ស្រមោលមកគ្របបាំងនាងព្រហ្មចារី (លូកា ១៣៥) គឺមិនបានទាក់ទង ឬញែកពងនៃមេជីវិតរបស់នាងឲ្យបានបរិសុទ្ធ ដើម្បីបង្កបង្កើតតាមមេជីវិតដែលមកពីព្រះវិញ្ញាណបរិសុទ្ធទេ គឺជាព្រះចេស្តានៃព្រះដែលបានមកសណ្ឋិតលើនាង ដើម្បីឲ្យពូជកើតឡើងតៅជាទារក (ប្រុស) (ម៉ាថាយ ១២០)។ ម៉ារីត្រូវជ្រើសរើសឲ្យធ្វើជាម្តាយរបស់ទារកនោះ។ ទាំងមេជីវិត និងពងនៃមេជិវិតបង្កើតបានជាមនុស្ស តចេញមកពីនិស្ស័យមនុស្សមានបាប ហើយការកើតជាថ្មីរបស់មនុស្សដួលចុះទៅក្នុងអំពើបាបអាចកើតឡើងពេលកើតថ្មីខា វិញ្ញាណវិញ នេះពិតប្រាកដ ជាការផ្ទុយហើយ ដែលឲ្យព្រះ ទៅយកពងនៃមេជីវិតរបស់ម៉ារី ហើយដកចេញនិស្ស័យធម្មជាតិរបស់មនុស្ស មិនអាចជាបុត្រារបស់ព្រះទេ។ ដុច្នេះ ដោយគ្មានការសង្ស័យ មេជីវិត និងពងនៃមេជីវិត ដែលបាននាំចេញឲ្យនាងមានគភ៌ ហើយបង្កើតជាយេស៊ូគ្រីស្ទនោះគឺជាការបង្កើតរបស់ព្រះទាំងអស់។

ឥឡូវ នៅពេលដែលអំប្រីយ៉ុង ដែលដាំនៅក្នុងផ្ទៃនាងម៉ារី ដោយព្រះវិញ្ញាណបរិសុទ្ធឲ្យជារូបកាយទារក។ អំប្រីយ៉ុងមិនមែនព្រះទេ។ គភ៌មិនមែនព្រះទេ។ ទារកក៏មិនមែនព្រះទេក្នុងដំណាក់កាលទាំងអស់បានលូតលាស់ឡើងក្នុងកោសិកាវាផ្ទាល់ រូបកាយទទួលការលូតលាស់ពីឈាមរបស់ម្តាយតាមរយៈសុក ដូចគ្នានឹងទារផ្សេងដែរ។ ជីវិតលូតលាស់ គឺជាសារធាតុនៃផែនដី ដែលផ្តល់ឲ្យរូបកាយលូតលាស់ ហើយព្រះមិនបានផ្សំឡើងតាមសារធាតុផែនដីទេ។ ឯព្រះជាវិញ្ញាណ។

ទារក ជា *"របស់បរិសុទ្ធ"* -ទារកបរិសុទ្ធ ។ ទ្រង់កើតមកជាព្រះរាជបុត្រានៃព្រះ ដើម្បីបង្ហាញ និងសំរេចអស់ទាំងអ្វី ដែលទ្រង់បានចែងទុកមក។ ព្រះយេស៊ូមានបន្ទូលថា *"បទគម្ពីរនេះ ត្រូវតែសំរេច"* ម៉ាកុស ១៤:៤៩។ អ្នកគង្វាលចៀមបានទៅថ្វាយទារកជាអ្នកសង្គ្រោះហើយអ្នកប្រាជ្ញ យកដង្វាយថ្វាយ ស្តេចទារក។ សូមចំណាំ គ្រីស្ទានជាច្រើន ប្រកែកថា ទារកយេស៊ូ គឺជាព្រះ ពីព្រោះអ្នកគង្វាល និងអ្នកប្រាជ្ញ *"ថ្វាយបង្គំទ្រង់"*។ ពាក្យ *"ថ្វាយបង្គំ"* មានន័យច្រើនជាង១ ចូរអានវិវរណៈ ៣៩ចុះ។ តើពួកបរិសុទ្ធនៃពួកជំនុំ ពិតជាព្រះឬ ព្រោះពួកគេទទួលការថ្វាយបង្គំ (ក្រាបសំពះ)ដែរ ? ម៉ាកុស ១៥:១៩ តើពួកទាហានពិតជាថ្វាយបង្គំ ព្រះគ្រីស្ទ ជាព្រះរបស់ពួកគេឬ? ប៉ុន្តែជាទារកឬជាកូនង៉ែត មនុស្សយេស៊ូ (ពាក្យហេព្រើរ: យេស៊ូអាជានាមប្រោសលោះរបស់ព្រះ )គ្រាន់តែជាអ្នកសង្គ្រោះ និងស្តេច ដែលមានសក្តានុពល។ ទ្រង់

គ្រាន់តែជាអ្នកសង្គ្រោះប៉ុណ្ណោះ។ នៅពេលដែលទ្រង់ដាក់ជីវិតរបស់ទ្រង់ នៅលើឈើឆ្កាងភ្នំកាល់វ៉ារី ហើយបានទៅជាស្តេច នៅពេលទ្រង់យាងមកវិញមកគ្រប់គ្រងរាជ១ពាន់ឆ្នាំរបស់ទ្រង់។

មាន**ការមកនៅខាងក្នុងតែ១គត់របស់ព្រះ** ហើយនោះគឺនៅពេលព្រះយេស៊ូទទួលបុណ្យជ្រមុជទឹក។ **ដូច្នេះ នៅក្នុងកំឡុងពេល ដែលទ្រង់រស់នៅបាន ៣០ឆ្នាំ មុនទទួលពិធីជ្រមុជទឹកព្រះយេស៊ូមិនមែនជាព្រះដ៏មានគ្រប់ព្រះចេស្តាមកនៅខាងក្នុងទេ (ឬព្រះបន្ទូលមកនៅក្នុងទ្រង់)។ ទ្រង់គ្រាន់តែជាមនុស្សម្នាក់ ជាកូនរបស់ព្រះ** ដូចអ័ដាមជាមនុស្សដែលអត់មានបាបមុនពេលគាត់ធ្លាក់ទៅក្នុងអំពើបាបដែរ។ (**វិញ្ញាណ នៃព្រះយេស៊ូគ្រីស្ទ** គឺជា**សែនតែ១**ចេញពីព្រះមក ប៉ុន្តែ**វិញ្ញាណនៃអ័ដាម** និង**វិញ្ញាណនៃកូនដែលប្រោសលោះហើយទាំងអស់របស់ព្រះ** គ្រាន់តែជា***សែនជាច្រើន*** ចេញពីព្រះប៉ុណ្ណោះ)។ ហើយដោយសារទ្រង់បានយាងចេញមកពីព្រះអស់កល្បផ្ទាល់ ព្រះយេស៊ូគ្មានបាបសោះ គឺទ្រង់បានគ្រប់លក្ខណ៍។ ទ្រង់មានជីវិតអស់កល្ប នៅក្នុងទ្រង់។ បើសិនជាទ្រង់មិនបានដាក់ជីវិតទ្រង់នៅកាល់វ៉ារីទេ នោះទ្រង់នឹងនៅតែរស់នៅលើផែនដីមកដល់សព្វថ្ងៃនេះ និងមានអាយុជិត២០០០ឆ្នាំ ផង។

ដូច្នេះ ពេលទ្រង់ចាប់មានអាយុ ៣០ ឆ្នាំដំបូង ទ្រង់គ្រាន់តែជាបុរសម្នាក់នៅចំណោមពួកមនុស្សប៉ុណ្ណោះ។ នៅក្នុងកំពុងពេលនេះ ទ្រង់បានរៀនពីព្រះវិញ្ញាណបរិសុទ្ធនៃព្រះ ពេលដែលទ្រង់បានដើរនៅក្នុងជំនឿអ័ប្រាហាំ អ៊ីសាក និងយ៉ាកុប។ **ទ្រង់បានចំរើនធំឡើង ទ្រង់បានរៀនៈ**

"*ឯព្រះឱរស ក៏កាន់តែមានវ័យចំរើនធំឡើង មានកំលាំងខាងវិញ្ញាណរឹតតែច្រើនឡើងប្រកបដោយប្រាជ្ញដ៏ពោរពេញ ហើយព្រះគុណនៃព្រះក៏សណ្ឋិតលើទ្រង់ផង*" (លូកា២:៤០)។

ផ្នែកខាងក្រៅ គ្មានអ្វីពិសេសសោះចំពោះទ្រង់- "*ទ្រង់ឥតមានទ្រង់ទ្រាយល្អ ឬសណ្ឋានរុងរឿងទេ នោះក៏គ្មានភាពលំអណា ដែលឲ្យយើងរីករាយចិត្តដែរ*" (អេសាយ ៥៣:២ខ)។

"*ព្រះយេស៊ូក៏កាន់តែធំប្រកបដោយប្រាជ្ញរឹតតែច្រើនឡើង ហើយជាទីគាប់ព្រះហឫទ័យដល់ព្រះ និងចិត្តមនុស្សផង*" (លូកា ២:៥២)។

ទោះបើជា "**កូនរបស់ព្រះ**" ក៏ដោយ ក៏ព្រះយេស៊ូត្រូវតែចំរើនធំឡើងក្នុងព្រះបន្ទូល មុនពេលទ្រង់អាចត្រូវបានប្រកាសថា ជាព្រះរាជបុត្រានៃព្រះ ។

## ហ៊ុយអូទីសៀ ( Huiothesia )

បន្ទាប់មក បានចូលដល់ថ្ងៃ ដែលទ្រង់ជា "**កូនចិញ្ចឹម**" (ពាក្យក្រិតៈ ហ៊ុយអូទីសៀ-**តាំងជាកូន** មានន័យថា ភាពជាកូនបានមក ខុសពីទំនាក់ទំនងតាម

ឡូហ្គុស: ការចាប់ផ្ដើមដំបូងនៃការបង្កើតរបស់ព្រះ

កតាមកំណើតប៉ុណ្ណោះ ជាធម្មតាត្រូវធ្វើឡើងជាចំហ។ សូមមើល កាឡាទី៤: ៥)។ គឺជាតាំងឡើងទុកជាមុន ដើម្បីសំដែងនៅពេលទ្រង់ទទួលបុណ្យជ្រមុជទឹក ពេលទ្រង់មានអាយុប្រហែលជា ៣០ឆ្នាំ។ នៅថ្ងៃនោះ ផ្ទៃមេឃបានបើកចំហ ហើយព្រះវិញ្ញាណដ៏មានគ្រប់ព្រះចេស្ដា បានយាងចុះមកសណ្ឋិតលើទ្រង់ហើយបានគង់នៅក្នុងទ្រង់។ **ព្រះបានយាងមកនៅខាងក្នុង មនុស្សយេស៊ូ-អេម៉ាញូអែល-ព្រះគង់នៅជាមួយយើងក្នុងសាច់ឈាម!** ច្រំណាំះ នឹងមានពេលមកជាឆាប់ ដែលសាតាំងនឹងមកនៅ ខាងក្នុងមនុស្សម្នាក់ ជាអាទទឹកព្រះគ្រីស្ទ (មេប្រឆាំងព្រះគ្រីស្ទ) ជាមនុស្សនៃបាប]។

"*កូនចិញ្ចឹម*" នេះបានប្រកាសថា ទ្រង់ជាអ្នកណា ហើយព្រះ ជាព្រះវរបិតារបស់ទ្រង់បានតាំងទ្រង់ឲ្យមានតំនែងនោះ។ នៅពេលព្រះបានមកគង់ខាងក្នុងព្រះយេស៊ូ ស្ថានសួគ៌មិនបានហូរមកទាំងអស់ពីព្រះវិញ្ញាណដ៏មានគ្រប់ព្រះចេស្ដានៃព្រះ ទៅក្នុងរូបកាយព្រះយេស៊ូទេ។ ប៉ុន្តែពួកអ្នកដែលជឿបែបនេះ គាំទ្រវាដោយខគម្ពីរនេះ (និងខ ស្រដៀងគ្នាជាច្រើនទៀត) ដោយគ្មានការយល់ដឹងសោះ

"*តើអ្នកមិនជឿថា ខ្ញុំនៅក្នុងព្រះវរបិតា ហើយព្រះវរបិតាគង់នៅក្នុងខ្ញុំឬអី អស់ទាំងពាក្យដែលខ្ញុំប្រាប់អ្នករាល់គ្នា នោះខ្ញុំមិនមែនប្រាប់ដោយអាងខ្លួនខ្ញុំទេ គឺជាព្រះវរបិតា ដែលគង់ក្នុងខ្ញុំ ទ្រង់ធ្វើការទាំងនោះវិញ*" (យ៉ូហាន ១៤: ១០-១១ខ)។

បើព្រះបានសណ្ឋិតនៅក្នុងព្រះយេស៊ូ ហើយថា ព្រះវរបិតាបានគង់ក្នុងទ្រង់ អញ្ចឹង ហេតុអ្វីបានជាព្រះយេស៊ូងើយទៅលើមេឃ នៅពេលទ្រង់បានអធិស្ឋាន(យ៉ូហាន ១៧:១, ១១:៤១)? [ចំណាំ គ្រីស្ទានខ្លះជឿយ៉ាងពិតប្រាកដថា ព្រះយេស៊ូបានអធិស្ឋានទៅព្រះវរបិតានៅក្នុងទ្រង់ឬទៅទ្រង់ផ្ទាល់ មានន័យថា ទ្រង់ផ្ទាល់ជាព្រះវរបិតា ( អស់កល្ប ) (គឺបានដាក់ខុសពាក្យនៅក្នុងអេសាយ ៩:៦ហើយ ]។

**ព្រះគឺជាជីវិត។ គ្មានជីវិតទេ នៅខាងក្រៅព្រះនោះ។** ដោយសារព្រះជាព្រះដ៏មើលមិនឃើញ (កូល៉ុស ១:១៥ សូមមើល អេសាយ ៤៥:១៥) នៅក្នុងការប្រឹក្សាផ្ទាល់របស់ទ្រង់ មុនពេលការចាប់ផ្ដើមនៃការបង្កើត ទ្រង់បានជ្រើសរើសទំរង់ដែលមើលឃើញដើម្បីសំដែងអង្គទ្រង់និងគង់ក្នុង **គឺព្រះបន្ទូល-រូបកាយ** ។ហើយដោយសារព្រះបន្ទូលនេះហើយ ដែលរបស់ទាំងអស់ត្រូវបានបង្កើតមក ពីព្រោះជីវិត នៅក្នុងព្រះបន្ទូល (យ៉ូហាន ១:៣-៤)។ **ព្រះបានដាក់វិញ្ញាណនៃជីវិតរបស់ទ្រង់ នៅក្នុងព្រះបន្ទូលរបស់ទ្រង់**(សូមមើល យ៉ូហាន ៦: ៦៣ , រ៉ូម៨:២-១០, ២កូរិនថូស ៣:៦, ភីលីព ២:១៦, ១យ៉ូហាន ១:១)។ ជីវិតរបស់ព្រះនៅក្នុងព្រះបន្ទូលរបស់ទ្រង់។ ដូច្នេះ គឺជាសេចក្តីពោរពេញនៃ

ព្រះបន្ទូលរបស់ព្រះ ដែលបំពេញមនុស្សយេស៊ូ។ ហើយព្រះបន្ទូលនៅកន្លែងណា នោះក៏មានព្រះ**វិញ្ញាណនៃព្រះ** ក៏មានជីវិតនៃព្រះដែរ។ នោះជារបៀបដែលព្រះវិញ្ញាណនៃព្រះបានសណ្ឋិតក្នុងព្រះយេស៊ូគ្រីស្ទ ហើយក៏នៅក្នុងយើង ពីព្រោះយើងបានទទួលព្រះបន្ទូលរបស់ទ្រង់។

*"ព្រះយេស៊ូមានបន្ទូលឆ្លើយថា តើគ្មានសេចក្តីចែងទុកមកក្នុងក្រឹត្យវិន័យរបស់អ្នករាល់គ្នាថា អញបាននិយាយថា ឯរាល់គ្នាជាព្រះឬអី? ដូច្នេះ បើទ្រង់បានហៅអ្នកទាំងនោះជាព្រះដែលព្រះបន្ទូលរបស់ព្រះអង្គបានឮដល់គេហើយ បើលើកចោលបទគម្ពីរណាមិនបាន នោះតើអ្នករាល់គ្នានិយាយមកខ្ញុំនេះ ដែលព្រះវរបិតាញែកជាបរិសុទ្ធ ហើយចាត់មកក្នុងលោកីយ៍ ថាខ្ញុំពោលពាក្យប្រមាថដល់ព្រះ ដោយព្រោះតែខ្ញុំនិយាយថា ខ្ញុំជាព្រះរាជបុត្រានៃព្រះដូច្នេះឬអី?"*(យ៉ូហាន ១០:៣៤-៣៦)។

**ព្រះវិញ្ញាណនៃព្រះគង់នៅក្នុងព្រះបន្ទូលរបស់ទ្រង់ ប៉ុន្តែព្រះបានគង់នៅពន្លឺរបស់ទ្រង់ផ្ទាល់ នៅក្នុងស្ថានសួគ៌។**

សាវកប៉ូលបាននិយាយថា ព្រះយេស៊ូគ្រីស្ទជា ***"រោងឧបោសថគ្រប់លក្ខណ៍ ដែលមិនបានធ្វើដោយដៃ"*** (ហេព្រើរ ៩:១១) រោងឧបោសថរបស់ម៉ូសេ បានធ្វើដោយផ្ទាល់ដៃរបស់ពួកកូនចៅអ៊ីស្រាអែល។ គឺពួកគេបានចំណាចពេលអស់ ៩ខែ ដើម្បីបញ្ចប់ការសាងសង់រោងឧបោសថ។(អាននិក្ខមនំ ២៥-២៩, ៣៥-៤០)។ ហើយនៅថ្ងៃដែលបានកំនត់ទុក និងពេលវេលា ដែលអ្វីៗទាំងអស់បានរួចជាស្រេច ហើយរោងឧបោសថក៏បានសង់ឡើង ***"ពពកក៏គ្របត្រសាលជំនុំ ហើយសិរីល្អនៃព្រះអម្ចាស់បានសណ្ឋិតនៅពេញរោងឧបាសថ"*** (និក្ខមនំ ៤០:៣៤)។ស្តេខិណាសិរីល្អ បានយាងចុះមកសណ្ឋិតនៅលើហឹបនៃសេចក្តីសញ្ញា ជាកន្លែង ដែលដាក់ព្រះបន្ទូលនៃជីវិតបន្ទះថ្ម២ផ្ទាំងនៃសេចក្តីសញ្ញា ចានដាក់នំម៉ាន៉ា ក៏មានដំបងរបស់លោកអើរ៉ុន ដែលប៉ិចឡើង( ហេព្រើរ ៩:៤)។ដូចគ្នាដែរ ព្រះយេស៊ូត្រូវបានរៀបចំឡើង និងសង់ឡើងរហូតដល់ថ្ងៃ និងពេលកំនត់ទុក នៅពេលដែលទ្រង់បានទទួលបុណ្យជ្រមុជទឹកក្នុងទន្លេយ័ដាន់។ ពេលទ្រង់ងើបពីក្នុងទឹកឡើង ហើយបានឈរនៅក្នុងទន្លេ ផ្ទៃមេឃបានបើកចំហ ហើយ**ស្តេខិណាសិរីល្អនៃព្រះបានយាងចុះមក ហើយបានគង់ក្នុងទ្រង់ជារោងឧបោសថ** (ម៉ាកុស ១:៩-១១, យ៉ូហាន ១:១៤ សូមមើល ម៉ាឡាគី ៣:១) ។





និមិត្តសញ្ញានៃព្រះត្រៃឯក ពេលដែលវាលេច
មកនៅក្នុងវិហារកាតូលិកនៅក្រុងតាញ៉ុង
ប្រទេសបារាំង។

ឥឡូវ បើព្រះយេស៊ូវ ឬព្រះបន្ទូល គឺជា ព្រះទី២ ដែលគង់នៅរួមជាមួយនឹងព្រះវិញ្ញាណដ៏មានគ្រប់ព្រះចេស្តា(មានន័យថា ព្រះវរបិតា) ហើយថាទ្រង់បានក្លាយមកជាសាច់ឈាមមែនទែន (មានន័យថាបានប្រែពីព្រះវិញ្ញាណមកសាច់ឈាម) ហើយជាព្រះពេលជាទារកនោះអញ្ចឹង ត្រូវតែសរុបថា ព្រះមកគង់ក្នុងព្រះ។ តើនោះមានក្នុងបទគម្ពីរឬទេ?

ពេងឧបោសថរបស់ម៉ូសេ ជាស្រមោលនៃមនុស្សម្នាក់ ដែលព្រះដ៏មានគ្រប់ព្រះចេស្តាបំផុត នឹងយាងមកគង់ជាពេងឧបោសថនោះ-"**ព្រះបានមកគង់ក្នុងសាច់ឈាម (មនុស្ស) ជាពេងឧបោសថ**" ឬដូចសាវកប៉ូលបានសរសេរ "**ព្រះបានគង់ក្នុងព្រះគ្រីស្ទ(ដែលមានប្រេងតាំង)**"(២កូរិនថូ៥:១៩)ព្រះយេស៊ូគ្រីស្ទ បានទទួលប្រេងតាំងពីព្រះវិញ្ញាណបរិសុទ្ធ ដែលដាក់ព្រះបន្ទូលរបស់ទ្រង់ក្នុងព្រះយេស៊ូ សំរាប់ការងាររបស់ព្រះ។

**យ៉ូហាន-បាទីស្ទមិនបានឃើញបុគ្គល៣នៃព្រះ នៅឯបុណ្យជ្រមុជទឹកទេ** (ដូចជាពួកជឿព្រះត្រៃឯកបង្ហាញថា គាត់បានឃើញ)។ យ៉ូហានបានឮ សំលេង នៃព្រះ ហើយបានឃើញព្រះវិញ្ញាណដ៏មើលមិនឃើញរបស់ព្រះ នៅក្នុងទំរង់នៃព្រាបយាងចុះមកពីស្ថានសួគ៌ ហើយគងក្នុង**ព្រះយេស៊ូ**។ បន្ទាប់មកព្រះយេស៊ូបានពេញដោយព្រះវិញ្ញាណបរិសុទ្ធ ***ដោយឥតកំរិត*** ហើយព្រះវរបិតាបានដាក់គ្រប់របស់***ទាំងអស់*** មកក្នុងព្រះហស្តទ្រង់ (លូកា៤:១),យ៉ូហាន ៣:៣៤-៣៥)។ហើយក្នុងនាមជាព្រះគ្រីស្ទនៃព្រះអម្ចាស់ ទ្រង់ត្រូវតែទទួលការល្បួងដោយអារក្ស និងទ្រង់ត្រូវតែសំដែង*ការគិត* និង*ព្រះហឫទ័យ* របស់ព្រះវរបិតាអស់កល្ប។

(ចំណាំះ ជាក់ស្តែង ព្រះយេស៊ូ បានពេញដោយព្រះវិញ្ញាណបរិសុទ្ធ មុនបុណ្យជ្រមុជទឹក (ដូចពួកបរិសុទ្ធជាច្រើនទៀតរបស់ព្រះដែរ) ប៉ុន្តែមិនមែនមានន័យថា ទ្រង់ជាព្រះមកនៅខាងក្នុង ដូចពួកជឿព្រះត្រៃឯកខ្លះបានប្រកែកនោះទេ។ គឺបានថែងថា យ៉ូហាន-បាទីស្ទបានពេញជាព្រះវិញ្ញាណមុន

ដែលគាត់កើតទៅទៀត (លូកា១:១៥) ប៉ុន្តែគាត់មិនមែនព្រះទេ។ បន្ទាប់ពីថ្ងៃបុណ្យទី៥០(ប៉ង់តាកូស)ក៏បាន *"ពេញព្រះវិញ្ញាណបរិសុទ្ធ"* ផងដែរ(កិច្ចការ ៦:៣-៥ ៧:៥៥ ១១:២៤) ប៉ុន្តែពួកគេមិនមែនជាព្រះទេ។ ខ ទាំងនេះ-លូកា ៤:១ និងយ៉ូហាន៣:៣៤-៣៥ គូសបញ្ជាក់យ៉ាងច្បាស់ថា ព្រះយេស៊ូ ជានរណា និងជាអ្វី បន្ទាប់បីបានទទួលបុណ្យជ្រមុជទឹករួច-១) **ទ្រង់បានពេញជាព្រះវិញ្ញាណបរិសុទ្ធ ឥតកំរិតនិង ២)ព្រះបានប្រតានគ្រប់ទាំងអស់មកក្នុងព្រះហស្តទ្រង់។)**

ព្រះគ្រីស្ទយេស៊ូមានពេញដោយលក្ខណៈនៃព្រះ ហើយទ្រង់ត្រូវយាងមកសំរេចគ្រប់សេចក្តី ដែលបានចែងទុកពីទ្រង់។ (ចូរចងចាំ ទ្រង់មិនបានធ្វើការអស្ចារ្យ មុនពេលទទួលបុណ្យជ្រមុជទឹកទេ)។ ហើយអ្នកណាដែលពិតជាបានឃើញព្រះ គ្រីស្ទ នោះក៏បានឃើញព្រះវរបិតាអស់កល្បដែរ (យ៉ូហាន ១៤:៩) ដ្បិតព្រះវរបិតាអស់កល្ប បានគង់ក្នុងសាច់ឈាមនោះ (យ៉ូហាន១៤:១០,អេសាយ ៩:៦)។ ***ព្រះយេស៊ូគឺជាព្រះលេចមកក្នុងសាច់ឈាម*** (១ធីម៉ូថេ ៣:១៦)ព្រះបានធ្វើការតាមរយៈព្រះយេស៊ូ ការងាររបស់ព្រះយេស៊ូ បានប្រកាសថា ព្រះបានកង់ក្នុងទ្រង់។ ***ទ្រង់ជាការគិត (ឡូហ្គុស) ដែលសំដែងចេញរបស់ព្រះ។ ទ្រង់ជាមនុស្សដ៏ជាព្រះ ព្រះដែលមកគង់នៅខាងក្នុង ។*** ទ្រង់ក៏បានក្លាយជាអ្នកសង្គ្រោះរបស់យើង ដូច្នេះ យើងត្រូវតែជឿក្នុងទ្រង់ ដើម្បីទទួលចិត្តថ្មី វិញ្ញាណថ្មី និងទទួលការប្រោសលោះ (អេសាយ ៣៦:២៦-២៧, កិច្ចការ ១៦:៣១, ទំនុក ២:១២ )។ *"ឯអ្នកណាដែលជឿដល់ព្រះរាជបុត្រា នោះមានជីវិតដ៏នៅអស់កល្បជានិច្ចហើយ តែអ្នកណាដែលមិនព្រមជឿដល់ព្រះរាជបុត្រាវិញឃើញជីវិតសោះឡើយ"* (យ៉ូហាន ៣៣៦) ពីព្រោះទ្រង់ជាព្រះបន្ទូលនៃព្រះ សំដែងចេញ។ **ការបង្កើតឡើងនៃទំនាក់ទំនងព្រះវរបិតា-ព្រះរាចបុត្រា (ដែលចាប់ផ្តើមនៅបេថ្លេហិម) ធ្វើឲ្យយើងអាចទៅជាអ្នកជឿកើតជាថ្មីជាកូនប្រុស និងកូនស្រីរបស់ព្រះដ៏មានព្រះជន្មរស់ តាមរយៈព្រះរាជបុត្រារបស់ព្រះផ្ទាល់** (ទំនុក ៨៩:២៦-២៧, អេភេសូ ១:៥, ២កូរិន ៦:១៨) ។ភាពជាព្រះវរបិតានៃព្រះបានលេចមកនៅក្នុងព្រះរាជបុត្រានៃព្រះដូច្នេះ មុខងារ *"ព្រះវរបិតាអស់កល្ប"* (អេសាយ ៩:៦)។

## នៅក្នុងទ្រង់មានជីវិត

សូមអង្កេតការនេះឲ្យបានច្បាស់។ សាវក យ៉ូហាន បានប្រកាសថា *"ព្រះបន្ទូលក៏បានគង់ជាមួយនឹងព្រះ...ហើយព្រះបន្ទូលនោះឯងជាព្រះ នៅក្នុងទ្រង់មានជីវិត ហើយជីវិតនោះ គឺជាពន្លឺនៃមនុស្សលោក"* (យ៉ូហាន១:២.៤)។ ព្រះបន្ទូល ដែលបានចេញមកពីព្រះគឺជាជីវិតផ្ទាល់។ ជីវិតនៃព្រះបន្ទូល គឺជាពន្លឺនៃមនុស្សលោក។ ***ជីវិតមិនបានប្រទានមកទ្រង់ទេ គឺទ្រង់ផ្ទាល់គឺជាជីវិត ។***

ឡូហ្គុស: ការចាប់ផ្ដើមដំបូងនៃការបង្កើតរបស់ព្រះ

ទោះបីយ៉ាងណាក៏ដោយ ***វាមិនមែនមានបែបដូចជាព្រះយេស៊ូវទេ*** ដែលមានបន្ទូលថា:

*"ពីព្រោះដែលព្រះវរបិតាមានជីវិតក្នុងព្រះអង្គទ្រង់យ៉ាងណា នោះទ្រង់ក៏ប្រទានឲ្យព្រះរាជបុត្រាមានជីវិត ក្នុងព្រះអង្គទ្រង់យ៉ាងណា នោះដែរ" (យ៉ូហាន ៥:២៦)។*

**ព្រះយេស៊ូមិនមានជីវិតនៅក្នុងព្រះអង្គទ្រង់ទេ។ គឺព្រះជាព្រះវរបិតាដែលបានប្រទានឲ្យទ្រង់មានអំណាច ដើម្បីមានជីវិតក្នុងព្រះអង្គទ្រង់។** បាទព្រះយេស៊ូបានទទួលអំណាចនៃជីវិតពន្លឺនៃជីវិត។ **ដូច្នេះ នេះច្បាប់ហើយថា *ព្រះបន្ទូលគឺជាព្រះ ព្រះបន្ទូល*** **មិនមែនជាព្រះយេស៊ូទេ។ ប៉ុន្តែព្រះយេស៊ូ *គឺជាព្រះបន្ទូល* ដែលសំដែងចេញ។ ពន្លឺនៃជីវិតបានយាងមកក្នុងលោកីយ៍នៅក្នុងព្រះយេស៊ូគ្រីស្ទ ។** ហេតុនេះហើយ បានជាព្រះយេស៊ូអាចប្រកាសថា:

*"ខ្ញុំជាពន្លឺលោកីយ៍ អ្នកណាដែលតាមខ្ញុំ នោះមិនដែលដើរក្នុងសេចក្ដីងងឹតឡើយ គឺនឹងមានពន្លឺនៃជីវិតវិញ" (យ៉ូហាន ៨:១២)។*

ដូចបានលើករួចមកហើយ សូមឲ្យខ្ញុំបង្ហាញអ្នកនូវការប្រើប្រាស់ពាក្យជាក់លាក់ ខ្លះនៅ ក្នុងខ មួយចំនួនតូច ដូចបានដាក់ដោយព្រះវិញ្ញាណទាក់ទងនឹងការចាប់កំណើតនៃព្រះយេស៊ូភាពក្មេងវ័យនិងភាពចាស់ទុំ:

អេសាយ ៩:៦-*"ដ្បិតមានបុត្រ១បានកើតមក ហើយបុត្រា១បានប្រទានមក..."*

លូកា ២:៤០-*"ឯព្រះឱរសក៏កាន់តែមានវ័យចំរើនឡើង មានកំលាំងខាងវិញ្ញាណរឹតតែច្រើនឡើង ប្រកបដោយប្រាជ្ញាដ៏ពោរពេញ ហើយព្រះគុណនៃព្រះក៏សណ្ឋិតលើទ្រង់ផង..."*

លូកា ២:៥២-"ព្រះយេស៊ូក៏កាន់តែធំ ប្រកបដោយប្រាជ្ញារឹតតែច្រើនឡើង ហើយជាទីគាប់ព្រះហឫទ័យដល់ព្រះ និងចិត្តមនុស្សផង

អេសាយ ៦១:១-*"ព្រះវិញ្ញាណនៃព្រះអម្ចាស់យេហូវ៉ា ទ្រង់សណ្ឋិតលើខ្ញុំ ពីព្រោះទ្រង់បានចាក់ប្រេងតាំងខ្ញុំឲ្យផ្សាយដំណឹងល្អដល់មនុស្សទាល់ក្រ ទ្រង់បានចាត់ខ្ញុំឲ្យមក..."*

យ៉ូហាន ៣:១៦-"ដ្បិតព្រះទ្រង់ស្រលាញ់មនុស្សលោកដល់ម្លេះ បានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឲ្យអ្នកណាដែលជឿលើព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ..."

យ៉ូហាន ៣:១៧-*"ពីព្រោះព្រះទ្រង់មិនបានចាត់ព្រះរាជបុត្រាទ្រង់ ឲ្យមកក្នុងលោកីយ៍..."*

យ៉ូហាន ២០:២១-"ដូចព្រះវរបិតាបានចាត់ឲ្យខ្ញុំមកដែរ..."

ម៉ាថាយ ២១:៣៧-"ដល់ក្រោយបង្អស់ គាត់ចាត់កូនគាត់ឲ្យទៅ..."

យ៉ូហាន ៣:៣៤-៣៥-*"ដ្បិតព្រះអង្គ ដែលព្រះបានចាត់ឲ្យមក ទ្រង់មានបន្ទូល តាមព្រះបន្ទូលនៃព្រះ ពីព្រោះព្រះ មិនប្រទានព្រះវិញ្ញាណមកដោយមានកំរិតទេ ឯព្រះវរបិតា ទ្រង់ស្រឡាញ់ព្រះរាជបុត្រា ហើយបានប្រគល់គ្រប់ទាំងអស់ មកក្នុងព្រះហស្តទ្រង់..."*

ច្បាស់ណាស់ថា **ព្រះយេស៊ូមិនបានកើតមក ជាព្រះរាជបុត្រាទេ។ ទ្រង់កើតមកជាទារកហើយចំរើនធំឡើងជាក្មេង និងចំរើនខាងប្រាជ្ញាពេលដែលទ្រង់បានរៀន។** ជាព្រះរាជបុត្រាទ្រង់បាន ប្រេងតាំងពេញដោយលក្ខណៈ នៃព្រះ និងបានទទួលខុសត្រូវអ្វីគ្រប់យ៉ាង ពីព្រះ។ **ទ្រង់ត្រូវបានចាត់មក និងប្រទានមកជាព្រះរាជបុត្រា ដើម្បីធ្វើជាអ្នកសង្គ្រោះមនុស្សលោក។** គ្មានការសង្ស័យទេ សេចក្តីពិតគឺថាព្រះយេស៊ូជាព្រះគ្រីស្ទ ត្រូវបានចាត់មក ជាមនុស្សចាស់ទុំ បន្ទាប់ពី ***"កូនចិញ្ចឹម"*** របស់ទ្រង់ ជាបុត្រា-ជាព្រះរាជបុត្រានៃព្រះ ហើយមិនមែនទារក (មើល*ហ៊ុយអូទីស៊ៀ* ខាងលើ)។ ជាបុត្រាចាស់ទុំហើយ ដែលបានរៀនយ៉ាងល្អពីព្រះវិញ្ញាណ។ បន្ទាប់មក ទ្រង់អាចអនុវត្តការងាររបស់ព្រះ ដើម្បីសំដែងព្រះនាមរបស់ទ្រង់ និងចែកចាយព្រះបន្ទូលរបស់ទ្រង់ (សូមមើល យ៉ូហាន ១៧:៣-៨) ។

ដូចគ្នាដែរ នៅពេលព្រះបានសង្គ្រោះយើង យើងបានទទួលព្រះវិញ្ញាណនៃព្រះរបស់ ព្រះរាជបុត្រស នៅក្នុងចិត្តរបស់យើង ដែលយើងអាចទទួល *"ការចិញ្ចឹម"* ជាកូន(កាឡាទី៤:៤-៧)។ ប៉ុន្តែនៅពេលណា យើងបានដឹងថាបាន *"ជាកូនចិញ្ចឹម?"* នៅពេលដែលយើងជារូបកាយនៃព្រះគ្រីស្ទ បានគ្រប់លក្ខណ៍ (សូមមើល អេភេសូរ ៤:៦-១២)ហើយរូបកាយរបស់យើងនឹងបានប្រោះលោះ។

*"មិនតែប៉ុណ្ណោះសោត ខ្លួនយើងរាល់គ្នាដែលមានផលជាដំបូងរបស់ព្រះវិញ្ញាណ ក៏ថ្ងូរក្នុងខ្លួនដែរ ទាំងរង់ចាំទំរាំ ការទទួលជាកូនចិញ្ចឹម គឺជាសេចក្តីប្រោសលោះដល់រូបកាយយើងផង"*(រ៉ូម ៨:២៣)។

នៅពេលការនេះកើតឡើង *"ការតទួលជាកូនចិញ្ចឹម"* នៃពួកបរិសុទ្ធនឹងកើតឡើងជា១ *"ការលេចមកនៃពួកកូនព្រះ"* (រ៉ូម ៨:១៩) នៅពេលដែលពួកគេបានទទួលតំណែងនៅក្នុង នគររបស់ព្រះ ដើម្បីគ្រប់គ្រងជាមួយព្រះគ្រីស្ទ នៅលើបល្ល័ង្ករបស់ទ្រង់ *នៅក្នុងយុគសម័យកែជំនាន់មនុស្សជាថ្មី។*

ច្រំណាំ នៅពេល*ពោងឧបោសថរបស់ម៉ូសេ បានបញ្ចប់ និងសង់ឡើងហើយ នៅចំពោះមនុស្ស ព្រះបានយាងចុះមក ហើយពន្លឺកិត្តិ៍*នពោង

ឡូហ្គុស: ការចាប់ផ្ដើមដំបូងនៃការបង្កើតរបស់ព្រះ

ឧបោសថបានចាប់ផ្ដើម។ នៅពេល*ព្រះរាជបុត្រានៃព្រះ ដែលបានចំរើនធំឡើង និងបានចាស់ទុំ ទ្រង់ក៏បានទទួលពិធីជ្រមុជទឹក។* នៅពេលដែលទ្រង់បានងើបពីទឹកឡើងវិញ ហើយបានឈរនៅទីនោះនៅចំពោះមនុស្ស ព្រះបានយាងចុះមក ហើយពន្ធកិច្ចនៃព្រះគ្រីស្ទបានចាប់ផ្ដើម។ នៅពេល*ដែលរូបកាយរួមនៃព្រះគ្រីស្ទ (ពួកជំនុំ) បានគ្រប់លក្ខណ៍ហើយបានសេចក្ដីប្រោសលោះដល់រូបកាយយើង* ព្រះគ្រីស្ទនឹងយាងមកប្រមូល អ្នកដែលបានប្រោសលោះទាំងអស់ សំរាប់ព្រះវរបិតា។ បន្ទាប់ពីព្រះគ្រីស្ទនឹងយាងត្រឡប់មកផែនដីវិញ ហើយបង្ហាញពួកគេជា*ភរិយា-កូនក្រមុំ* របស់ទ្រង់នៅក្នុងនគររបស់ទ្រង់។ ព្រះវិញ្ញាណដ៏មានគ្រប់ព្រះចេស្ដានិង*ចុះមក* ចាក់ប្រេងតាំងអ្នកដែលបានប្រោសលោះ និង "*ការលេចមកនៃពួកកូនព្រះ*" និងចាប់ផ្ដើម នៅពេលពួកគេ សោយរាជ្យជាមួយព្រះគ្រីស្ទ ១ពាន់ឆ្នាំ។)

## ការលេចមកជាបុគ្គល

ព្រះគ្រីស្ទ***ជាព្រះបន្ទូលដ៏រស់*** នៃព្រះបានមកជាបុគ្គល នៅក្នុងរបៀបផ្សេងៗ នៅក្នុងគម្ពីរទាំងមូល។ ក្នុងសុភាសិត ៨:២២ យើងឃើញព្រះ*កាន់កាប់* (បានបង្កើតមក ប្រមូលបាន សង់ឡើង នាំចេញមក ពាក្យក្រិក *កាណា*) ***ប្រាជ្ញា ជាមេជាង*** របស់ទ្រង់ដែល ជាទីគាប់ព្រះហឫទ័យ ទ្រង់រាល់ៗថ្ងៃ (សុភាសិត ៨:៣០)។ *ប្រាជ្ញា* នៃព្រះ គឺជា ***ព្រះចេស្ដា*** របស់ទ្រង់ក្នុង***គំនិតព្រះបន្ទូល*** និង***កិច្ចការ។*** ប៉ូលបានហៅ "***ព្រះគ្រីស្ទព្រះចេស្ដានៃព្រះ និងប្រាជ្ញានៃព្រះ***" (១កូរិនថូស ១:២៤)។ *ព្រះបន្ទូល* របស់ព្រះនិង*ប្រាជ្ញា*របស់ទ្រង់ជារឿយៗត្រូវបានគេប្រើជាន័យដូចគ្នា។*ប្រាជ្ញា* គឺ*ជាការបើកសំដែង* នៃព្រះចេស្ដារបស់ព្រះ ក្នុងការនាំចេញចាជីវិត។ នោះគឺជា***ឡូហ្គុស*** នៃព្រះ ដែលជាកត្ដាដែលបង្កើតចេញ។

គឺនាំចេញជា*វិញ្ញាណ* នៅក្នុងទំរង់នៃរូបកាយ ពេលព្រះបានគិតទុក ថាព្រះនឹងត្រូវបង្កើតឡើងនៅពេលក្រោយ នៅក្នុងរូបរាងដូចគ្នានឹងទំរង់រូបកាយនោះ មានភាពដូចជាទ្រង់ (លោកុប្បត្ដិ ១:២៦)។

ខាងក្រោមនេះ គឺជាការសំដែងចេញជាក់លាក់តិចតួច ដែលបង្ហាញថាព្រះបន្ទូលដែលចែងទុកជា***ការលេចមកជាបុគ្គលនៃព្រះគ្រីស្ទៈ***

សុភាសិត ៣:១៩- "*ព្រះយេហូវ៉ាបានប្រតិស្ឋានផែនដីដោយសារប្រាជ្ញា*"

យ៉ូហាន ១:៣- "*គ្រប់របស់ទាំងអស់បានកើតមកដោយសារទ្រង់ ហើយក្នុងបណ្ដារបស់ដែលបាបបង្កើតមកទាំងប៉ុន្មាន នោះគ្មានអ្វីណា១ កើតមកក្រៅពីទ្រង់ឡើយ*"

ទំនាយ ដែលបានបើកសំដែង

*សុភាសិត ១០:២៩-"ផ្លូវព្រះយេហូវ៉ា ជាបន្ទាយដល់មនុស្សទៀតត្រង់ (សុចរិត)*

*យ៉ូហាន ១៤:៦-(ព្រះយេស៊ូបានមានបន្ទូលថា) "ខ្ញុំជាផ្លូវ"*

---

ចោទិ ៨:៣-*"មនុស្សមិនមែនរស់ដោយសារនំប៉័ងប៉ុណ្ណោះទេ គឺរស់ដោយសារគ្រប់ទាំងព្រះបន្ទូលចេញពីព្រះឱស្ឋព្រះយេហូវ៉ាមកដែរ"*

យ៉ូហាន ៦:៣៣-*"នំប៉័ងរបស់ព្រះ គឺជាព្រះអង្គដែលយាងចុះពីស្ថានសួគ៌មក ព្រមទាំងប្រទានឲ្យមនុស្សលោក បានជីវិតផង"*

---

ទំនុក ៣៤:២០-*"ទ្រង់រក្សាអស់ទាំងឆ្អឹងរបស់អ្នកនោះ មិនឲ្យឆ្អឹងណា១ត្រូវបាក់ឡើយ"*។

យ៉ូហាន ១០:៣៥- (ព្រះយេស៊ូមានបន្ទូលថា) "*ដោយលើកចោទបទគម្ពីរណាមិនបាន"*

ដូច្នេះ សូម្បីតែបទគម្ពីររបស់ព្រះ គឺជាការសំដែងចេញពិតៗ អំពី***ព្រះគ្រីស្ទដ៏រស់*** នៅក្នុង***ព្រះបន្ទូលដែលចែងទុកមក។***

## ព្រះបន្ទូល

ពួកហេព្រើរ ដែលបទគម្ពីរបរិសុទ្ធបានប្រទានមក មិនបានមក មិនបានធ្វើឲ្យពាក្យ និងការប្រព្រឹត្តខុសពីគ្នាឡើយ។ (ឧ សូមអានលុកា៤:៣២, ម៉ាថាយ ១២:៣៤, ២របាក្សត្រ ២៩:៣០, សុភាសិត១០:១៩-២១) ។***ព្រះបន្ទូលនៃព្រះ ជារឿយៗ ត្រូវបានគេឃើញនិងបានឮ។*** នោះហើយជារបៀប ដែលព្រះបានសំដែងអង្គទ្រង់ នៅពេលខុសៗគ្នា និងច្រើនបែបច្រើនសារ ដល់ពួកភាជនះដែលបានរើសតាំងនៅក្នុងសម័យសញ្ញាចាស់។ ដោយគ្មានការសង្ស័យ យើងអាចឃើញថា *ព្រះបន្ទូល* (ពាក្យហេព្រើរ *ដេបារ*) នៃយេហូវ៉ា ដែលមកឬសំដែងដល់ពួកអ្នកបំរើនៃព្រះដ៏មានព្រះចេស្តាបំផុត (លោកុ ១៥:១ , ៤ ១សាំយ៉ូអែល ៣:៧ , ១របាក្សត្រ ១៧:៣)។ល។ )គឺជា*ព្រះបន្ទូល* ដដែល (ពាក្យក្រិត *ឡូហ្គុស*) បាននិយាយនៅក្នុង យ៉ូហាន១។

នៅពេលទ្រង់បានប្រឹក្សានៅក្នុងគំនិតរបស់ទ្រង់ នោះគឺជាបំណងព្រះហឫទ័យព្រះ ដើម្បីសំដែងអង្គទ្រង់ នៅក្នុងទំរង់រូបកាយ-*រូបកាយព្រះបន្ទូល*-ដូចជា*បុគ្គលម្នាក់* មិនមែនគ្រាន់តែជាពាក្យសំដីទេ។ ជាព្រះវិញ្ញាណដ៏មើលមិនឃើញ ទ្រង់បានសំដែងបុគ្គលិកលក្ខណះរបស់ទ្រង់ នៅក្នុងទំរង់ដ៏មើលឃើញនៃមនុស្ស ដោយ*ទីអូហ្វានី*។ គ្រប់*ទីអូហ្វានី* ទាំងអស់ គឺជាស្រមោលនៃរបស់ពិតដែលត្រូវមក។ ពួកគេជាស្រមោលពី*ព្រះមែស៊ី* ជា*ពូជសន្យា*នោះ (លោកុ ៣:១៥ ២២:១៨ កាឡាទី ៣:១៦.២៩) ដែលត្រូវមកសំរេចអស់ទាំងសេចក្តី

ដែលបានថ្លែង ឬចែងទុកពីទ្រង់។ ដូច្នេះ ពេលដែលពេលវេលាកំនត់បានមកដល់ ទ្រង់បានចាត់ព្រះបន្ទូលរបស់មកក្នុងលោកីយ៍ ដើម្បីសំដែងនៅក្នុងទំរង់ជាមនុស្ស។ គឺលែងបានសំដែងនៅក្នុង*រូបកាយ-ព្រះបន្ទូល* (ទីអូហ្វានី) ទៀត ហើយប៉ុន្តែនៅ*ក្នុងសាច់ឈាមពិតរបស់មនុស្សធំ* (មិនមែនទារក ឬក្មេង ព្រោះ*អស់ទាំងទីអូហ្វានី បនាលេចមកនៅក្នុងទំរង់មនុស្ស)* ដែលបានបង្កើតមកទាបជាងពួកទេវតាបន្តិច ដោយកើតមកតាមរយះភាជនះនៃស្រីព្រហ្មចារី ។ **ពេលព្រះបានសំដែងនៅក្នុងការគិត របស់ទ្រង់ នៅក្នុង*ទំរង់មនុស្ស* នៅតិអូហ្វានី ដូចគ្នាដែរ ទ្រង់បានសំដែងការគិត របស់ទ្រង់ នៅក្នុងភាពដូចគ្នា ដដែលរបស់មនុស្ស** (លោកុ ១:២៦) **នៅក្នុងសាច់ឈាមរូប-កាយអាចប៉ះបាន ដោយការចាប់កំណើត។** *មនុស្សនោះ* (យ៉ូហាន ១៩:៥) គឺជា*ការគិត ដែលសំដែងចេញពេញលេញរបស់ព្រះ* ហើយត្រូវបានហៅថា *ព្រះបន្ទូលនៃព្រះ*គឺដូចជា*ការគិត ដែលសំដែងចេញពេញលេញរបស់ព្រះ* ហើយត្រូវបានហៅថា ព្រះបន្ទូលនៃព្រះ គឺដូចជាការគិត *ដែលសំដែងចេញពេញលេញរបស់ព្រះត្រូវបានសំដែងក្នុងនិងតាមរយះរូបកាយព្រះបន្ទូល* នៅក្នុងការចាប់ផ្តើមដំបូង។ ព្រះយេស៊ូគ្រីស្ទ គឺជា**មនុស្សតែម្នាក់គត់** ដែលមាន**សេចក្តីពោរពេញនៃព្រះដ៏ជាកំពូល** *ដែលសណ្ឋិតនៅក្នុងទ្រង់ទាំងមានរូបអង្គផង។*

ក្នុង*ការបង្កើត* មនុស្សរបស់ទ្រង់ ព្រះបានប្រទានជីវិតដល់មនុស្សតាមរយះ*ព្រះបន្ទូល។* នៅក្នុង*ការប្រោសលោះ*មនុស្សរបស់ទ្រង់ ព្រះបានបង្កើតទ្រង់ជាថ្មីសំរាប់ជីវិតអស់កល្បជានិច្ចតាមរយះ*ព្រះបន្ទូល*ដដែល។ *"ព្រះបាននៅក្នុងព្រះគ្រីស្ទ (ព្រះបន្ទូលនៃព្រះ) កំពុងផ្សះផ្សាលោកីយ៍នឹងព្រះអង្គទ្រង់"* (២កូរិនថូស ៥:១៩)។

## បុគ្គល និងបុគ្គលិកលក្ខណះ

គួរតែបានច្បាស់លាស់ឥតខ្ចោះហើយថា មុននឹងយាងមកផែនដីជិត ២០០០ ឆ្នាំកន្លងទៅនេះ មនុស្សយេស៊ូគ្រីស្ទ មិនបានគង់នៅរួចមកហើយទេ **ទ្រង់គឺជាសេចក្តីអាថ៌កំបាំងដ៏លាក់កំបាំងរបស់ព្រះ ដែលបានយាងចេញមកពីគំនិតរបស់ព្រះ មុនអ្វីៗបានកើតមកទៅទៀត ដើម្បីសំដែងបុគ្គលិកលក្ខណះនៃព្រះ។** ដូច្នេះព្រះយេស៊ូ គឺជា*ឡូហ្គុស (ព្រះបន្ទូល)* នៃព្រះ លេចមកក្នុងសាច់ឈាម *"ទ្រង់ក៏ទ្រង់ព្រះពស្ត្រជ្រលក់ដោយឈាម ហើយព្រះនាមទ្រង់ទ្រង់ហៅថា ព្រះបន្ទូលនៃព្រះ"* (វិវរណះ ១៩:១៣ កូល៉ុស ១:១៩. ២៩ )។ គឺជាព្រះបន្ទូលទេដែលបានគង់នៅពីមុនរួចទៅហើយនោះ ។ គឺបានចេញពីព្រះវិញ្ញាណដ៏មានព្រះចេស្តាបំផុត (មានឫទ្ធិ) តាំងពីកាលដើមដំបូង (ការចាប់ផ្តើម)ម្ល៉េះ ជា *"ការចាប់ផ្តើមនៃការបង្កើតរបស់ព្រះ"* និងជា *"បងច្បងនៃរបស់ទាំងអស់"* ។

មិនថា គេជឿលើ បុគ្គល ១ ២ ឬ ៣ ក្នុងព្រះដ៏ជាកំពូលទេ គ្រីស្ទានភាគច្រើនគិតថា ព្រះគឺជា*បុគ្គល*។ ដោយសារតែបទគម្ពីរត្រូវបានសរសេរឡើងតាមរបៀបនោះ និង***ប្រើពាក្យដាក់លាក់***ផ្សេងៗគ្នា នោះពួកជឿព្រះត្រៃឯកបានសន្និដ្ឋានខុសថា មាន*បុគ្គលរួមស្មើគ្នាដាច់ដោយ ឡែក ៣ នៃសារធាតុ ដែលមានអត្តសញ្ញាណដូចគ្នា* នៅក្នុងព្រះដ៏ជាកំពូល ហេតុនោះហើយ នាំឲ្យបង្កើតបានជា***ព្រះ៣នៅក្នុងបុគ្គល៣។*** ផ្ទុយទៅវិញ ពួកអ្នកជឿនិកាយវាន់នែស(Oneness)បានគាំទ្រង គោលលទ្ធិ*បុគ្គល-២* ជាយូរមកហើយ ដែលបង្រៀនថា*ឡូហ្គុស* គឺជាបុគ្គល១និងព្រះជាបុគ្គល១ទៀត ឬថា *ព្រះយេស៊ូគ្រីស្ទ*គឺចាបុគ្គល១ និងព្រះដ៏មានគ្រប់***ព្រះចេស្តា***ជាបុគ្គល១ទៀត ។

ច្រំណាំ ក្រុមព្រះត្រៃឯកខ្លះ ខំបង្ហាញភស្តុតាងថា ការប្រើពាក្យ*បុគ្គល* ដែលជំនួសឲ្យ ពាក្យ *'ភើរសូណា'*។ប៉ុន្តែការប្រើពាក្យ *ភើរសូណា* 'ដែលមានន័យថា' *របាំងមុខដែលអ្នកសំដែងប្រើតួអង្គម្នាក់ បានចេញសកម្មភាព*ការពិតផ្ទុយនិងសម័យរបស់ខ្លួននៃបុគ្គល៣នៃព្រះត្រៃឯក ថាជាបុគ្គលខុសពីគ្នា នឹងដាច់ដោយឡែកពីគ្នា ដែលបុគ្គលម្នាក់ៗ មានបំនងផ្ទាល់ខ្លួន ។ ទោះបីជាព្រះមិនបានលេចមកក្នុង*ភើរសូណា* នៃ**មិុលគីស្សាដែក** ឲ្យអ័ប្រាហាំបានឃើញ និង**ទេវតានៃព្រះអម្ចាស់**ផងដែរដែលបោកចំបាប់ជាមួយយ៉ាកុបនោះ ទ្រង់នៅតែជាព្រះតែ១ដដែលមិនមែន៣ទេ ។]

ដើម្បីឲ្យបានយល់ច្បាស់ យើងត្រូវពិនិត្យមើលអត្ថន័យនៃពាក្យទាំង២នេះ គឺពាក្យ '*បុគ្គល*' និង '*បុគ្គលិកលក្ខណៈ*'។ វចនានុក្រមភាពច្រើន ផ្តល់អត្ថន័យគ្រឹះនៃពាក្យទាំង២ ដូចខាងក្រោមនេះ

**បុគ្គល-១**) មនុស្ស ២) បុគ្គល

៣) បុគ្គលិកលក្ខណៈផ្ទាល់ខ្លួនពិតរបស់នរណាម្នាក់

៤) រូបកាយនៃមនុស្ស ការលេចមកខាងរូបកាយ

(ក្រៅពីមានរូបកាយមើលឃើញ បុគ្គលក៏មានបញ្ញាខាងវិញ្ញាណផងដែរ)។

**បុគ្គលិកលក្ខណៈ**-១) ចំនួនគុណភាពនៃគំនិត និងអត្តចរិករបស់នរណាម្នាក់

២) ភាពជាបុគ្គល អត្តសញ្ញាណផ្ទាល់ខ្លួន

មិនអាចបដិសេធបានទេ ថា ព្រះដ៏មានចេស្តាបំផុត មាន **បុគ្គលិកលក្ខណៈ។** យើង អាចឃើញលក្ខណៈផ្សេងៗនៃបុគ្គលិកលក្ខណៈ ពេលដែលទ្រង់សំដែងអង្គទ្រង់ នៅក្នុងបទគម្ពីរទាំងមូល។ ទោះបីយ៉ាងណាក៏ដោយ **ព្រះមិនមែនជាបុគ្គលទេ** តែមនុស្សជាបុគ្គល។ **ព្រះ គឺជាវិញ្ញាណ**។ គឺមានចែងយ៉ាងច្បាស់ នៅក្នុងយ៉ូហាន ៤:២៤ និងអេភេសូរ ៤:៤ ។

ឡូហ្គុស: ការចាប់ផ្ដើមដំបូងនៃការបង្កើតរបស់ព្រះ

សូមមើលការបំភ្លឺ១។ យើងដឹងថា សត្វមិនមែនជា*បុគ្គលទេ* ប៉ុន្តែសត្វដូចជាសាឌី មានបុគ្គលិកលក្ខណះច្បាស់លាស់ (នោះគឺ ចំនួនគុណភាពនៃគំនិត និងអត្តចរិករបស់វា)។

***បុគ្គលិកលក្ខណះនៃព្រះវិញ្ញាណរបស់ ព្រះបានលេចមកនៅក្នុងបុគ្គល-បុគ្គលយេស៊ូគ្រីស្ទ***ដូចជាទ្រង់បានសំដែងអង្គទ្រង់នៅទំរង់ដូច "*បុគ្គល*នៃព្រហបន្ទូល (រូបកាយ) កាលពីដើមដំបូង។ នៅក្នុង ហេព្រើរ ១:៣ បានចែងថា ព្រះយេស៊ូគ្រីស្ទ គឺជា *"រូបភាពនៃបុគ្គលទ្រង់"។* ពាក្យ *"បុគ្គល"* គឺជាការបកប្រែខុសទេ។ ពាក្យក្រិតគឺ *"ហ៊ិបប៉ូតាស្តាស៊ីស"* មានន័យថាជា *"សារធាតុ អ្វីដែលមាននៅ និស្ស័យពិត"។* ដូច្នេះ **ព្រះយេស៊ូ គឺជារូបភាពសំដែងចេញនៃសារធាតុ ឬនិស្ស័យ របស់ព្រះ។បញ្ជាក់យ៉ាងសាមញ្ញថាអ្នកសង្គ្រោះ គឺជាបុគ្គល នៃព្រះ។** បុគ្គលិកលក្ខណះនៃព្រះ បានសំដែង និងលេចមកនៅក្នុងទ្រង់

[ចំណាំ ពួកទេវតាព្រះមិនមែនជាពួកមនុស្សលោកទេ ដូច្នេះ ពួកគេមិនមែនជាបុគ្គលទេ *ភើ ស៊ី។* ពួកគេត្រូវបានបង្កើតមកជាតួវិញ្ញាណ (ទំនុក ១០៤:៤ ហេព្រើរ ១:៧ )។ ទោះបីជាពេលខ្លះ ពួកគេសំដែងអង្គពួកគេ នៅក្នុងទំរង់មនុស្ស ដូចជាពេលទេវតា២នាក់និងអេឡូហ៊ីម(អេឡូអ៊ីម) បានលេចមកឲ្យអ័ប្រាហាំឃើញ (ក្នុងលោកុ ១៨) ក៏ដោយ ក៏ពួកគេមិនមែន ជាបុគ្គលដែរ ភើ វៀដ ។ ព្រះជាវិញ្ញាណ។ ពួកទេវតា គឺជាវិញ្ញាណ។]

## និស្ស័យ២យ៉ាង

អ្វីដែលពិបាកយល់ជាងគេបំផុត គឺអំពីព្រះយេស៊ូគ្រីស្ទជានរនា ប្រហែលនិស្ស័យ ***បុគ្គលិកលក្ខណះ*** របស់ទ្រង់។ ទោះបីយ៉ាងណាក៏ដោយ យើងពិតជាយល់ថា ដូចមនុស្សទាំងអស់ដែរទ្រង់ជាបុគ្គលម្នាក់ និងជាតួដាច់ដោយឡែកពីអង្គភាពនៃព្រះ។ ប៉ុន្តែ ចូរចាំថា ពីមុនពិធីជ្រមុជទឹក ទ្រង់គ្រាន់តែជា **មនុស្ស** គ្មានបាបប៉ុណ្ណោះ ដែលបានចេញពីស្ថានលើផ្ទាល់(យ៉ូហាន ៨:២៣) មិនមែនបានចេញពីយ៉ូសែបរួមរស់ជាមួយម៉ារីទេ។ ទ្រង់មានជីវិតអស់កល្បជានិច្ចព្រោះទ្រង់គ្មានបាបសោះ នៅក្នុងទ្រង់។ ទ្រង់មកពីព្រះ តែមិនមែនភាពជាព្រះទេ ។ ដូច្នេះ តាមនិស្ស័យ ទ្រង់មិនអាចស្លាប់ទេ ។ សេចក្ដីស្លាប់អាចធ្លាក់មកលើទ្រង់ ដោយការបង្ខំលើរូបកាយប៉ុណ្ណោះបើសិនជាព្រហអនុញ្ញាត្តការនោះ (លូកា ២៣:៤៦ យ៉ូហាន ១៩:១០-១១ក ១កូរិនថូស១៥:៣ ទ្រង់ត្រូវតែបរិភោគ ហើយដេក (ម៉ាថាយ ៤:២ ៨:២៤)។ ទ្រង់អាចមានអារម្មណ៍ថា ភ័យ និងឈឺចាប់ (យ៉ូហាន ៤:៦ លូកា ២២:៤៤ ហេព្រើរ ៤:១៥)។ ប៉ុន្តែព្រះ ដែលជាវិញ្ញាណគ្មាននិស្ស័យទាំងអស់នេះទេ។

ដូច្នេះ ព្រះយេស៊ូជា**មនុស្ស**ហើយមិនមែនព្រះទេ ពីមុន**ការមកគង់នៅខាងក្នុង** នៅឯពីធីជ្រមុជទឹកនោះ។ ទ្រង់គ្រាន់តែជាមនុស្សម្នាក់ និងជាកូនរបស់ព្រះ ដូចជាអ័ដាមដែរ គឺជាមនុស្សនិងជាកូនរបស់ព្រះដែលគ្មានបាប និងមានជីវិតអស់កល្ប មុនគាត់ដួលចុះក្នុងអំពើបាប។ ប៉ុន្តែ *មានតែព្រះយេស៊ូទេ ដែលមានអំណាចខ្ពស់ជាងគេ* ***ជាព្រះរាជបុត្រានៃព្រះ***ដ្បិតទ្រង់គឺជាឡូហ្គុសនោះដែលត្រូវបានប្រកាស និងសំដែងដល់ពួកបរិសុទ្ធនៃសញ្ញាចាស់ ។ កាលដើមដំបូង*ព្រះបន្ទូល*(សែនតែ១ពូជ) ដែលត្រូវតែសំដែងនៅក្នុងព្រះយេស៊ូ គឺជា*បុត្រា* ដែលគង់នៅជាមួយនឹងព្រះ ដែលជាព្រះវរបិតានៃយើងទាំងអស់(យ៉ូហាន ១:២) ។

បន្ទាប់ពីពិធីជ្រមុជទឹក ព្រះយេស៊ូបានក្លាយជា**មនុស្សដ៏ជាព្រះ គឺទាំងមនុស្ស និងព្រះ**ដែល**សេចក្តីពោរពេញនៃព្រះ** បានសណ្ឋិតនៅកទ្រង់។ គឺបន្ទាប់ពីពេលនោះប៉ុណ្ណោះ ដែលទ្រង់**មានចេស្តានៃព្រះបន្ទូល** *"ពីព្រោះដែលព្រះវរបិតាមានជីវិតក្នុងព្រះអង្គទ្រង់យ៉ាងណា នោះ ទ្រង់ក៏បានប្រទានឲ្យព្រះរាជបុត្រាមានជីវិត ក្នុងព្រះអង្គទ្រង់យ៉ាងនោះដែរ ហើយបានប្រទានអំណាចមកទ្រង់ ឲ្យជំនុំជំរះផង ពីព្រោះទ្រង់ជាកូនមនុស្ស"* (យ៉ូហាន ៥២៦-២៧)។ មុនពេលនោះ គ្មានព្រហចេស្តានៅក្នុងព្រះបន្ទូលរបស់ទ្រង់ ពីបបូរមាត់នៃមនុស្ស-ដ៏ជាព្រះនោះ។ ផ្ទុយទៅវិញ មនុស្សយេស៊ូ ក៏ប្រើបបរមាត់ដដែលដើម្បីថ្លែងពាក្យ ប្រហែល អរគុណ ដល់មិត្តរបស់ទ្រង់ ដែលផ្តល់អាហារ និងកន្លែងស្នាក់នៅដល់ទ្រង់ ហើយសរសើរព្រះជាព្រះវរបិតារបស់ទ្រង់

ព្រះយេស៊ូនោះ ដែលជាមនុស្សផង ព្រះផង មិនមានន័យថា ភាពជាព្រះ និងភាពមនុស្សបានលាយចូលគ្នាទៅជានិស្ស័យតែ១ ដូចគ្រីស្ទានខ្លះបានជឿនោះទេ។ ព្រះយេស៊ូពេញជាព្រះ និងពេញជាមនុស្ស។ ទ្រង់មានវិញ្ញាណផ្សេងគ្នា និងបំនងផ្សេងគ្នា ពីព្រះវរបិតា ដែលគង់នៅស្ថានសួគ៌។

នៅពេលប៉ូលនិយាយថា *"ព្រះបានចាត់ព្រះរាជបុត្រាទ្រង់ កើតពីស្ត្រី"*(កាឡាទី ៤៤) ដោយមិនអាចជំទាស់បាន គឺគាត់សំដៅទៅសាច់ឈាម ឬភាពជាមនុស្សនៃព្រះគ្រីស្ទ។ រីឯ នៅពេលព្រះវរបិតាអស់កល្បឬ ព្រះត្រូវបានលើកឡើង គឺសំដៅទៅព្រះវិញ្ញាណដ៏មានព្រះចេស្តាបំផុត ដែលគង់នៅក្នុងព្រះរាជបុត្រា។ ដូច្នេះ សេចក្តីអាថ៌កំបាំងដ៏អស្ចារ្យនៃ១ធីម៉ូថេ ៣១៦ ត្រូវបានសំដែងនៅក្នុងនោះ គឺ *"ព្រះបានលេចមកក្នុងសាច់ឈាម"*។

ច្រំណាំ គ្រីស្ទានជាច្រើន ដែលសន្មតថា សាសន៍យូដានៃសញ្ញាចាស់បានស្គាល់ថា ព្រះមានបុត្រា ឬថាមាន *"ព្រះ-ព្រះរាជបុត្រា"* នោះ គ្រាន់តែជាការសន្មត់ ដោយដកចេញពីឃ្លាបទគម្ពីរ ដូចជាដានីយ៉ែល ៣២៣-២៥ និង

ឡូហុស: ការចាប់ផ្តើមដំបូងនៃការបង្កើតរបស់ព្រះ

យ៉ូហាន២៥-២៩ ប៉ុណ្ណោះ។ ជាការពិត ពួកយូដា បានជឿថា ព្រះមែស៊ី (មនុស្ស)របស់ពួកគេ នឹងជាព្រះផងដែរ។ប៉ុន្តែតើពួកគេបានដឹងថា ព្រះមានបុត្រាឬទេ (បើ " ព្រះ-ព្រះរាជបុត្រា " ពិតជាបានគង់នៅពីមុនរួចហើយ) ពួកគេនឹងបានទទួលព្រះគ្រីស្ទដោយអំណរ ជាព្រះមែស៊ីរបស់ពួកគេ ហើយនឹងមិននិយាយថា

*"ឯអ្នកនេះ យើងដឹងជាមកពីណា តែព្រះគ្រីស្ទវិ កាលណាទ្រង់យាងមក នោះគ្មានអ្នកណា ដឹងជាមកពីណាទេ"* (យ៉ូហាន ៧:២៧)

សូម្បីតែសុល ជាពួកផារិស៊ី មិនបានទទួលសេចក្តីបង្រៀនបែបនេះ អំពី *"ព្រះ-ព្រះរាជបុត្រា"* ទេទោះជាគាត់ដឹងពី***អដូណៃ*** *ទេវតានៃយ៉ាវេ* ផងនោះ។ ដូច្នេះ នេះច្បាស់ហើយថាសូម្បីតែពួកអ្នក នៅក្នុងសម័យសញ្ញាចាស់ មិនមានការបើកសំដែងបែបនេះអំពីព្រះរាជបុត្រានៃព្រះទេ។ ប៉ុន្តែតើអ្នកណាជាបុរសទី៤នៅក្នុងភ្លើងជាមួយសាដ្រាក់ មែសាក់ អ័បេឌ-នេកា? នេប៊ូក្នេសាបាននិយាយថា

*"មើល យើងឃើញ៤នាក់ឥតជាប់ចំណងសោះ កំពុងដើរនៅកណ្តាលភ្លើងឥតមានអ្វីសោះឯអ្នកទី៤ ក៏មានភាពដូចជាកូនព្រះ"* ( ដានីយ៉ែល ៣:២៥ )

តើនេប៊ូក្នេសាអាចមានការបើកសំដែងបែបនេះ អំពី *"ព្រះរាជបុត្រានៃព្រះ"* ឬ? ពាក្យនេះ គឺជាកុះហុសខាងការបកប្រែ។ គឺគ្មានចំណងជឿក្នុងពាក្យនោះ និងការបកប្រែគួរជា "កូនព្រះ" ឬ *"កូននៃព្រះប្រើន"* ទេ គឺសំគាល់ឲ្យ *"ម្នាក់មានឫទ្ធិ" "ទេវតា" "អ្នកនាំព្រះរាជសារ" ឬ "តួមនុស្សអស្ចារ្យ"*។ ( មើលគម្ពីរផ្សេងទៀតទៅ )។ ទោះបីយ៉ាងណាក៏ដោយ ក៏មនុស្សទី៤នេះ ដោយគ្មានការសង្ស័យ គឺជាព្រះបន្ទូលជារូបភាពគំរូពីព្រះយេស៊ូគ្រីស្ទជាព្រះរាជបុត្រានៃព្រះ

មនុស្សរើសតាំង នៅក្នុងសម័យសញ្ញាចាស់ មិនដែលគូសបញ្ជាក់ថា ព្រះជា *"ព្រះវរបិតាដែលគង់នៅស្ថានសួគ៌ទេ"*។ ហើយក៏គ្មានរឿង ដែលគេបែរទៅអំពាវនាវដល់ "ព្រះរាជបុត្រាដែលគង់នៅស្ថានសួគ៌" ដែរ។ ពាក្យ *"ព្រហវរបិតាអស់កល្ប"* និង *"ព្រះវរបិតា ដែលគង់នៅស្ថានសួគ៌"* គឺជាពាក្យនៅសញ្ញាថ្មីទេ ។ទោះជាពីមុន ត្រូវបានប្រើម្តង នៅក្នុងសញ្ញាចាស់មែន(អេសាយ ៩:៦) ក៏គេប្រើជាសេចក្តីទំនាយ ទាក់ទងទៅនិងសញ្ញាថ្មី នៅពេលព្រះអស់កល្បនិងសំដែងអង្គទ្រង់នៅសាច់ឈាមនៃព្រះរាជបុត្រា។ ពាក្យទំាង២នោះ ត្រូវបានគេប្រើដោយសារតែមានព្រះរាជបុត្រាតែ១ ដែលបានកើតមក ដើម្បីផ្សះផ្សាគ្រួសាររបស់ព្រះ។ មើលហេព្រើរ១:៥-១៤. មើល២សាំយូអែល ៧:១៤. ទំនុកដំកើង ២:៧ កិច្ចការ ១៣:៣៣ រ៉ូម១:៤ និងដានីយ៉ែល៧:៩-១០.១៣-១៤. វិវរណះ ១:១៣. ម៉ាថាយ ២៥:៣១. អេភេ ១:២០-២២។

ឃ្លា *"ដើមកំណើតរបស់អ្នកនោះបានចាប់តាំងពីបុរាណគឺពីអស់កល្ប រៀងមក"* ទាក់ទងនឹង *"អ្នកគ្រប់គ្រង"* ដែលព្រះបង្កើតចេញពីអ៊ីស្រាអែល ក្នុងទំនាយនៃហោរាមីក (៥១) នេះមិនមែនមានន័យថា ព្រះយេស៊ូ (ដែលបានសំរេចទំនាយនេះជាអ្នកគ្រប់គ្រង) បានគង់នៅតាំងពីអស់កល្បពីអតីតកាលនោះទេ ប៉ុន្តែគឺនៅសម័យដ៏យូរលុងយុគសម័យអតីតកាលវិញ។ ព្រះយេស៊ូមិនបានមានពីមុនរួចហើយ ជាគូដាច់ដោយឡែកពីព្រះនោះទេ។ ប៉ុន្តែដោយសារទ្រង់ជា*ព្រះបន្ទូលទាំងអស់នៃព្រះ បានគង់នៅខាងក្នុង និងសំដែងចេញបទគម្ពីរបានរ៉ាយរ៉ាប់ពីទ្រង់* ទៅឯការចាប់ផ្តើមដំបូងរបស់ទ្រង់ នៅក្នុងអេឡូហ៊ីមជាម្នាក់ ដែលមានអំណាចលើគេ *នៅក្នុងគំនិត* ឬឧរា នៃព្រះវិញ្ញាណដ៏មានគ្រប់ព្រះចេស្តា។ ទ្រង់ជាព្រះរាជបុត្រាតែ១ (សែនតែ១)ដែលឡូហ្គុសបានចេញមកពីគំនិតអស់កល្ប នៃការប្រឹក្សារបស់ព្រះ ដើម្បីសំដែងចេញនិងធ្វើជារូបភាពគំរូ។ ក្រោយមក ឡូហ្គុសបានត្រឡប់មកគង់នៅខាងក្នុងព្រះយេស៊ូភ្លាម បន្ទាប់ពីទ្រង់បានទទួលពិធីជ្រមុជទឹក **នៅក្នុងទន្លេយ័រដាន់** ការបកនែ្រផ្សេងទៅនៅខាងក្រោមនេះនឹងធ្វើឲ្យអ្នកយល់ថែមទៀត ។

គម្ពីរយេរូសាឡិម-*"ប្រភពដើមរបស់ទ្រង់ បែរទៅឯអតីតកាលដ៏យូរលង់ទៅឯសម័យបុរាណ"*

គម្ពីរពិសិដ្ឋ (បេតអែល)–*"ដែលប្រភពដើមរបស់ទ្រង់ មកពីយុគសម័យបុរាណ មកពីយុគសម័យជាច្រើននៃអស់កល្ប"*

ការបកប្រែឡាំសា-"ដែលការចាប់ផ្តើមរបស់ទ្រង់ ត្រូវបាទាយទុក ពីចាស់បុរាណ ពីអស់កល្បមក"។

**នៅពេលព្រះយេស៊ូកំពុងតែអធិស្ឋាននៅក្នុងសួនច្បារគែរសេម៉ានី មិនមែនព្រហអធិស្ឋានទៅព្រះទេ។** ព្រះជាអ្នកទទួលការថ្វាយបង្គំនិងជាអ្នកទទួលការអធិស្ឋាន។ ព្រះមិនថ្វាយបង្គំឬអធិស្ឋានទេ។ បើទ្រង់ធ្វើការនេះ នោះវាខូចភាពបរិសុទ្ធរបស់ទ្រង់ហើយ។ គឺជាមនុស្សយេស៊ូទេ ដែលបនាអធិស្ឋានទៅព្រះ **ជាព្រះវរបិតារបស់ទ្រង់**។ បន្ទាប់ពីទ្រង់រស់ពីសុគតឡើងវិញលេចមកឲ្យម៉ារី ចាអ្នកស្រុកម៉ាក់ដាឡាឃើញ *"ព្រះយេស៊ូមានបន្ទូលទៅនាងថា កុំពាល់ខ្ញុំព្រោះខ្ញុំមិនទាន់ឡើងទៅឯព្រះវរបិតាខ្ញុំនៅលើយចូរនាងទៅឯពួកបងប្អូនខ្ញុំប្រាប់គេថា ខ្ញុំឡើង ទៅឯព្រះវរបិតាខ្ញុំជាព្រះនៃអ្នករាល់គ្នា គឺជាព្រះនៃខ្ញុំហើយជាព្រះនៃអ្នករាល់គ្នាដែរ"* (យ៉ូហាន ២០:១៧)។

**ហើយក៏មិនមែនព្រះដែលសុគតជំនួសបាបយើងនៅកាល់វ៉ារីដែរ ដ្បិតព្រះមិនអាចស្លាប់ឡើយ។ ព្រះគឺជាវិញ្ញាណ។ គឺព្រះយេស៊ូគ្រីស្ទ ជាព្រះរាជបុត្រាតែ ១ របស់ដែលសុគតជំនួសយើង** (១កូរិនថូស១៥:៣)។ ប៉ុន្តែ យ៉ាងម៉េចក៏

ឡូហ្គុស: ការចាប់ផ្តើមដំបូងនៃការបង្កើតរបស់ព្រះ

ដោយ ព្រះបាន *"សុគត"* តាមរបៀប១ដូចដែលបាននិយាយអញ្ចឹង។ ដើម្បី អនុវត្ត ផែនការណ៍សេចក្តីសញ្ញានៃការប្រោសលោះ របស់ទ្រង់ ព្រះវិញ្ញាណ អស់កល្ប ត្រូវតែជា ព្រះផង និងមនុស្សផង។ច្បាប់នៃសេចក្តីសញ្ញា គឺថាអ្នក ធ្វើ-សេចក្តីសញ្ញា ត្រូវតែមកស្លាប់ មុននឹងសេចក្តីសញ្ញានោះនៅក្នុងការបង្ខំឲ្យ សំរេចតាម(ហេព្រើរ ៨:៧-១៣. ៩:១៦-១៧) ហើយដោយសារព្រះជាវិញ្ញាណ ទ្រង់ត្រូវតែយកទំរង់ជាមនុស្ស ដើម្បីបង្ហាញឲ្យមនុស្សលោកបានស្គាល់ដល់ ទ្រង់ ហើយភក់សេចក្តីស្លាប់ជំនួសយើងដើម្បីប្រោសលោះយើង (ហេព្រើរ ២: ៩ រ៉ូម ៨:៣)។ដូច្នេះ ត្រូវ ដែលសុគតនៅកាល់វ៉ារី គឺនៅក្នុងញាណ*យ៉ាវេ៉ អ្នក ធ្វើ-សេចក្តីសញ្ញា*(កិច្ចព្រមព្រៀង)។

## ព្រះបន្ទូល ត្រូវបានឆ្កាង មិនមែនព្រះទេ

ចូលមកចំនុចផ្សេងទៀត យើងក៏ដឹងដែរថា *ព្រះបន្ទូលដែលជាព្រះ* ត្រូវ បានឆ្កាង។ ***ព្រះបន្ទូល ដែលបានដំកើងឡើង ពីមុនកំណើតលោកីយ៍***(យ៉ូហាន ១៧:៥) ត្រូវបានឆ្កាងនៅកាល់វ៉ារី។ យើងមិនអាចបំបែក ព្រះបន្ទូលចេញពី ព្រះយេស៊ូទេ ព្រោះព្រះយេស៊ូ គឺជាព្រះបន្ទូលនៃជីវិត។ ព្រះយេស៊ូ *ព្រះបន្ទូល* នៃព្រះ ជាព្រះរាជបុត្រានៃព្រះ បានសុគត។ ហើយបន្ទាប់ពីរស់ពីសុគតឡើង វិញ និងបានលោកឡើងទៅស្ថានសួគ៌ព្រះវិញ្ញាណបានយាងមកដើម្បីបញ្ជាក់ បន្ថែម ថាព្រះបន្ទូលបានដំកើងឡើងម្តងទៀតហើយ ដោយព្រះវិញ្ញាណដ៏មាន ព្រះចេសកដា ដូចជាទ្រង់បានអធិស្ឋាន (យ៉ូហាន ១២:២៨ ៧:៣៩. ១ធីម៉ូថេ ៣:១៦)។

វាបង្ហាញឲ្យយើងដឹងថា ***អេឡូហ៊ីម*** តែងតែបង្ហាញអង្គទ្រង់ជាមួយ***ព្រះ បន្ទូល*** ដ្បិតពួកគេគឺ**តែ១** ទេ (យ៉ូហាន ១:១. ១យ៉ូហាន ៥:៧) ។នៅពេល ដែលទ្រង់សុគតនៅលើឈើឆ្កាងភ្លាមនោះ ព្រះយេស៊ូបានស្រែកឡើងយ៉ាង ខ្លាំងថា *"ឲ្យព្រះ ព្រះនៃទូលបង្គំអើយ ហេតុអ្វីបានជាទ្រង់ចោលទូលបង្គំ?"* (ម៉ាថាយ២៧:៤៦)។ សំរែកនោះ គឺជាសំរែកនៃការឈឺចាប់ខ្លាំងដ្បិតទ្រង់ ដែលមិនស្គាល់បាបសោះ បានទទួលបាបនៃមនុស្សលោកមកដាក់លើទ្រង់ មួយរំពេច។ ទ្រង់បាបក្លាយទៅជា**អ្នកទទួល-បាប** ដើម្បីសំរេចទំនាយសញ្ញា ចាស់ ដែលបានចែងទុកពីទ្រង់។ នៅក្រោមបន្ទុកនៃអំពើបាប ទ្រង់មាន អារម្មណ៍ថា ព្រះ-បានបោះបង់ចោល ពីព្រោះទ្រង់គឺជាមនុស្ស។ ហើយដោយ ព្រោះទ្រង់បាបយកបាបនៃមនុស្សលោកមកដាក់លើអង្គទ្រង់ នោះការចំនុំជំរះ បានធ្លាក់មកលើទ្រង់។ ដូច្នេះហើយ បានជាមានសំរែកដ៏ខ្លាំងនេះ។ ប៉ុន្តែព្រះ ពិតជាមិនបានដក ឬបោះបង់ចោលទ្រង់ទាល់តែសោះ (យ៉ូហាន ១៦:៣២) ច្រំណាំ ការសិក្សានៃ *"ការថ្វាយដង្វាយអាហារ"* នៅក្នុងគម្ពីរលេវីវិន័យ ២:១-៣ ដែលម្សៅល្អ (ភាពជាមនុស្សរបស់ព្រះគ្រីស្ទ) និងគ្រឿង(ជ័រ) កំញាន (ជីវិត

ទួលបង្គំរបស់ព្រះគ្រីស្ទ) បានលាយជាមួយនឹងប្រេង (ព្រះវិញ្ញាណបរិសុទ្ធនៃព្រះ) ហើយយកទៅដុតនឹងភ្លើងទាំងអស់ នៅលើអាសនា (ដែលថ្លែងពីកាល់វ៉ារី) បញ្ជាក់ថា ព្រះយេស៊ូ ពិតជាមិនដែលត្រូវបានព្រះបោះបង់ចោលនៅកាល់វ៉ារីទេ។]

## រូបកាយសិរីល្អរបស់ព្រះគ្រីស្ទ

បន្ទាប់ពីអ្នកសង្គ្រោះយើង បានឈ្នះសេចក្ដីស្លាប់ នឹងស្ថានឃុំព្រលឹងមនុស្សស្លាប់ **ទ្រង់ក៏បានរស់ឡើងវិញ**ហើយបានលើកឡើងទៅស្ថានសួគ៌ ហើយពាក់រូបកាយនៃស្ថានសួគ៌ រូបកាយព្រះបន្ទូល។ **ការផ្សំ** នៃរូបកាយ**មនុស្ស និងស្ថានសួគ៌** បង្កើតបានជារូបកាយថ្មី ដែល**មិនពុករលួយហើយមិនចេះស្លាប់**។ រូបកាយ**សិរីល្អ**នេះ ហៅថារូបកាយ**ខាងវិញ្ញាណ**។

នៅពេលអ័ដាមបានចូលមកក្នុងលោកីយ៍នេះ គាត់គឺជាមនុស្សធម្មតានៃធូលីដី។ គាត់មានរូបកាយផែនដី ជាសាច់ឈាម។ ព្រះបានដាំរូបកាយធម្មតានេះនៅក្នុងព្រះយេស៊ូ ដើម្បីឲ្យទ្រង់អាចបង្កើត រូបកាយខាងវិញ្ញាណ ចេញពីអ្វីដែលបានដាំ។

*"សេចក្ដីដែលមនុស្សស្លាប់បានរស់ឡើងវិញ នោះក៏បែបដូច្នេះដែរ គេបានកប់ទៅ ជារូបកាយពុករលួយ តែបានរស់ឡើងវិញជារូបកាយ មិនចេះពុករលួយឡើយ បានកប់ទៅទាំងមានសេចក្ដីអាប់ឱន តែរស់ឡើងវិញ ទាំងមានសិរីល្អ បានកប់ទៅទាំងមានសេចក្ដីកំសោយ តែរស់ឡើងវិញ ទាំងមានព្រះចេស្តា បានកប់ទៅជារូបកាយខាងសាច់ឈាម តែរស់ឡើងវិញជា រូបកាយខាងវិញ្ញាណ បើមានរូបកាយខាងសាច់ឈាម នោះក៏មានរូបកាយខាងវិញ្ញាណដែរ"* (១កូរិនថូស ១៥:៤២-៤៤)

នៅពេលការពុករលួយបានបំពាក់នៅលើព្រលឹងមនុស្ស *"អ័ដាមចុងក្រោយ ជាវិញ្ញាណដ៏ប្រោសឲ្យរស់វិញ"* (១កូរិនថូស ១៥:៤៥ខ) ដើម្បីផ្ដល់ជីវិត និងរូបកាយថ្មី-គឺជារូបកាយខាងវិញ្ញាណ-ដល់ពួកអ្នក ដែលបានជឿ។

*"ពីព្រោះយើងដឹងថា បើត្រសាលដែលជាលំនៅរបស់យើងខ្ញុំ នៅផែនដីត្រូវបំផ្លាញនៅវេលាណា នោះយើងខ្ញុំមានវិមាន១ ដែលមកពីព្រះ មិនមែនធ្វើនឹងដៃទេ គឺនៅលើស្ថានសួគ៌វិញ ជាវិមានដ៏នៅជាប់លាប់អស់កល្បជានិច្ច"* (២កូរិនថូស ៥:១)។

នៅពេលដែលអ្នកបរិសុទ្ធនៃព្រះបានស្លាប់ទៅ ព្រលឹងរបស់គាត់បានចាកចេញពីរូបកាយនៅផែនដីរបស់គាត់ ទៅធូលីនៃផែនដី ហើយត្រឡប់ទៅស្ថានសួគ៌ ដើម្បីទទួល *"វិមានដែលមិនមែនធ្វើនឹងដៃ"* គឺរូបកាយព្រះបន្ទូល។ ហើយនៅព្រឹកនៃការរស់ឡើងវិញ ពេលដែលពួកស្លាប់ក្នុងព្រះគ្រីស្ទនឹងរស់

ឡូហ្គុស: ការចាប់ផ្ដើមដំបូងនៃការបង្កើតរបស់ព្រះ

ឡើង នោះគេនឹងមានរូបកាយថ្មី។ គេនឹងយាងមកមានរូបកាយព្រះបន្ទូល ដើម្បីចាប់យករូបកាយនៅផែនដីនៃធូលីដី។ ការផ្សំនៃរូបកាយទាំង២នេះនឹងបង្កើតចេញ*ជារូបកាយសិរីល្អខាងវិញ្ញាណ។* ដូចគ្នាដែរ សំរាប់ពួកបរិសុទ្ធនៅរស់ ពួកគេក៏នឹងបានផ្លាស់ប្រែនៅពេលរូបកាយព្រះបន្ទូលរបស់ពួកគេ យាងមកចាប់យក *រូបកាយសាច់ឈាម*របស់ពួកគេនៅពេលត្រែចុងក្រោយបង្អស់

*"តែទាំងអស់គ្នានឹងបានផ្លាស់ប្រែទៅក្នុង១រំពេចវិញ គឺក្នុង១ប៉ព្រិចភ្នែកប៉ុណ្ណោះ ក្នុងកាលដែលឮសូរត្រែក្រោយបង្អស់ ដ្បិតត្រែនឹងឮឡើងមែន នោះពួកស្លាប់នឹងរស់ឡើងវិញ មិនពុករលួយទៀតឡើយ រួចយើងរាល់គ្នានឹងបានផ្លាស់ប្រែទៅ ដ្បិតត្រូវតែរូបកាយដ៏ពុករលួយនេះបានប្រដាប់ដោយសេចក្ដីពិតពុករលួយវិញ ហើយរូបកាយដែលរមែងស្លាប់នេះ ត្រូវតែបានប្រដាប់ដោយសេចក្ដីមិនចេះស្លាប់វិញដែរ" (១កូរិនថូស ១៥:៥២-៥៣)។*

ហើយនៅពេលការទាំងអស់នេះបានសំរេច នោះពាក្យរបស់ប៉ុលនឹងក្លាយជាការពិត ។

*"យើងក៏នឹងមានរូបកាយរបស់ព្រះអម្ចាស់ពីស្ថានសួគ៌ ដូចជាយើងមានរូបកាយរបស់ មនុស្ស ដែលធ្វើពីធូលីដីមកដែរ"* ( ១កូរិនថូស ១៥:៤៩)។

អាម៉ែន។ យើងពិតជានឹងបានប្រដាប់ដោយរូបកាយសិរីល្អខាងវិញ្ញាណជាប្រភេទដូចគ្នាដែលព្រះយេស៊ូគ្រីស្ទកំពុងមានឥឡូវនេះ។

## ភាពជាព្រហពេញលេញរបស់ព្រះយេស៊ូគ្រីស្ទ
## -ព្រះនៅក្នុងព្រះគ្រីស្ទ

នៅក្នុងយ៉ូហាន ១៧ យើងដឹងថា ព្រះយេស៊ូបានយាងមកសំរេចការងារ ៣ ដែលព្រះបានគិតទុកសំរាប់ទ្រង់។ ទ្រង់ត្រូវ **បញ្ចប់ការងាររបស់ព្រះ** (ខ ៤) **ទ្រង់ត្រូវសំដែងព្រះនាមព្រះ** (ខ ៦) **ចែកចាយព្រះបន្ទូលរបស់ព្រះ** (ខ ៨) ។ ទ្រង់បានបំពេញបេសកម្មទាំងអស់បានចប់សព្វគ្រប់ ដោយសិទ្ធអំណាចដែលព្រះបានប្រទានដល់ទ្រង់។ នៅក្នុងយ៉ូហាន ១៤:១០ ទ្រង់មានបន្ទូលថា

*"ខ្ញុំនៅក្នុងព្រះវរបិតា ហើយព្រះវរបិតាគង់នៅក្នុងខ្ញុំទេឬអី អស់ទាំងពាក្យដែលខ្ញុំប្រាប់ អ្នករាល់គ្នា នោះខ្ញុំមិនមែនប្រាប់ដោយអាងខ្លួនខ្ញុំទេ គឺជាព្រះវរបិតាដែលគង់ក្នុងខ្ញុំ ទ្រង់ធ្វើការទាំងនោះវិញ"។*

នេះគួរតែជាភស្តុតាងបញ្ជាក់គ្រប់គ្រាន់ហើយ ថា **ព្រះយេស៊ូមិនមែនជាព្រះវរបិតាទ្រង់ ផ្ទាល់ទេ** ផ្ទុយនឹងអ្វី ដែលចលនា *"យេស៊ូតែ១"* បានប្រកាសអះអាងនោះ។

*ព្រះបន្ទូល* គឺជា*សែនតែ១របស់ព្រះ*។ ដើម្បីសំរេចបំណង ដែលជំរូវទុករបស់ព្រះ *ព្រះបន្ទូល* (គង់នៅក្នុងរូបកាយ-*រូបកាយខាងវិញ្ញាណ*) ត្រូវតែមកសំដែងភាពជាកូនរបស់ទ្រង់។ **សេចក្តីអាថ៌កំបាំងដែលលាក់ទុក** នៅក្នុងទំនាក់ទំនងរវាង*ព្រះវិញ្ញាណដ៏មានចេស្តាបំផុត* និង*ព្រះបន្ទូលគឺជាសេចក្តីអាថ៌កំបាំងនៃទំនាក់ទំនងព្រះវិញ្ញាណដ៏មានព្រះចេស្តាបំផុត* និងព្រះ*បន្ទូលគឺជា សេចក្តីអាថ៌កំបាំងនៃទំនាក់ទំនងព្រះវរបិតា-ព្រះរាជបុត្រា*។ ដើម្បីឲ្យទំនាក់ទំនងព្រះវរបិតា-ព្រះរាជបុត្រាអាចក្លាយជា *ការពិតដ៏មើលឃើញ* នៅក្នុងការបង្កើតរបស់ទ្រង់ព្រះបានតាំងវិញ្ញាណភាពជាកូននៃឡូហ្កុស ដើម្បីយកទំរង់ជាបុគ្គលមនុស្ស។ ឡូហ្កុស នឹងមិនបន្តមាននៅក្នុងរូបកាយខាងវិញ្ញាណទេ។ ព្រះបានរៀបចំរូបកាយមនុស្ស ពីធូលីដីនៃផែនដី *សំរាប់ឡូហ្កុសដើម្បីសំដែង* ជាព្រះរាជបុត្រានៃព្រះ (ហេព្រើរ ១០: ៥ខ)។ បន្ទាប់មក ទីអូហ្វានីលែងឃើញមាន នៅពេលដែលទារក១បានកើតនៅបេថ្លេហិម ។

*"ហេតុនោះបានជាទ្រង់យាងមកក្នុងលោកីយ៍ ទ្រង់មានបន្ទូលថា ព្រះអង្គមិនចង់បានយញ្ញបូជា និងដង្វាយទេ តែទ្រង់បានរៀបចំរូបកាយឲ្យទូលបង្គំវិញ ទ្រង់ក៏មិនសព្វព្រះហឬទ័យនិងដង្វាយដុត ឬ នឹងដង្វាយលោះបាបដែរ បានជាទូលបង្គំទូលថា មើល ឱព្រះអង្គអើយ ទូលបង្គំមកនឹងធ្វើតាមព្រះហឬទ័យទ្រង់ (សេចក្តីនេះបានកត់ទុកពីទូលបង្គំនៅក្នុងគម្ពីរហើយ)"* (ហេព្រើរ ១០:៥-៧)។

*"ដ្បិតតើព្រះដែលមានបន្ទូលនឹងទេវតាណាមួយថា ឯងជាកូនអញ អញបានបង្កើតឯងនៅថ្ងៃនេះ ឬថា អញនឹងបានជាឱពុកវា ហើយវានឹងបានជាកូនរបស់អញដូច្នេះឬទេ?"* (ហេព្រើរ ១:៥)

នៅក្នុងភាពជាមនុស្ស ព្រះគ្រីស្ទយេស៊ូអាចរកនឹងធ្វើតាមបំណងរបស់ទ្រង់ផ្ទាល់បាន។ ប៉ុន្តែទ្រង់ចង់បានតែព្រះហឬទ័យដ៏គ្រប់លក្ខណ៍របស់ព្រះប៉ុណ្ណោះនៅក្នុងជីវិតរបស់ទ្រង់។ ទ្រង់បាននៅរួមតែ១នឹងព្រះបន្ទូល ។ **អ្នកមិនអាចបំបែកព្រះបន្ទូល និងព្រះយេស៊ូចេញពីគ្នាទេ។ ទ្រង់គឺជាព្រះបន្ទូលពិតនៃជីវិត ជាជីវិតនៃព្រះផ្ទាល់** ។ ប៉ុលបានសរសេរថា

*"ហើយទោះបើទ្រង់ជាព្រះរាជបុត្រាក៏ដោយ គង់តែទ្រង់បានរៀនស្តាប់បង្គាប់ ដោយសារការដែលទ្រង់រងទុក្ខលំបាកទាំងប៉ុន្មាននោះដែរ"* (ហេព្រើរ ៥:៨) ។

បាទ ព្រះយេស៊ូបានស្តាប់បង្គាប់រហូតដល់ស្លាប់ គឺជាសេចក្តីស្លាប់នៅលើឈើឆ្កាង។

*"ដែលទោះបីទ្រង់មានរូបអង្គជាព្រះក៏ដោយ គង់តែមិនបានរាប់សេចក្តីដែលស្មើនឹងព្រះនោះ ទុកជាសេចក្តីដែលគួរកាន់ខ្ជាប់ឡើយ គឺទ្រង់បានលះបង់ព្រះ*

ឡូហ្គុស: ការចាប់ផ្តើមដំបូងនៃការបង្កើតរបស់ព្រះ

*អង្គទ្រង់ មកយករូបភាពជាបាវបំរើញព្រមទាំងប្រសូតមកមានរូបជាមនុស្ស ផង ហើយដែលឃើញទ្រង់មានភាពជាមនុស្ស ដូច្នោះ នោះក៏បានបន្ទាប់ព្រះអង្គទ្រង់ ទាំងចុះចូលស្តាប់បង្គាប់ រហូតដល់ទីមរណៈ គឺទ្រង់ទទួលសុគត ជាប់លើឈើឆ្កាងផង ដោយហេតុនោះបានជាព្រះបានលើកទ្រង់ឡើងយ៉ាងខ្ពស់ ហើយបានប្រទានឲ្យមាននាមដ៏ប្រសើរ លើសជាអស់ទាំងនាមផង ដើម្បីកាលណាឮព្រះនាមព្រះយេស៊ូនោះឲ្យគ្រប់ទាំងជង្គង់នៅស្ថានសួគ៌ នៅផែនដី ហើយនៅក្រោមផែនដី ត្រូវលុតចុះ ហើយឲ្យ គ្រប់ទាំងអណ្តាតបានថ្លែងប្រាប់ថា ព្រះយេស៊ូគ្រីស្ទ គឺជាព្រះអម្ចាស់ សំរាប់ជាសិរីល្អដល់ព្រះជាព្រះវរបិតា"* (ភីលីព ២:៦-១១ ពីអត្ថបទក្រិក ដែលបានបង្កើតដោយគម្ពីរនូមើរីក្ស សូមមើលទំនុក ១២៩: ៣ អេសាយ ៥៣:២-៥ ១១ ម៉ាកុស ១៥:១៩-២៨ ១ ពេត្រុស ១:៩-១១) ។ [ការសង្កត់ធ្ងន់ខាងគំនិត]

*គំនិត* ទ្រង់ *ព្រះបន្ទូល* របស់ទ្រង់ និង*កិច្ចការរបស់ទ្រង់* គឺបានចុះចូលចំពោះព្រះទាំងអស់បានជាទ្រង់ និងព្រះឃើញថា ត្រឡប់ទៅ**តែ១**មែន *"ខ្ញុំ និងព្រះវរបិតាគឺតែ១ព្រះអង្គទេ"* (យ៉ូហាន ១០:៣០ ១០:៣៨) និង *"អ្នកណាដែលឃើញខ្ញុំ នោះក៏ឃើញព្រះវរបិតាដែរ"* (យ៉ូហាន ១៤:៩) វិញ្ញាណបានលាយជាមួយវិញ្ញាណនៃព្រះយ៉ាងជិតស្និទ្ធ បានជា***វិញ្ញាណរបស់ទ្រង់ បានត្រឡប់ទៅជាតែ១នឹងព្រះវិញ្ញាណអស់កល្ប។*** សូមឲ្យយើងជាពួកបរិសុទ្ធនៃព្រះ បានលាយជាមួយនឹងព្រះវិញ្ញាណនៃព្រះ ដោយចុះចូលនឹងព្រះបន្ទូលរបស់ទ្រង់ទាំងអស់ ដើម្បីឲ្យលោកីយ៍បានឃើញតែព្រះគ្រីស្ទនៅក្នុងយើង សូម្បីតែព្រះយេស៊ូបានមានបន្ទូលថា *"នៅថ្ងៃនោះអ្នករាល់គ្នានឹងដឹងថា ខ្ញុំនៅក្នុងព្រះវរបិតាខ្ញុំ អ្នករាល់គ្នាក៏នៅក្នុងខ្ញុំ ហើយខ្ញុំនៅក្នុងអ្នករាល់គ្នាដែរ"* (យ៉ូហាន ១៤: ២០)។ សូមឲ្យយើងសំរេចព្រះបំណងរបស់ទ្រង់ផងដែរ ដូចជាទ្រង់បានអធិស្ឋាន *"ដើម្បីឲ្យទាំងអស់បានរួមមកតែ១ឲ្យព្រះវរបិតាអើយ ដូចជាទ្រង់គង់នៅក្នុងទូលបង្គំហើយទូលបង្គំនៅក្នុងទ្រង់ដែរ គឺឲ្យអ្នកទាំងនោះបានរួមគ្នាតែ១ នៅក្នុងយើង ប្រយោជន៍ឲ្យលោកីយ៍បានជឿថា ទ្រង់ចាត់ទូលបង្គំមកពិត"*(យ៉ូហាន១៧:២១ ព្រមទាំងខ ២២-២៣)។

ពាក្យរបស់សាវកប៉ូល នៅក្នុងភីលីព ២:៥-៨ ជារឿយៗត្រូវបានគេបកស្រាយខុស និងយល់ខុស ។ ផ្ទុយទៅវិញ ប៉ូលបានសំដៅទៅមនុស្សយេស៊ូគ្រីស្ទ ព្រោះគាត់បានស្គាល់ទ្រង់ ដោយការបើកសំដែងថាទ្រង់ជានរណា គ្រីស្ទានខ្លះខំរកភស្តុតាងថា ព្រះយេស៊ូបានគង់នៅជាមួយនឹងព្រះពីមុនរួចហើយ គឺពីមុនការបង្កើត ដោយគេអានពាក្យលោកប៉ូលខាងក្រោមយ៉ាងនេះវិញ

*"ត្រូវមានគំនិតដូចជាព្រះគ្រីស្ទយេស៊ូ ដែលបានគង់នៅ**ពីមុន** ក្នុងទំរង់របស់ព្រះ គង់តែមិនបានរាប់សេចក្តីដែលស្មើនឹងព្រះនោះ ទុកជាសេចក្តីដែល*

*គួរកាន់ខ្ជាប់ឡើយ គឺទ្រង់រាប់អង្គទ្រង់ជាទទេ មកយកទំរង់នៃបាវបំរើ ព្រះទាំងប្រសូតមកមានភាពដូចជាមនុស្ស ហើយដែលឃើញទ្រង់មានភាពជាមនុស្ស ដូច្នេះ នោះក៏បន្ទាបអង្គទ្រង់ ទាំងចុះចូលស្តាប់បង្គាប់រហូតដល់ទីមរណៈ គឺទ្រង់ទទួលសុគតជាប់នៅលើឈើឆ្កាងផង"។*

ឬ ដោយប្រើគម្ពីរយើងចេម្ស ពួកគេយល់ច្រឡំពាក្យក្រិក "*គង់នៅ* ( being )" នៅក្នុងបទគម្ពីរ ដោយអានដូចខាងក្រោម

"*ត្រូវមានគំនិតដូចជាព្រះគ្រីស្ទដែលបានគង់នៅ**(ពីដើម)** ក្នុងទំរង់របស់ព្រះ គង់តែមិនបានរាប់សេចក្តីដែលស្មើនឹងព្រះនោះ ទុកជាសេចក្តីដែលគួរកាន់ខ្ជាប់ឡើយ គឺទ្រង់រាប់អង្គទ្រង់ជាទទេ មកយកទំរង់នៃបាវបំរើ ព្រមទាំងប្រសូតមកមានភាពដូចជាមនុស្ស ហើយដែលឃើញទ្រង់មានភាពជាមនុស្សដូច្នេះ នោះក៏បន្ទាបអង្គទ្រង់ ទាំងចុះចូលស្តាប់បង្គាប់រហូតដល់ទីមរណៈ គឺទ្រង់ទទួលសុគតជាប់នៅលើឈើឆ្កាងផង"។*

គ្រីស្ទានទាំងនេះ គេពេញចិត្តថាដូចជាង៏ដាមបានមានរួចហើយក្នុងទំរង់ជាវិញ្ញាណនោះព្រះយេស៊ូក៏បានគង់នៅរួចហើយ ក្នុងទំរង់របស់ព្រះជាបុគ្គលទី២មានតែឈ្មោះ (ព្រះរាជបុត្រាអស់កល្ប) នៃព្រះដ៏ជាកំពូល ឬ "*កាលដើមដំបូង*" ដូចជាបានចែងនៅក្នុង យ៉ូហាន ១:១។ហើយដោយសារពួកគេជឿថាទ្រង់បានគង់នៅពីមុន ដូច្នេះហើយព្រះយេស៊ូអាចជ្រើសរើសដោយអង្គទ្រង់ផ្ទាល់ ដើម្បីយាងមកផែនដី ជាមនុស្សលោក។ ប៉ុន្តែតើអ័ដាមពិតជាបានជ្រើសរើសថា គាត់គួរនៅមានទំរង់ជាវិញ្ញាណ ឬមកផែនដីជាមនុស្សឬ? ពិតជាមិនបានទេ។ ព្រះបានបង្កើតរបស់ទាំងអស់សំរាប់បំណងព្រះហឫទ័យល្អផ្ទាលរបស់ទ្រង់ និងសិរីល្អដែលទ្រង់បានគិតនៅក្នុងអង្គទ្រង់ តាមព្រះដំរិះ (ការប្រឹក្សា)នៃបំណងព្រះហឫទ័យផ្ទាល់របស់ទ្រង់ (អេភេសូរ១:១៩ វិវរណៈ ៤:១១)

មុននឹងមានព្រះបន្ទូលនៅកាលដើមដំបូង (យ៉ូហាន ១:១) ព្រះដ៏មានព្រះចេស្តាអស្ចារ្យបំផុត ក្នុងការប្រឹក្សាផ្ទាល់របស់ទ្រង់ បានតាំងទុកជាមុនថា ពូជរបស់ទ្រង់គួរតែមកផែនដី និងយកទំរង់នៃមនុស្សដើម្បីសំរេចបំណងព្រះហឫទ័យរបស់ទ្រង់ ដូចបានដំរូវទុកជាមុន។ ទ្រង់បានរៀបចំផែនការ ទ្រង់ក៏បានបង្កើត ទ្រង់បានចាត់ និងសំរេចបំនងរបស់ទ្រង់ផ្ទាល់ "*តាមព្រះដំរិះនៃបំណងព្រះហឫទ័យទ្រង់ផ្ទាល់*"(អេភេសូរ ១:១១)

**ដោយព្រោះព្រះយេស៊ូគ្រីស្ទ គឺជា "*រូបអង្គសំដែងចេញ*" នៃសារជាតុនៃព្រះ (ហេព្រើរ ១:៣) ហើយព្រះបន្ទូលនៃជីវិត (១យ៉ូហាន ១:១) ទ្រង់ទទួលការថ្វាយបង្គំដូចជាព្រះ។**ដោយមានទំរង់ជាព្រះ (ព្រះបន្ទូល ដែលមកសណ្ឋិត

ខាងក្នុងជារូបភាពគំរូ ក្នុងរយះពេលជាយូរលងមកហើយ) ព្រះបន្ទូល បានស្មើជាមួយនឹងព្រះជាព្រះវរបិតា។ ទោះបីយ៉ាងណាក៏ដោយ ក៏ព្រះយេស៊ូបានបោះបង់តំណែងនោះ ឬអត្តសញ្ញាណនោះ ដោយបន្ទាបអង្គទ្រង់គឺដើម្បីសំរេចការសុគតនៅលើឈើឆ្កាង ដែលព្រះបានរៀបចំផែនការទុកជាមុន។ **ហើយទ្រង់តែងតែដឹកនាំចំណាំអារម្មណ៍ មនុស្សទៅឯព្រះវរបិតាដ៏អស់កល្ប គឺព្រះវិញ្ញាណនៃជីវិត។**

*"ពីព្រោះមានតែ១ ហើយមានអ្នកសង្គ្រោះតែ១ នៅកណ្តាលព្រះ និងមនុស្សគឺជាមនុស្ស ដ៏ជាព្រះគ្រីស្ទយេស៊ូ"*(១ធីម៉ូថេ ២:៥)។ *"រីឯអ្នកកណ្តាល (អ្នកសង្រួបសង្រួម) នោះមិនមែនបង្រួបបង្រួមអ្នកណាតែម្នាក់ឯងនោះឡើយ តែចំណែកព្រះ ទ្រង់ជាព្រះតែ១ទេ"* (កាឡាទី ៣:២០) ទាក់ទងនឹងព្រះយេស៊ូ ប៉ុលបានសរសេរ នៅក្នុងរ៉ូម ៩:៥ *"... ហើយព្រះគ្រីស្ទក៏បានកើតពីពួកគេខាងឯសាច់ឈាមដែរ ដែលទ្រង់ខ្ពស់លើសទាំងអស់ ជាព្រះដ៏មានពរអស់កល្បជានិច្ចអាម៉ែន"*។ ព្រះយេស៊ូ គឺជាព្រះអម្ចាស់ និងព្រះគ្រីស្ទផង (កិច្ចការ ២:៣៦)។ ដូច្នេះ ដោយគ្មានស្រមោលនៃការសង្ស័យ ព្រះអម្ចាស់យេស៊ូគ្រីស្ទ គឺជាព្រះផងនិងជាមនុស្សផង ហើយថាព្រះនិងព្រះគ្រីស្ទ គឺតែ១។ មិនមែន *"ព្រះនៅក្នុងបុគ្គល៣ ជាព្រះត្រៃឯកដ៏មានពរទេ"* ។ ហេតុនេះយើងឃើញការបញ្ជាក់យ៉ាងត្រឹមត្រូវនៃសេចក្តីពិតនៃការបើកសំដែង ពួកសាវក ដែលទាក់ទងនឹងពិធីជ្រមុជទឹក នៅក្នុងព្រះនាមនៃព្រះអម្ចាស់យេស៊ូគ្រីស្ទ (កិច្ចការ ២:៣៨: ៨:១២ ១៦. ១០:៤៨. ១៩:៥ ម៉ាថាយ ២៨: ១៩-ព្រះនាមនៃតួនាទីត្រៃឯក )។

## អ្នកកំសាន្តចិត្ត ( ព្រះដ៏ជាជំនួយ)

***ព្រះវិញ្ញាណបរិសុទ្ធ គឺជាព្រះវិញ្ញាណ នៃព្រះវរបិតា ដែលគង់នៅក្នុងព្រះគ្រីស្ទ។*** ហើយដោយសារព្រះគ្រីស្ទ និងព្រះ គឺតែ១នោះអាចហៅព្រះគ្រីស្ទថា ជាវិញ្ញាណនៃព្រះយេស៊ូគ្រីស្ទ (ភីលីព១:១៩) ដូច វិញ្ញាណនៃព្រះរាជបុត្រារបស់ទ្រង់ដែរ (កាឡាទី ៤:៦)។ចំណាំព្រះបន្ទូលរបស់ព្រះយេស៊ូ

*"នោះខ្ញុំនឹងទូលសូមដល់ព្រះវរបិតា ហើយទ្រង់នឹងប្រទានព្រះដ៏ជាជំនួស ១អង្គទៀត មកអ្នករាល់គ្នាឲ្យបានគង់នៅជាមួយ នៅអស់កល្បរៀងទៅ គឺជាព្រះវិញ្ញាណនៃសេចក្តីពិត ដែលលោកីយ៍ទទួលពុំបាន ព្រោះមិនឃើញ ហើយមិនស្គាល់ទ្រង់សោះ តែអ្នករាល់គ្នាស្គាល់ទ្រង់ ដ្បិតទ្រង់គង់ជាមួយ ក៏នឹង*

*សណ្ឋិតនៅក្នុងអ្នករាល់គ្នាដែរខ្ញុំមិនចោលឲ្យអ្នករាល់គ្នាឲ្យនៅកំព្រាទេ ខ្ញុំនឹងមកឯអ្នករាល់គ្នាវិញ"* យ៉ូហាន ១៤:១៦-១៨ ។

ចំពោះ *"អ្នកកំសាន្តចិត្ត១អង្គទៀត (ឬអ្នកជំនួយ)"* ព្រះយេស៊ូមិនបានសំដៅទៅព្រះ ១ ផ្សេងទៀតទេ ប៉ុន្តែគឺ (ទំរង់ខុសគ្នា) ១ផ្សេងទៀតនៃការបំរើរបស់ព្រះគ្រីស្ទទ្រង់ផ្ទាល់ ជាព្រះវិញ្ញាណបរិសុទ្ធ។ព្រះគ្រីស្ទបានមានបន្ទូលពីអង្គទ្រង់យ៉ាងច្បាស់ ដែលនឹងយាងមកក្នុងទំរង់នៃវិញ្ញាណ ពេលដែលទ្រង់បានមានបន្ទូលថា *"គឺជាព្រះវិញ្ញាណនៃសេចក្តីពិត ដែលលោកីយ៍ទទួលពុំបានព្រោះមិនឃើញហើយមិនស្គាល់ទ្រង់សោះ តែអ្នករាល់គ្នាស្គាល់ទ្រង់ ដ្បិតទ្រង់គង់ជាមួយក៏នឹងសណ្ឋិតនៅក្នុងអ្នករាល់គ្នាដែរខ្ញុំមិចោលឲ្យអ្នករាល់គ្នាឲ្យនៅកំព្រាទេ នឹងមកឯអ្នករាល់គ្នាវិញ"*។ ពួកសាវកកស្គាល់ទ្រង់ ព្រោះទ្រង់បានគង់ជាមួយពួកគេ។ ហើយដូចដែលទ្រង់បានសន្យា ព្រះយេស៊ូបានមកឯពួកគេ-នៅក្នុងទំរង់ជាព្រះវិញ្ញាណបរិសុទ្ធ នៅថ្ងៃទី៥០!

សាវកយ៉ូហាន ដែលបានកត់ត្រាព្រះបន្ទូលទាំងនេះរបស់ព្រះយេស៊ូ *"គឺជាវិញ្ញាណដែលឲ្យមានជីវិត រូបសាច់គ្មានប្រយោជន៍អីទេ ឯពាក្យដែលខ្ញុំនិយាយនឹងអ្នករាល់គ្នា នោះត្រូវខាងវិញ្ញាណ និងជីវិតវិញ"* (យ៉ូហាន ៦:៦៣) គាត់បានសរសេរលើកក្រោយក្នុងសៀវភៅដដែលថា *"ទ្រង់ក៏ផ្លុំលើគេទាំងមានបន្ទូលថា ចូរទទួលព្រះវិញ្ញាណបរិសុទ្ធចុះ"* (យ៉ូហាន ២០:២២)។ ប្រយោគទាំងនេះបង្ហាញថា បុគ្គលនៃមនុស្ស និងការផ្លុំរបស់ទ្រង់ មិនអាចធ្វើឲ្យខុសពីគ្នាទេ។ បើយើងមិនអាចធ្វើឲ្យខុសពីគ្នាទេ នោះយើងមិនអាចមានជោគជ័យក្នុងការបញ្ជាក់ថា បុគ្គលនៃព្រះយេស៊ូ នឹងព្រះវិញ្ញាណបរិសុទ្ធគឺជាបុគ្គលផ្សេងគ្នា នឹងដាច់ដោយឡែកពីគ្នា។

**ព្រះគ្រីស្ទ** *(ព្រះបន្ទូល)* បានមកពី**ព្រះវរបិតា** *(ព្រះវិញ្ញាណអស់កល្ប)* និងត្រូវតែវិលទៅព្រះវរបិតាវិញ បន្ទាប់ពីទ្រង់បានរងទុក្ខរួចហើយ (យ៉ូហាន ១៦:២៨)។ ប៉ុន្តែទ្រង់បានសន្យាថា *"ខ្ញុំមិនចោលឲ្យអ្នករាល់គ្នានៅកំព្រា (ពាក្យក្រិកៈអរហ្វាណូស-គ្មានឪពុកម្តាយ-គ្មានឪពុក)ទេ ខ្ញុំនឹងមកឯអ្នករាល់គ្នាវិញ"* យ៉ូហាន ១៤:១៨។ ១០ថ្ងៃក្រោយមក បន្ទាប់ពីទ្រង់យាងទៅលើ ទ្រង់បានចេញមកពីរន្ធ (ប្រភព)ទឹកដ៏អស្ចារ្យដែលនៃជីវិតម្តងទៀត ដើម្បីគង់នៅជាមួយពួកជំនុំរបស់ទ្រង់ និងក្នុងគ្រប់អវះយវះ ជាវិញ្ញាណនៃព្រះវរបិតា (កាឡាទី ៤:៦ វិវរណៈ ២១:៧)។ ទ្រង់មិនអាចធ្វើការនេះបានទេ នៅខាងខណៈ ដែលទ្រង់បាននៅលើផែនដីជាបុគ្គលបានកើតមកនៅក្នុងលោកីយ៍នេះ ប៉ុន្តែទ្រង់អាចធ្វើហើយឥឡូវនេះនៅក្នុងទំរង់ជាវិញ្ញាណ (យ៉ូហាន ១៤:១៦-២០)។ ដូច្នេះ បុគ្គលនៃព្រះយេស៊ូ នៅក្នុងទំរង់ជាព្រះវិញ្ញាណបរិសុទ្ធនៃព្រះកំពុងតែនៅជាប់ក្នុងពួកបរិសុទ្ធដែលជឿ-ព្រះបន្ទូលរបស់ទ្រង់។

ឡូហ្គុស: ការចាប់ផ្ដើមដំបូងនៃការបង្កើតរបស់ព្រះ

*"ឯងអ្នករាល់គ្នា ក៏បានឮព្រះបន្ទូលនៃសេចក្ដីពិត គឺជាដំណឹងល្អសេចក្ដីសង្គ្រោះរបស់អ្នករាល់គ្នាដោយសារទ្រង់ដែរ ហើយកាលអ្នករាល់គ្នាបានជឿហើយ នោះទ្រង់ក៏ដៅចំណាំ ដោយព្រះវិញ្ញាណបរិសុទ្ធ ដែលបានសន្យា"* (អេភេសូរ ១:៣) ។

ពាក្យទាំងនេះរបស់សាវកប៉ូលបានចង្អុលយ៉ាងច្បាស់ទៅឯព្រះ វិញ្ញាណបរិសុទ្ធដែលគង់នៅក្នុងយើង *"ព្រះគ្រីស្ទទ្រង់សណ្ឋិតនៅក្នុងអ្នករាល់គ្នា ដែលជាទីសង្ឃឹមយ៉ាងឧត្ដម"* (កូល៉ុស ១:២៧ សូមមើល៨:៩.១១)។ បាទ យើងបានមានបរិបូរតាមរយះភាពក្រីក្ររបស់ព្រះគ្រីស្ទ *"ដ្បិតអ្នករាល់គ្នាបានស្គាល់ព្រះគុណនៃព្រះយេស៊ូគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នាហើយថាទោះបីទ្រង់ជាសេដ្ឋីក៏ដោយ គង់តែទ្រង់បានត្រឡប់ជាក្រ ដោយព្រោះអ្នករាល់គ្នា ដើម្បីឲ្យអ្នករាល់គ្នាបានមានឡើង ដោយសារសេចក្ដីក្រររបស់ទ្រង់"* (២កូរិនថូស ៨:៩ អេភេសូរ ២:១៣-១៦)។

ហេតុនេះ ការ ជាប់នៅក្នុងពួកបរិសុទ្ធនៃព្រះ គឺមិនមែនបុគ្គលនៃព្រះ ២ ឬ ៣ ទេ។ សព្វនាម *"យើង"* និង *"របស់យើង"* នៅក្នុងសញ្ញាថ្មីដូចនៅក្នុងយ៉ូហាន ១៤:២៣ និយាយពីភាពខុសគ្នារវាង ព្រះជាអ្វី ជាយ៉ាវេដ៏មានគ្រប់ព្រះចេស្ដា និងទ្រង់ជាអ្វី ជាអ្នកសង្គ្រោះ នៅក្នុងមនុស្សយេស៊ូអា។ នៅក្នុងយ៉ូហាន ១២:៤៥ យើងឃើញប្រតិបត្តការនៃមុខងារ២នៃបុគ្គល១មាននិស្ស័យ ២ យ៉ាង នៅក្នុងព្រះគ្រីស្ទយេស៊ូ-**ជាវិញ្ញាណនៃព្រះវរបិតា ដែលមានចេស្ដាបំផុត សព្វញ្ញូញាណ និងគង់គ្រប់ទីកន្លែង និង វិញ្ញាណនៃព្រះរាជបុត្រា ដែលមានភាពបន្ទាបខ្លួនស្ដាប់បង្គាប់ មានភាពដូចជាសង្ឃ ពេញដោយសេចក្ដីអធិស្ឋាន និងការចុះចូល ។ប៉ុន្តែគឺជាវិញ្ញាណតែ ១** (អេភេសូរ ៤:៤ យ៉ូហាន ៤:២៤)។

## អាលផា និងអូមេកា

*"គ្រានោះបានដល់ចុងបំផុតហើយ ជាវេលាដែលទ្រង់នឹងប្រគល់នគរ ដល់ព្រះដ៏ជាព្រះវរបិតាទៅវិញក្រោយដែលទ្រង់បានទំលាក់អស់ទាំងរាជ្យនិងអំណាចហើយនឹងឥទ្ធិឫទ្ធិទាំងប៉ុន្មានចេញ ដ្បិតគួរឲ្យទ្រង់បានសោយរាជ្យទាល់តែដាក់អស់ទាំងខ្មាំងសត្រូវនៅក្រោមព្រះបាទទ្រង់ឯខ្មាំងសត្រូវចុងក្រោយបង្អស់ ដែលត្រូវបំផ្លាញ គឺជាសេចក្ដីស្លាប់ ពីព្រោះទ្រង់បានបង្ក្រាបគ្រប់ទាំងអស់នៅក្រោមព្រះបាទទ្រង់ហើយ តែដែលថា បានបង្ក្រាបគ្រប់ទាំងអស់ នៅក្រោមទ្រង់នោះទេ ហើយកាលណាទ្រង់បានបង្ក្រាបគ្រប់ទាំងអស់នៅក្រោមទ្រង់ នោះព្រះរាជបុត្រានោះឯង ក៏នឹងត្រូវក្រាបក្រោមព្រះ ដែលបានបង្ក្រាបគ្រប់ទាំងអស់ នៅក្រោមទ្រង់ដែរ ដើម្បីឲ្យព្រះបានធ្វើគ្រប់ទាំងអស់ក្នុងគ្រប់ទាំងអស់"* ( ១កូរិនថូស ១៥:២៤-២៨)។

**ព្រះយេស៊ូ មិនដែលជាព្រះរាជបុត្រាអស់កល្ប របស់ព្រះទេ។ ទ្រង់ជាព្រះរាជបុត្រាតែ១របស់ព្រះ។** ដូចនេះ**ពន្ធកិច្ចភាពជាកូន** នឹងមានពេលចប់ដូចជាមានពេល**ចាប់ផ្តើម**ដែរ។ បន្ទាប់ពីទ្រង់សោយរាជ្យជាស្តេចលើអស់ទាំងស្តេច អស់ ១000 ឆ្នាំហើយ ព្រះយេស៊ូគ្រីស្ទនឹងគង់លើបល្ល័ង្កសដ៏ធំ ដើម្បីបើកការជំនុំជំរះចុងក្រោយ និងសំងាចផែបដីចេញពីគំនរនៃអំពើបាប និងសេចក្តីស្លាប់ បន្ទាប់ពីនោះមកទៀត ទ្រង់នឹងប្រគល់រាជ្យនគរ ដែលបានប្រោសលោះហើយទៅឲ្យ*ព្រះវរបិតា* វិញ ដើម្បីឲ្យ*ព្រះវរបិតា* អាចធ្វើជា ***គ្រប់ទាំងអស់ក្នុងគ្រប់ទាំងអស់*** ដូចជានៅកាលដើមដំបូង (ការចាប់ផ្តើមដំបូង) ។ រួចហើយ ព្រះយេស៊ូនឹងមានតួនាទីជាអ្នកដឹងនាំនៃគ្រួសារពួកកូនរបស់ព្រះ ជាបងគេបង្អស់ ជាបងច្បង នៅចំណោមពួកបងប្អូនជាច្រើន ។ **ភាពជាព្រះអម្ចាស់** នៃព្រះយេស៊ូគ្រីស្ទ **សិទ្ធិអំណាចដែលបានផ្តល់ឲ្យ** ដែលជាព្រះហស្តស្តាំនៃកេរ្ត៍អាករ (មត៌ត) ប្រទានមកពីព្រះវរបិតា ហើយដែលកំពុងតែដំណើរការនៅបច្ចុប្បន្ននេះ នឹងត្រូវដាក់ឲ្យចុះចូលនឹងព្រះដ៏កំពូល-"***ដើម្បីឲ្យព្រះបានធ្វើជាគ្រប់ទាំងអស់ក្នុងគ្រប់ទាំងអស់***"។

វិវរណៈ១:៨ ព្រះអម្ចាស់ *ដែលគង់នៅ ក៏គង់នៅតាំងតែពីដើម ហើយដែលត្រូវយាងមកទៀត ជាព្រះដ៏មាន*(ឫទ្ធិ) ព្រះចេស្តាបំផុត (ជាព្រះវិញ្ញាណដ៏ធំ ហើយខ្ពស់បំផុ ដែលគង់នៅអស់កល្បជានិច្ច ) បានមានបន្ទូលថា

*"អញជាអាលផា និងអូមេកា ជាដើម (ការចាប់ផ្តើម) ហើយជាចុង (ការបញ្ចប់)"*។

ខនេះនិយាយអំពីទ្រង់ ដែលគង់នៅអស់កល្ប ទាក់ទងនឹងផែនការនៃការបង្កើតរបស់ទ្រង់និងរបៀបដែលទ្រង់នឹងបញ្ចប់ដោយគ្រប់លក្ខណ៌ថា ទ្រង់បានគិតគូរទុក និងបានតាំងឡើង ក្នុងការចាប់ផ្តើមតាមព្រះដំរិះនៃព្រហ្មទ័យផ្ទាល់របស់ទ្រង់។ ហើយកាលដែល ***ពេលវេលា***-"*ការចាប់ផ្តើម និងការបញ្ចប់*" -បានចូលទៅក្នុង***វង្វង់អស់កល្ប*** នៅក្នុងព្រះជាព្រះវិញ្ញាណអស់កល្ប នោះនឹងមានតែ***ភាពអស់កល្ប***ប៉ុណ្ណោះ។

——— ចប់ ———

ឡូហ្គុស: ការចាប់ផ្តើមដំបូងនៃការបង្កើតរបស់ព្រះ



## ទំនៀមទំលាប់របស់ពួកជំនុំជាច្រើន ពោលថាៈ




## ព្រះបន្ទូលរបស់ព្រះចែងថា

"បុព្វបុរសរបស់យើងនាំគ្នាថ្វាយបង្គំព្រះជាម្ចាស់នៅលើភ្នំនេះ... អ្នករាល់គ្នាមិនស្គាល់ព្រះអង្គដែលអ្នករាល់គ្នាថ្វាយបង្គំទេ... រីឯយើងវិញ យើងស្គាល់ព្រះអង្គដែលយើងថ្វាយបង្គំ ដ្បិតការសង្គ្រោះចេញមកពីជនជាតិយូដា។ ប៉ុន្តែ ដល់ពេលកំណត់ គឺឥឡូវហ្នឹងហើយ អ្នកថ្វាយបង្គំដ៏ពិតប្រាកដ នឹងថ្វាយបង្គំព្រះបិតាតាមវិញ្ញាណ និងតាមសេចក្តីពិត ដ្បិតព្រះបិតាសព្វព្រះហឫទ័យនឹងអ្នកថ្វាយបង្គំបែបនេះឯងថ្វាយបង្គំព្រះអង្គ ត្រូវតែថ្វាយបង្គំតាមវិញ្ញាណ និងតាមសេចក្តីពិត"។

ព្រះគឺត្រឹមត្រូវ (ការបើកសំដែង, សេចក្តីពិត)
ហើយនៅក្នុងទ្រង់មិនមែនជាភាពងងឹតទេ។
(ប្រពៃណីភាពមិនពិត) ទាល់តែសោះ"

# * សេចក្តីបន្ថែម *

## គោលលទ្ធិនៃព្រះត្រៃឯក

គោលលទ្ធិនៃព្រះត្រៃឯក (៣-នៅក្នុង-ព្រៃតែ១) ត្រូវបានទទួលស្គាល់ និងពិពណ៌នាដោយគ្រូបង្រៀនភ្លៀងក្លាភាគច្រើនថា ជា "*សេចក្តីអាថ៌កំបាំងខ្ពស់ជាងការពន្យល់ ឬការបង្កើតទស្សនៈ*" ទៅទៀត។ តែការពិត គឺជារឿងភាន់ច្រឡំ ( វឹកវរ)សោះ!

នៅក្នុងសៀវភៅរបស់អាលិកសិនឌ័រ ហ៊ីសឡប មានចំណងជើថា បាប៊ីឡូនទាំង២ "(the two babylons)" បានរកឃើញ ការអនុវត្ត នឹងសេចក្តីបង្រៀននៃសាសនាពួករ៉ូម៉ាំងឆ្ពោះទៅពួកថ្វាយបង្គំរូបព្រះរបស់សាសាន៍ដទៃ ហើយបញ្ជាក់ថា ជាការថ្វាយបង្គំសេចប៉ាប នៅក្នុងភាពដើមរបស់វា ជាការបង្គំនីមរ៉ុឌ និងប្រពន្ធរបស់គាត់ ។ មើលលោក ១០:៨-១២ ។

បើយើងប្រៀបធៀប សាសនារ៉ូម៉ាំងកាតូលិក ជាមួយនឹងសាសនាបាប៊ីឡូនពីបុរាណ (យើងក៏អាចសន្និដ្ឋានបានថា ពួកប្រូតែស្តង់និយាម ក៏ពិបាករើបំរាស់ចេញពីពួកកាតូលិកនិយមដែរ) ហ៊ីសឡបប្រើឃ្លា "*ព្រះត្រៃឯក ក្នុងឯកភាពតែ១*" ជាប្រធានបទដំបូងគេបង្អស់។ ដកស្រង់ចេញពីប្រភពរក្សាសិទ្ធិផ្សេងៗ វាបានបង្ហាញថា គំនិតនៃព្រះត្រៃឯក គឺជាគំនិតពីបុរាណ។ "*នៅក្នុងការឯកភាពតែ១នៃព្រះតែ១គត់របស់ពួកបាប៊ីឡូន មានបុគ្គល ៣ ហើយ ពួកគេមានការងារ ត្រីកោណស្មើៗគ្នា ដូចជាគេបានដឹងយ៉ាងច្បាស់ថា ពួកជំនុំរ៉ូម៉ាំងក៏ធ្វើអញ្ចឹងដែរនៅសព្វថ្ងៃនេះ*"។ (ទំព័រ ១៦) "*ការថ្វាយបង្គំស្តេចប៉ាបមានវិហារនៃពួកជឿព្រះត្រៃឯកមានតែឈ្មោះរបស់ម៉ាឌ្រីឌ ជារូបភាពនៃព្រះត្រៃឯក (ត្រីឯក) ដែលមានក្បាល៣ នៅលើខ្លួនតែ១*" (ទំព័រ ១៧)។ វាស្រដៀងទៅនឹងរូបព្រះក្បាល ៣ដែលគេរកឃើញនៅប្រទេសឥណ្ឌាមានរូបភាពជាព្រះកំពូលពីបុរាណនិងនៅប្រទេសជប៉ុនរូបព្រះពុទ្ធ (ទំព័រ ១៧-១៨)។ "*ការទទួលស្គាល់ព្រះត្រៃឯក មានជាសកលនៅក្នុងប្រជាជាតិពីបុរាណនៃពិភពលោក*"(ទំព័រ ១៨)

មានខ្លឹមសារដដែល១ដែលមើលទៅដូចទៅនឹងសញ្ញាចាស់ គឺរូបព្រះ ឬរូបចម្លាក់ព្រះគួរឲ្យស្អប់ ។ព្រះនៃអ៊ីស្រាអែល មិនដែលប្រដូចព្រះអង្គទ្រង់ទៅនឹងសេចក្តីស្អប់ខ្ពើមរបស់សាសន៍ដទៃណាឡើយ ។

ខាងក្រោមនេះ គឺជាសេចក្តីបង្រៀនពីព្រះត្រៃឯក ដោយគ្រូបង្រៀនខាងព្រះត្រៃឯក ដ៏ល្បីល្បាយ២រូប :

"*អ្វីដែលយើងចង់និយាយ គឺថា ព្រះត្រៃឯកមានបុគ្គល ៣ ផ្សេងគ្នា និងដាច់ដោយឡែកពីគ្នា នៅក្នុងព្រះដ៏ជាកំពូល បុគ្គលនិមួយៗមានរូបកាយខាងវិញ្ញាណផ្ទាល់ខ្លួន ព្រលឹងផ្ទាល់ខ្លួននិងវិញ្ញាណផ្ទាល់ខ្លួន ដូចគ្នានិងមនុស្ស*

*លោក ទេវតា ឬអ្វីផ្សេងទៀត ដែលមានរូបកាយផ្ទាល់ខ្លួនព្រលឹង និងវិញ្ញាណដែរ ។ឯរូបកាយដែលយើងចង់និយាយ មិនថា ជារូបកាយខាងវិញ្ញាណ ឬរូបកាយសាច់ឈាម ជាផ្ទះសមរាប់ឲ្យព្រលឹង និងវិញ្ញាណគង់នៅខាងក្នុង ។ ព្រលឹងគឺអ្វីដែលមានអារម្មណ៍ដឹង ហើយវិញ្ញាណគឺអ្វីដែលដឹងស្គាល់"* (ហ្វីនីស ចេ. ឌេក. គម្ពីរមានឯកសារយោងពន្យល់ របស់ឌេក) (finis J.Dake, Dakes Annotated Reference Bible )

ខេត អេល ប្រ៊ូក្ស និយាយថា *"បើសិនជាគោលលទ្ធិនៃព្រះត្រៃឯក មិនអាចទទួលយកបាន នោះ ព្រះគ្រីស្ទមិនមែនមានភាពជាព្រះទេ ហើយលក្ខណះនៃកិច្ចការប្រោសលោះរបស់ទ្រង់ ត្រូវបានដកចេញទទេ។ បើសិនជាមានព្រះត្រៃឯក ហើយការថ្វាយបង្គំមិនរួមព្រះយេស៊ូ និងព្រះវិញ្ញាណបរិសុទ្ធទេ នោះការថ្វាយបង្គំដ៏ត្រឹមត្រូវ ត្រូវបានដកយកចេញពីព្រះដ៏ជាកំពូល ២ភាគ៣ ហើយ"* (ដកស្រង់ចេញពីសៀវភៅ នំប៉័ងប្រចាំថ្ងៃរបស់យើង *'Our Daily* Bread' ៨ កក្កដា ១៩៧១ )។

ទាំងនេះគឺជាពាក្យរបស់ពួកមនុស្ស ដែលមានប្រាជ្ញាតាមទស្សនះផ្ទាល់ខ្លួនរបស់ពួកគេ។ពួកគេគ្រាន់តែធ្វើឲ្យខ្លួនឯងទៅជាឆ្កួត ដោយសំដែងនូវភាពល្ងង់ខ្លៅនិងភ្លឺភ្លើប៉ុណ្ណោះ។

**តើព្រះអង្គម្ចាស់យេស៊ូគ្រីស្ទគ្រាន់តែ មាន ១ភាគ៣ នៃព្រះដ៏ជាកំពូល ?** (១ធីម៉ូថេ ៣:១៦ និងកូល៉ុស ២:៩ បានចែងយ៉ាងច្បាស់ថា **ព្រះបានលេចមកក្នុងសាច់ឈាម ហើយថាព្រះអម្ចាស់យេស៊ូគ្រីស្ទ មានគ្រប់ទាំងសេចក្តីពោរពេញនៃព្រះដ៏ជាកំពូល ទាមងមានរូបអង្គផងវាមានន័យយ៉ាងសាមញ្ញថាព្រះតែ ១ នៅក្នុងបុគ្គលតែ១ គឺព្រះយេស៊ូគ្រីស្ទ។**

ពួកជឿព្រះត្រៃឯកបានក្លាយទៅជាអ្នកកាប់សាច់ នៅពេលដែលពួកគេបា*នកាត់ព្រះទៅជា ៣ ផ្នែកស្មើៗគ្នា* ដើម្បីបង្កើត *ព្រះ៣អង្គ* ចេញពីព្រះដ៏មានព្រះចេស្តាបំផុតតែ១ ។ គ្មានកន្លែងណា១នៅក្នុងគម្ពីរ មានការកត់ត្រាទុកថា ព្រះ ជាព្រះត្រៃឯក ឬព្រះត្រៃសរណគមន៍ទេប៉ុន្តែ ពួកជឿខាងព្រះត្រៃឯកអាចដកស្រង់ អត្ថបទគម្ពីរខ្លាំងៗ៨០ ដើម្បីបង្ហាញពីភាពគង់នៅនៃ*ព្រះត្រៃឯក* ។

គោលលទ្ធិព្រះត្រៃឯក នេះ ត្រូវបានគេបង្កើតឡើងនៅពេលណា១ បន្ទាប់ពីពួកសាវកបានស្លាប់អស់ទៅ នៅក្នុងសតវត្សទី២ ។ មានពួកទេវវិទូល្បីៗជាច្រើន បានខំដោះស្រាយព្រះដ៏ជាកំពូល។ នៅក្នុងចំណោមមនុស្សទាំងនោះ ដូចជា អ៊ិកណាធាស (Irenaeus) ប៉ូលីខាប់ (Poly-Carp) ចឹស្ទីន ម៉ាទ័រ (Justin Martyr) អ៊ែរីណឺស (Irenaeus) ក្លេមិន្ស (Clemens) នឹងអ្នកផ្សេងៗជាច្រើនទៀត ។

ឡូហ្កុស: ការចាប់ផ្តើមដំបូងនៃការបង្កើតរបស់ព្រះ

សូមមើលពីរបៀបដែល ចឹស្ទីន បានទទួលលការត្រឹមត្រូវ និងបន្ទាប់មក បានធ្លាក់ទៅក្នុងការខុសឆ្គង និងការភាន់ច្រឡំវិញ។

*"គាត់ ( ចឹស្ទីន) មានការពិបាកយ៉ាងខ្លាំងក្នុងការសំដែងចេញពីចំនុចទស្សនះនេះ វាជាការពិត គាត់មានហេតុផលនៃហ្វីឡូ (Philo) ហើយព្រមទាំង អ្នកបរិសុទ្ធ យ៉ូហានដ្បិតនៅក្នុងអ្នកបរិសុទ្ធ យ៉ូហាន ឡូហ្កុស ឬ ហេតុផល ឬ ព្រះបន្ទូល គឺជាព្រះចេស្តា ដែលដោយសារទ្រង់ព្រះបានបង្កើតពិភពលោក និងពន្លឺផងដែរ ដែលបំភ្លឺគ្រប់មនុស្ស ដែលចូលមកលោកីយ៍នេះ បើសិន វាជាការបកប្រែត្រឹមត្រូវមែនប៉ុន្តែចឹស្ទីនប៉ងនឹងកំនត់ន័យបញ្ហានេះយ៉ាងច្បាស់បំផុត។ ហេតុផលមកពីព្រះ គឺជាព្រះទី២។ ទ្រង់ជាព្រះទី២ នៅក្នុងចំនួន ប៉ុន្តែមិនមែននៅក្នុងគំនិតទេគឺត្រូវនិយាយយ៉ាងនោះឯង។ ទ្រង់ជាព្រះទី ២ ហើយ ទ្រង់មិនមែនជាព្រះទី ២ទេ"។* ( វចនានុក្រមជីវប្រវត្តិផ្ទាល់ខ្លួនរបស់គ្រីស្ទាន ( Dictionary of Christian Biography)។

ឥឡូវ សូមមើលថាតើអាចយល់ការនេះឬក៏អត់

*"អ្នកខ្លះនិយាយថា មានតែសារធាតុតែ១ប៉ុណ្ណោះ នៅក្នុងព្រះដ៏ជាកំពូល អ្នកខ្លះទៀតថាមាន ៣។ អ្នកខ្លះក៏យល់ស្រប ខ្លះក៏បដិសេធពាក្យទាំងនេះ យោងទៅតាមពួកគេទទួលការដឹកនាំពីក្រុមបក្សពួកដែលល្បីនៃសម័យនោះ ហើយការវិនិច្ឆ័យផ្ទាល់របស់បយកគេទាក់ទងនឹងរបៀបសំរេចការនេះ អ្នកខ្លះប្រកាសថា ព្រះមាន៣តាមចំនួន អ្នកផ្សេងទៀតថាតាមចំនួនគឺតែ១ទេផ្ទុយទៅវិញចំពោះអ្នកផ្សេងទៀត វាអាចលេចនូវទស្សនះវិជ្ជាច្រើនជាងមុន ដើម្បីដកចំនួនទាំងអស់ចេញ នៅក្នុងការពិភាក្សាថា និស្ស័យអាថ៌កំបាំង គឺជាលើការប្រៀបធៀប ថាតើបានមើលឃើញ ១ ឬ ៣ ហើយកុំឲ្យធ្លាក់ចុះក្រោម ឬបង្កើតជាគ្រឹះស្រមើស្រម៉ៃ"។* (អារាន នៃសតវត្សទី៤ (The Arian Of the 4th Century)។

ជាច្រើនសតវត្សមកហើយដែលគិលលទ្ធិនៃព្រះត្រៃឯកនេះបានជា គោលលទ្ធិគ្រឹះរបស់ពួកជំនុំកាតូលិក ក្រុមផ្សាយដំណឹងល្អ នឹងប្រូតែស្តង់ភាគច្រើន ។ ប៉ុន្តែគោលលទ្ធិនេះមិនមែនជាផ្នែកនៃ "*សេចក្តីជំនឿដែលបានប្រទានមកពួកបរិសុទ្ធ១ ដងជាសំរេចនិះទេ*" (យូដាស៣ )។
សេព្វវចនាធិប្បាយកាតូលិក បានថែងថា

*"នេះ (ព្រះត្រៃឯក) ដែលពួកជំនុំបានបង្រៀន គឺជាការបើកសំដែងទាក់ទងនឹងនិស្ស័យរបស់ព្រះ ដែលព្រះយេស៊ូគ្រីស្ទ ព្រះរាជបុត្រានៃព្រះ បានយាងមកផែនដីដើម្បីសង្គ្រោះមនុស្សលោក ហើយនាង ( ពួកជំនុំកាតូលិក ) ប្រកាសដល់មនុស្សថា ជាមូលដ្ឋានគ្រឹះនៃប្រពន្ធ័គោលលទ្ធិទាំងអស់"* ។

ហេតុនេះ យើងអាចឃើញថា គឺពួកជំនុំម៉ាំងកាតូលិកទេ ដែលបង្កើតគោលលទ្ធិនៃព្រះត្រៃឯក ថាជាគោលលទ្ធិគ្រឹះនៃប្រពន្ធ័គោលលទ្ធិទាំងអស់របស់នាង។ ហើយនៅក្នុង ឆ្នាំ៣២៥ គ,ស ដែល "*គោលលទ្ធិខុសឆ្គងនៃព្រះត្រៃឯកបានកំនត់ឡើង ព្រះតែ១ក្នុងបុគ្គល* បានធ្វើឲ្យមានការផ្លាស់ប្តូរ ***ទាំងស្រុង នៅក្នុងជីវិត និងការគិតរបស់គ្រីស្ទាន***"។ ("*ព្រះត្រៃឯកដ៏បរិសុទ្ធ*"-ក្នុងសៀវភៅសព្វវចនាធិប្បាយកាតូលិក ថ្មី )។

នេះគឺជាការកក់ត្រាទុក បង្ហាញពីជំនឿនៃព្រះត្រៃឯក

"*យើងមានអាចសង្ស័យពីការកើតមានឡើងនៅក្នុងចំណោមពួកឪពុកអរដុក្សនៃមតិខុសៗគ្នាអំពីប្រធានបទដ៏អាថ៌កំបាំងនេះ រហូតទាល់តែមាននិយមន័យចុងបញ្ចប់បង្កើតដោយ ពួកជំនុំ*"។ (វចនានុក្រមនៃគោលលទ្ធិ នឹងប្រវត្តិទេវវិទ្យា)

ហើយជាការពិត គោលលទ្ធិនៃព្រះដ៏ជាកំពូលមាននិយមន័យចុងបញ្ចប់-*កំណើតនៃ៣អង្គក្នុងព្រះតែ១*-ក្នុងឆ្នាំ ៣២៥ គ,ស ប្រហែល ៣០០ ឆ្នាំ បន្ទាប់ពីការសុគតការរស់ឡើងវិញនឹងការលើកឡើងទៅស្ថានសួគ៌របស់ព្រះ គ្រីស្ទ! គឺជារ៉ូម៉ាំសាសន៍ដទៃ ដែលបានដឹកនាំឲ្យបង្កើតគោលលទ្ធិនេះឡើង! គឺជាគោលលទ្ធិសាសន៍ដទៃ ដែលបានចាប់ផ្តើមដោយពួកជំនុំសាសន៍ដទៃ!អ្នកអាចរកឃើញ "*ព្រះត្រៃឯក*" នេះ នៅក្នុងគោលលទ្ធិណៃសិន (Nicene Creed) បង្កើតឡើង ដោយក្រុមប្រឹក្សាណៃសៀ (the Council of Nicea) ក្នុងឆ្នាំ៣២៥ គស។ គោលលទ្ធិរបស់ពួកសាវក មានតែឈ្មោះនេះ (ឆ្នាំ ១០០-១៥០ គស) ដែលមិនបានចែងទុកដោយពួកសាវក១សោះ ក៏មិនបានកំនត់និយមន័យឲ្យព្រះដ៏ជាកំពូលថា ជាព្រះត្រៃឯកទេ។ "*វាមិនមែន ដូចជាបានឃើញព្រះបន្ទូលនៃព្រះរួចហើយ ផ្ទាល់ និងភ្លាមៗទេ*"។ (សព្វវចនាធិប្បាយកាតូលិកថ្មី)។ ជាការពិត គឺ មិនដែលឃើញមាននៅក្នុងព្រះបន្ទូលនៃព្រះទេ!

តាំងពីពេលនោះមក គោលលទ្ធិខុសឆ្គងនេះបានធ្វើឲ្យមានការផ្លាស់ប្តូរទាំងស្រុង នៅក្នុងជីវិត និងការគិតរបស់គ្រីស្ទាន ហើយសព្វថ្ងៃនេះ គ្រីស្ទានភាគច្រើនពិបាកនឹងបោះបង់គោលលទ្ធិខុសនៃព្រះដ៏ជាកំពូលនេះណាស់ ។ ពួកគេបានទទួលគោលលទ្ធិពីប្រពន្ធ័ពួកជំនុំឲ្យជឿ និងទទួលយកវាថា ជា*សេចក្តីអាថ៌កំបាំង*។

វាពិតជាសេចក្តីអាថ៌កំបាំងមែន ព្រោះប្រពន្ធ័ពួកជំនុំជាអ្នកបង្កើតវាមក។ ត "*មូលហេតុដែលជាផលផ្លែនៃសេចក្តីខុសឆ្គងនេះ នៅក្នុងសម័យបុរាណ និងទំនើប បានសារភាពជាការប៉ុនប៉ង ដើម្បីពន្យល់ ឬបំភ្លឺគោលលទ្ធិនេះ ដោយបំភ្លេចថាវាជាសេចក្តីអាថ៌កំបាំងដើម្បីឲ្យគេទទួលជាសេចក្តីជំនឿ ដែល*

ឡូហ្កុស: ការចាប់ផ្តើមដំបូងនៃការបង្កើតរបស់ព្រះ

*មិនអាចបង្ហាញដោយឆ្លាត ដល់បញ្ហារបស់មនុស្សពីនិស្ស័យផ្ទាល់របស់វាទេ*" ( "ព្រះត្រៃឯក" វចនានុក្រមនៃគោលលទ្ធិ និងប្រវត្តិទេវវិទ្យា)។

តើអាចឲ្យពួកអ្នកដែលជឿពិត ដោយសេចក្តីជំនឿ លើអ្វី ដែលមិនមានទាស់តែសោះឬ? *ព្រះត្រៃឯក* តែងតែជាសេចក្តីអាថ៌កំបាំង ដែលមានពេញទៅដោយរឿងចំរូងចំរះ ហើយអ្នកណាក៏ដោយ ក៏ពិបាកយល់ដែរ។ ការប៉ុនប៉ងសិក្សាទាំងអស់ដើម្បីយល់ការនេះ បានបណ្តាលឲ្យកើតមានការយល់ច្រឡំតែប៉ុណ្ណោះ! ការប៉ុនប៉ងរបស់ទេវវិទូទាំងអស់ក្នុងការបញ្ជាក់ការនេះបាននាំមកនូវការភាន់ច្រឡំកាន់តែច្រើន។

ហេតុអ្វី?

ជាសាមញ្ញ ព្រោះវាជារឿងប្រឌិត ដែលមនុស្សបានបង្កើត! អ្នកសិក្សាគម្ពីរទាំងអស់បានសារភាពថា គ្មានឯកសារយោងទៅលើ*ព្រះត្រៃឯក* នៅក្នុងគម្ពីរទេះ វា**គ្រាន់តែបានបង្ហាញដូចជាពួកគេនិយាយប៉ុណ្ណោះ**។ ការប៉ុនប៉ងរបស់ពួកគេក្នុងការបកស្រាយបទគម្ពីរដ៏សាមញ្ញនេះដោយបទគម្ពីរមិនច្បាស់សាល់ បានក្លាយទៅចាការអនុវត្តដ៏ឆ្គួតចាស់កំរិល។

ហេតុអ្វីបានជាពួកគេមិនរើសវិធីសាស្រ្តងាយទទួល និងភ្លឺថ្លាជាងនេះសំរាប់បញ្ហានេះទៅ? នោះគឺជា ការប្រើប្រាស់បទគម្ពីរដ៏សាមញ្ញនេះ ដើម្បីវិភាគ និងយល់បទគម្ពីរមិនច្បាស់លាស់!

ឱ ពួកអ្នកជឿគម្ពីរដែលគ្មានសង្ឃឹមអើយ ពិតជាត្រូវការការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធយ៉ាងណាទៅដើម្បីជួយពួកគេ ដើម្បីញែកសេចក្តីពិតផ្ទាល់របស់ព្រះ ចេញពីគោលលទ្ធិប្រឌិតនិងតាមការនិយាយរបស់មនុស្សនៅចាងសាច់ឈាម!

* * * * * * *

## ភាពជាព្រះត្រៃឯក



...គេថ្វាយបង្គំនៅក្នុងប្រទេសអាស៊ីរី (Assyria)(អាសស៊ើរ)ពីបុរាណ



...គេបានថ្វាយបង្គំនៅក្នុង ចំណោមពួកសាសន៍ដទៃនៃស៊ីបេរី (Siberia)

*កុងស្តង់ទីនសោយរាជ្យ គ្រីស្ទសាសនាត្រូវបានប្រកាសថា ជាសាសនារដ្ឋរបស់ចក្រភពរ៉ូងម៉ាំង។ ដោយហេតុនេះហើយ បានជាមនុស្ស១ចំនួនធំ បានចាប់ផ្តើមបើកការពិភាក្សាជាចំហ១អំពីបញ្ហានៃទេវវិទ្យាប្រធានបទមុននេះថាសក្តិសមនឹងពួកទស្សនះវិទូ។ ឥទ្ធិពលខាងទស្សនវិជ្ជារបស់ប្លាតុង អំពីយ៉ូហាន ១១ និងបទគម្ពីរផ្សេងទៀត បាននាំឲ្យមានសេចក្តីពេញចិត្តយ៉ាងខ្លាំង ថា ជា "តួអង្គ" នៃឡូហ្កុស ។*

*អារៀស (Arius) ជាអ្នកចាស់ទុំរបស់អាលិកសិនឌ្រា (Alexendria) នឹងជាអ្នកដឹកនាំនៃគោលលទ្ធិ-អារៀសនិយម-បានបង្រៀនថា ព្រះយេស៊ូជារបស់បង្កើតដំបូង "បានបង្កើតជាព្រះទី២" មានឋានះតូចជាងព្រះដ៏មានគ្រប់ព្រះចេស្តា។ ដូចជាផ្ទុយនឹងទស្សនះរបស់ពួកជឿព្រះត្រៃឯក គាត់បានបង្រៀនថា ព្រះយេស៊ូមិនមែនស្មើ ឬមានអត្តសញ្ញាណជាមួយព្រះជាព្រះវរបិតាទេ។*

*គឺនៅឯក្រុមប្រឹក្សាណៃសិន ក្នុងឆ្នាំ ៣២៥ គ,ស ដែលគោលលទ្ធិណៃសិន បានបង្កើតជារូបមន្តឡើង ដើម្បីញែកអារៀសនិយម និងពួកជំនុំ ឲ្យទទួលគោលលទ្ធិនៃព្រះជាកំពូលត្រៃឯកក។ ទោះបីយ៉ាងណាក៏ដោយ ការបើកសំដែងនៃព្រះបន្ទូលព្រះអាចផ្ទៀងផ្ទាត់ថា គោលលទ្ធិទាំង២នេះ ទោះជាត្រូវជាផ្នែកៗ ក៏មានពេញដោយសេចក្តីខុសឆ្គងជាច្រើនដែរ ។*

*អាថាណាសៀស។*

*(Athanasius) អ្នកជំនួយដែលបានដឹកនាំការប្រឆាំងនឹងអារៀស ក្រោយមកក៏ក្លាយជាអភិបាលរបស់អាលិកសិនឌ្រា។ គោលលទ្ធអាថាណាសៀសឃើញមាននៅក្នុងសៀវភៅនៃការអធិស្ឋានទូទៅ បង្ហាញដោយគូសបញ្ជាក់យ៉ាងច្បាស់ថា ការឈរឡើងរបស់ពួកជំនុំដោយការគោរពដល់ចំនួនដ៏ធំនៃព្រះជាច្រើន។*

→

ឡូហ្កុស: ការចាប់ផ្តើមដំបូងនៃការបង្កើតរបស់ព្រះ

**នេះគឺជាព្រះត្រៃឯក-តើអ្នកអាចជឿឬទេ?**

នេះជាអ្វី ដែលកំពុងតែការពារ-បើអ្នកមិនចង់ធ្វើជាពួកជឿព្រះត្រៃឯក!

## គោលលទ្ធិអាថាណាសៀស

-ជាគោលលទ្ធិគ្រឹះនៃព្រះត្រៃឯក ដែលបានយល់ព្រម
ដោយពួកជំនុំកាតូលិក ប៉ង់តាកូស និងប្រូតែស្តង់

ដកស្រង់ចេះពីសព្វវចនាធិប្បាយ New Schaff Herzog នៃការយល់ដឹងអំពីសាសនា វ៉ុល ១១ ទំព័រ ២០២ ដកស្រង់ចេញពី The Guardian London ១០,១១,១៩០៩ ដែលចេញជាការបកប្រែថ្មីគោលលទ្ធិអាថាណាសៀសបង្កើតឡើងដោយការស្នើសុំរបស់ទេសាភិបាលនៃ Canterbury យោងទៅតាម ដំណោះស្រាយនៃសន្និសិទ្ធ Lambeth នៃឆ្នាំ ១៩០៨។

៣-ឥឡូវនេះ ជំនឿកាតូលិក គឺយ៉ាងនេះ ថាយើងថ្វាយបង្គំព្រះតែ១ ជាព្រះត្រៃឯក ហើយព្រះត្រៃឯកជាឯកភាពតែ ១ ។

៤-មិនត្រូវបំភាន់បុគ្គលជាច្រើន ឬចែកសារធាតុឡើយ ។

៥-ដ្បិតមានបុគ្គលនៃព្រះវរបិតា១ បុគ្គលនៃព្រះរាជបុត្រា១ និងបុគ្គលនៃព្រះវិញ្ញាណបរិសុទ្ធ១ដែរ

៦-ប៉ុន្តែព្រះដ៏ជាកំពូលនៃព្រះវរបិតា ព្រះរាជបុត្រា នឹងព្រះវិញ្ញាណបរិសុទ្ធ គឺតែ ១ សិរីល្អស្មើគ្នា អំណាចត្រួតត្រា អស់កល្បរួមគ្នា ។

៧-ជឿលើព្រះវរបិតា ជឿលើព្រះរាជបុត្រា និងជឿលើព្រះវិញ្ញាណបរិសុទ្ធ។

៨-ព្រះវរបិតា មិនត្រូវបានបង្កើតមក ព្រះរាជបុត្រា មិនត្រូវបានបង្កើតមក នឹងព្រះវិញ្ញាណបរិសុទ្ធមិនត្រូវបាន បង្កើតមកដែរ ។

៩-ព្រះវរបិតា គ្មានទីបញ្ចប់ ព្រះរាជបុត្រា គ្មានទីបញ្ចប់ និងព្រះវិញ្ញាណបរិសុទ្ធ គ្មានទីបញ្ចប់ដែរ

១០-ព្រះវរបិតាអស់កល្ប ព្រហរាជបុត្រា អសល់កល្ប និងព្រះវិញ្ញាណបរិសុទ្ទ អស់កល្បដែរ។

១១-ហើយប៉ុន្តែពួកគេមិនមែនជា ព្រះអស់កល្ប ៣ទេប៉ុន្តែគឺ ព្រះអស់កល្ប១ ។

១២-ហើយពួកគេក៏មិនមែន ៣ មិនត្រូវបនាបង្កើត ឬ ៣ គ្មានទីបញ្ចប់ ដែរប៉ុន្តែ ១ មិនត្រូវបានបង្កើត នឹង ១ គ្មានទីបញ្ចប់ ។

១៣-ដូចជាព្រះវរបិតាដ៏មានឫទ្ធី ព្រះរាជបុត្រាក៏មានឫទ្ធី ព្រះវិញ្ញាណបរិសុទ្ធក៏មានឫទ្ធីដែរ ។

១៤-ហើយប៉ុន្តែពួកគេមិនមែនព្រះមានដ៏មានឫទ្ធី ៣ ដែរ ប៉ុន្តែ គឺ តែ ១ វិញ ។

១៥-ដូច្នេះព្រះវរបិតា គឺជាព្រះជាម្ចាស់ ព្រះរាជបុត្រា គឺជាព្រះជាម្ចាស់ ព្រះវិញ្ញាណបរិសុទ្ធ គឺជាព្រះជាម្ចាស់

១៦-ហើយពួកគេមិនមែនជាព្រះជាម្ចាស់ ៣ ទេ ប៉ុន្តែ គឺ ព្រះ ( ជាម្ចាស់ ) តែ១វិញ ។

១៧-ដូច្នេះ ព្រះវរបិតា ជាព្រះអម្ចាស់ ព្រះរាជបុត្រា គឺជាព្រះអម្ចាស់ និងព្រះវិញ្ញាណបរិសុទ្ធ ជាព្រះអម្ចាស់ដែរ

## គោលលទ្ធិអាថាណាសៀស

-ជាគោលលទ្ធិគ្រឹះនៃព្រះត្រៃឯក ដែលបានយល់ព្រម
ដោយពួកជំនុំកាតូលិក ប៉ង់តាកូស និងប្រូតែស្តង់

ដកស្រង់ចេះពីសព្វវចនាធិប្បាយ New Schaff Herzog នៃការយល់ដឹងអំពីសាសនា វ៉ុល ១១ ទំព័រ ២០២ ដកស្រង់ចេញពី The Guardian London ១០,១១,១៩០៩ ដែលចេញជាការបកប្រែថ្មីគោលលទ្ធិអាថាណាសៀសបង្កើតឡើងដោយការស្នើសុំរបស់ទេសាភិបាលនៃ Canterbury យោងទៅតាម ដំណោះស្រាយនៃសន្និសិទ្ធ Lambeth នៃឆ្នាំ ១៩០៨។

១៨-ហើយពួកគេមិនមែនជាព្រះអម្ចាស់ ៣ ទេ ប៉ុន្តែ គឺ ព្រះអម្ចាស់តែ ១ វិញ ។

១៩-ដ្បិតដូចជាយើងត្រូវបានបង្ខំដោយជំនឿគ្រីស្ទាន ឲ្យសារភាពថា បុគ្គលនិមួយៗដោយអង្គទ្រង់ផ្ទាល់ ជាព្រះ ( ជាម្ចាស់ ) ផង និងជាព្រះអម្ចាស់ផង។

២០- ដូច្នេះ យើងត្រូវបានហាមដោយសាសនាកាតូលិក មិនឲ្យនិយាយថាមាន ព្រះ ៣ ឬព្រះអម្ចាស់ ៣។

២១-ព្រះវរបិតាមិនមែនជារបស់អង្គណា មិនបានធ្វើ ឬបង្កើត ឬមានឪពុក ។

២២-ព្រះរាជបុត្រាជារបស់ព្រះវរបិតាតែ១គត់ មិនបានធ្វើ ឬបង្កើត ប៉ុន្តែមានឪពុក ។

២៣-ព្រះវិញ្ញាណបរិសុទ្ធជារបស់ព្រះវរបិតា នឹងព្រះរាជបុត្រា មិនបានធ្វើ ឬបង្កើត ឬមានឪពុក ប៉ុន្តែចេញមក។

២៤-ដូច្នេះ មានព្រះវរបិតាតែ ១ មិនមែន ព្រះវរបិតា ៣ ទេ មានព្រះរាជបុត្រាតែ ១ មិនមែន ៣ ទេ មានព្រះ វិញ្ញាណបរិសុទ្ធតែ ១ មិនមែនព្រះវិញ្ញាណបរិសុទ្ធ៣ ទេ។

២៥-ហើយនៅក្នុងព្រះត្រៃឯក គ្មានអង្គណាគង់នៅមុន ឬ ក្រោយទេ គ្មាននរណាធំជាង ឬ តូចជាងទេ។

២៦-ប៉ុន្តែបុគ្គលទាំង ៣ ជាអស់កល្បរួមគ្នា (សហាអស់កល្ប) និងស្មើរួមគ្នា (សហាស្មើគ្នា)។

២៧-ហេតុនេះ ដូចជាបាននិយាយពីមុនរួចមកហើយ ថាយើងថ្វាយបង្គំជាព្រះត្រៃឯកជា ឯកភាពតែ១ ហើយឯក ភាពតែ១ ជាព្រះត្រៃឯក

២៨-ដូច្នេះ សូមឲ្យអ្នកដែលបានសង្គ្រោះ គិតអំពីព្រះត្រៃឯកចេះ។

## ឥឡូវនេះ តើអ្នកជឿលើព្រះត្រៃឯកទៀតឬទេ?

សត្វឥន្ទ្រីស្រែក...





...សត្វព្រាបនាំ

**PROPHETIC*REVELATION**

**Ghim Moh Estate Post Office Box 333**
**Republic of Singapore 912742**